ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-May-2015, 10:53
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២៨២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

កញ្ញា ជា ស៊ីវហ៊ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក សេង លាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វលក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ឱ ហូ (2-TCW-836) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឡិ ហុ** (2-TCW-836)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ..........ទំព័រ ២

សួរដោយលោក សេង លាង ផ្ដើមពី ..........ទំព័រ ៥

សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី ..........ទំព័រ ១៧

សួរដោយលោក ហុង គីមសួន ផ្ដើមពី ..........ទំព័រ ៤៥

សួរដោយចៅក្រម ក្លូឌា ហ្វែនស៍ ផ្ដើមពី ..........ទំព័រ ៥៧

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ..........ទំព័រ ៦២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីទី១ ពាក់ព័ន្ធជាមួយនឹងអង្គហេតុចោទប្រកាន់ការដ្ឋានទំនប់១មករា។ ហើយសាក្សីទី១ ដែលត្រូវស្តាប់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-836។ ក្រឡាបញ្ជីសវនាការ លោកស្រី -- កញ្ញា ជា ស៊ីវហ៉ាង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-836។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនោះទេ។ សាក្សីបានធ្វើសម្បថនៅមុខ -- នៅចំពោះមុខលោកតាដំបងដែករួចហើយ កាលពីព្រឹកមិញនេះ មុននឹងផ្តល់សក្ខីកម្ម។

សូមអរគុណលោកប្រធាន។

[០៩:០៦:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការ ដោយផ្ទាល់ក្នុងបន្ទប់

សវនាការនេះ របស់ជនចាប់ចោទ នួន ជា ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥។ ដោយមេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីសិទ្ធិ -- អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ បានកត់សម្គាល់ថា សុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ មិនអាចអង្គុយយូរបាន និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៩:០២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកឈ្មោះអី?

**លោក ឱ ហួ៖**

**ឆ៖** ខ្ញុំបាទឈ្មោះ ឱ ហួ។

**ស៖** អរគុណលោក ឱ ហ្វ។ តើលោកកើតនៅថ្ងៃខែឆ្នាំណា? លោកចាំទេ?

**ឆ៖** ខ្ញុំកើតនៅថ្ងៃ០៥ ខែតុលា ឆ្នាំ១៩៧០ -- ឆ្នាំ១៩៤៥។

**ស៖** បាទ អរគុណ។ ហើយលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណា?

**ឆ៖** សព្វថ្ងៃ ខ្ញុំមានទីលំនៅនៅភូមិទួលសាលា ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

**ស៖** បាទ អរគុណ។ ហើយតើលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំសព្វថ្ងៃធ្វើស្រែ របររកស៊ីធ្វើស្រែទាន។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ឱ កែត ម្ដាយឈ្មោះ ម៉ម អ៊ុំ។

**ស៖** បាទ អរគុណ ហើយប្រពន្ធរបស់លោកឈ្មោះអី? លោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ សោម រ៉េត។ កូនទាំងអស់ប្រាំបួននាក់ តែស្លាប់អស់បួននាក់ហើយ។

**ស៖** បាទ អរគុណ។ ហើយលោក ឱ ហ្វ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ អម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹងថា លោកមានញាតិលោហិត ឬក៏ញាតិពន្ធត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** ពិតណាស់ទាន។

**ស៖** បាទ អរគុណ។ ហើយថាលោកបានស្បថរួចហើយមុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ពិតមែនដែរទេ?

**ឆ៖** ពិតជាបានស្បថរួចហើយទាន។

[០៩:១១:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក ឱ ហ្វ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើ -- សុំឲ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ច លោក ឱ ហូ ក្នុងនាមលោកជាសាក្សីត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ លោកត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់សាក្សីរួចហើយអម្បាញ់មិញនេះ។

ហើយក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ឱ ហូ តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើធ្លាប់ តើបានធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា?

**លោក ឱ ហូ៖**

**ឆ៖** បាទ ធ្វើនៅឃុំបល្ល័ង្កម្ដង។

[០៩:១៣:៤០]

**ស៖** នៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យ ឬក៏បានអាននូវកំណត់ហេតុ ដែលលោកបានផ្ដល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ទាន វាភ្លេចភ្លាំងខ្លះដែរទាន។

**ស៖** ក៏ប៉ុន្តែលោកបានពិនិត្យទេ? បានពិនិត្យមើល ឬក៏បានអានឡើងវិញទេ?

**ឆ៖** បាទ។

**ស៖** លោកបានអានទេ បានអាន ឬក៏បានពិនិត្យមើលកំណត់ហេតុនុ៎ងឡើងវិញទេ មុនពេលចូលមកផ្ដល់សក្ខីកម្មនាពេលនេះ?

**ឆ៖** កំណត់ហេតុហ្នឹង វាមិនដឹងជាកូនក្មេងយកទៅណា វាអត់ឃើញទាន រកវាអត់ឃើញ។

**ស៖** អ៊ីចឹងបានន័យថាលោកអត់បានអានទេ មែនទេ?

[០៩:១៥:00]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** កុំអាលទាន់ឆ្លើយលោក ឱ ហ្វ! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដោយឲ្យសញ្ញាភ្លើងក្រហម អាហ្នឹងសូមឆ្លើយ ទើបសំឡេងរបស់លោកហ្នឹង បានចែកចាយដល់អ្នកដែលចូលរួម និងរួមទាំងទាំងភាគី រួមទាំងសាធារណជនផងបានស្តាប់សំឡេងរបស់លោក។

**ឆ៖** ខ្ញុំភ្លេចហើយសំណួរដែលលោកសួរអំមិញ។

**ស៖** អ៊ីចឹងបានន័យថា លោកអត់បាននូវកំណត់ហេតុដែលលោកផ្តល់សក្ខីកម្មកាលពីពេលមុនចំពោះមុខ -- ចំពោះអ្នកស៊ើបអង្កេតពិតមែនដែរទេ?

**ឆ៖** ខ្ញុំអត់បានអានមែនទាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយ អង្គជំនុំជម្រះបានទទួលព័ត៌មានថា លោកមានបញ្ហាសុខភាពដែលនឹងអាចត្រូវទៅបន្ទប់ជាញឹកញាប់។ បើដូច្នេះមែនសូមលោកសាក្សីកុំខ្លាចក្រែងអី ក្នុងអំឡុងពេលសវនាការលោកអាចសុំទៅកាន់បន្ទប់ទឹកបានដោយគ្រប់ពេលវេលា គ្រាន់តែលោកលើកដៃជាសញ្ញាប្រាប់ដល់យើងទៅ យើងនឹងអនុញ្ញាតឲ្យលោកចាកចេញ ដើម្បីទៅបន្ទប់ទឹក នៅក្នុងអំឡុងពេលធ្វើសវនាការនេះ។

ក្នុងការសួរដេញដោលសាក្សីរូបនេះ អង្គ -- អនុវត្តតាមវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិការជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយបញ្ជាក់ថាសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលបីវគ្គ នៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក សេង លាង៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោក លោកស្រីចៅក្រម លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសវនាការនៅថ្ងៃនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិ។ ថ្ងៃ

នេះ ខ្ញុំមានសំណួរមួយចំនួន ចង់ឲ្យលោកសាក្សីជួយបំភ្លឺដល់អង្គសវនាការទាំងមូលទៅលើប្រធានបទមួយចំនួន ដូចជា ទី១) ប្រវត្តិមួយចំនួនរបស់លោកមុនឆ្នាំ ៧៥, ទី២) ការប្រព្រឹត្តទៅលើប្រជាជន១៧ មេសា, ទី៣) ការប្រព្រឹត្តចំពោះអតីតទាហាន និងមន្ត្រីរាជការលន់ នល់, ទី៤) ការប្រព្រឹត្តចំពោះព្រះពុទ្ធសាសនា ការប្រព្រឹត្តចំពោះជនជាតិចាម និងអាពាហ៍ពិពាហ៍ដោយបង្ខំ។

បន្ទាប់មកសហការីអន្តរជាតិរបស់ខ្ញុំ គឺលោក នីក នឹងមានសំណួរមួយចំនួន ពាក់ព័ន្ធជាមួយប្រធានបទ លក្ខខណ្ឌការងារ និងរចនាសម្ព័ន្ធចាត់តាំងការងារនៅទំនប់១មករា និងមន្ទីរសន្តិសុខ ហើយក៏ដូចជានឹងមានសំណួរមួយចំនួនទៀត ឲ្យលោកសាក្សីរជួបបំភ្លឺផងដែរ។

សំណួរដំបូងរបស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងប្រធានបទ នៃជីវប្រវត្តិរបស់លោកនៅមុនឆ្នាំ៧៥។ ហើយខ្ញុំចង់សួរថា តើលោករស់នៅឯណាមុនថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥?

[០៩:១៨:៤៨]

**លោក ឱ ហួះ**

**ឆ៖** មុនឆ្នាំ១៩៧៥ ខ្ញុំបាទនៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

**ស៖** អរគុណលោកសាក្សី។ តើលោកអាចប្រាប់បានទេថា តើពួកខ្មែរក្រហមចូលកាន់កាប់តំបន់របស់លោកនៅឆ្នាំណាដែរ?

**ឆ៖** ពួកខ្មែរក្រហមដែលចូលកាន់កាប់នៅកន្លែងខ្ញុំតាំងពីឆ្នាំ១៩៧០។

**ស៖** អរគុណលោកសាក្សី។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកមួយ ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5255 ត្រង់ ERN ជាភាសាខ្មែរ 00239906, ERN ជាភាសាអង់គ្លេស 00230043, ERN ជាភាសាបារាំង 00277224។ លោកបានឆ្លើយតបនឹងសំណួរថា "មុនឆ្នាំ៧៥ តើលោករស់នៅឯណា?" លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់ "នៅភូមិព្រៃស្រង៉ែ" និងឆ្លើយតបទៅនឹងសំណួរបន្ទាប់ទៀតថា "តើលោករស់នៅឯណាក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥ រហូតដល់ឆ្នាំ៧៩ និងលោកធ្វើអ្វី?" លោកបានឆ្លើយតបថា "ខ្ញុំរស់នៅភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំដដែល ហើយធ្វើជាប្រធានភូមិស្រង៉ែរហូតដល់ខែកក្កដា ឆ្នាំ៧៧។" តើលោកអាចបញ្ជាក់បានទេថា លោកចូលរួមជាមួយនឹងបដិវត្តន៍នៅឆ្នាំណា?

**ឆ៖** ខ្ញុំបាទធ្វើការងារបដិវត្តន៍តាំងពីឆ្នាំ១៩៧២ ដល់ ឆ្នាំ១៩៧៨។

**ស៖** នៅពេលដែលលោកចូលធ្វើការដំបូងនៅឆ្នាំ៧២នោះ តើលោកធ្វើអ្វីដែរ?

**ឆ៖** កាលឆ្នាំ១៩៧២ ខ្ញុំបាទធ្វើជាអនុភូមិព្រៃស្រង៉ែ។

[០៩:២២:១២]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការពិនិត្យមើលគាត់មើល ដូចគាត់ៗមើលអានក្រដាស អានឯកសារទេអី?

*(មន្ត្រីតុលាការទៅពិនិត្យមើលសាក្សី)*

លោក ឱ ហូ ចាំបានប៉ុន្មានឆ្លើយជូនតុលាការប៉ុណ្ណឹងទៅ កន្លែងណាមិនចាំឆ្លើយថាមិនចាំអីចឹងទៅ។ បាទ មិនបាច់ប្រើប្រាស់ឯកសារអ្វីទេ។ បាទ នេះជាការសួរដេញដោលផ្ទាល់មាត់។

បាទ សូមអញ្ជើញបន្តលោកតំណាងសហព្រះរាជអាជ្ញាជាតិ។

**លោក សេង លាង៖**

អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** តើលោកបានឡើងជាមេភូមិនៅឆ្នាំណាដែរ? លោកអាចប្រាប់បានទេ?

**លោក ឱ ហូ៖**

**ឆ៖** ខ្ញុំបាទធ្វើមេភូមិព្រៃស្រង៉ែពីឆ្នាំ១៩៧៥។

**ស៖** តើអ្នកណាគេជាអ្នកតែងតាំងលោកធ្វើជាមេភូមិ?

**ឆ៖** អ្នកតែងតាំងខ្ញុំបាទធ្វើជាមេភូមិ គឺលោក ប៊ិន, លោក វុត, លោក -- ខ្ញុំមិនចាំពីរនាក់ទៀត។

**ស៖** តើលោក ប៊ិន និងលោក វុត ហ្នឹងគឺជានរណា?

**ឆ៖** លោក ប៊ិន, លោក វុត នោះគឺជាមេឃុំ និងអនុឃុំ។

**ស៖** តើលោកនៅជាមេភូមិហ្នឹងរហូតដល់ឆ្នាំណាដែរ?

**ឆ៖** ខ្ញុំធ្វើមេភូមិពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ អង្គការរំសាយឲ្យឈប់ធ្វើការងារ។

[០៩:២៥:១៧]

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើឆ្នាំ៧៧ ឬក៏៧៨ ឲ្យប្រាកដ?

**ឆ៖** ខ្ញុំបាទឈប់ធ្វើការងារនៅឆ្នាំ១៩៧៨ ទាន។

**ស៖** នៅខែណាលោកអាចបញ្ជាក់បានដែរ?

**ឆ៖** នៅខែ៧ ទាន។

**ស៖** អ៊ីចឹងលោកចង់និយាយថា ខែ៧ ឆ្នាំ៧៨ មិនមែនខែ៧ ឆ្នាំ៧៧ ទេឬ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយ អំមិញអត់ទាន់ឆ្លើយទេ។ ឆ្លើយអំមិញអត់មានក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការទេ ស្មើមិនឆ្លើយ។

**លោក ឱ ហួ៖**

**ឆ៖** ខ្ញុំធ្វើការតាំងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៨ ខែ៥ -- អូ៎ ខែ៧ៗ ទាន។

**សួរដោយលោក សេង លាង៖**

**ស៖** តើលោកអាចប្រាប់បានទេ នៅក្រោយ -- មានអ្វីកើតឡើងនៅខែ៧ ឆ្នាំ៧៨ហ្នឹង ទើបលោកឈប់ធ្វើជាមេភូមិ?

**ឆ៖** ក្នុងសម័យនុ៎ង វាសម្លាប់កម្មាភិបាលច្រើនណាស់ទាន កម្មាភិបាលត្រូវស្លាប់ច្រើនណាស់។ ដូច្នេះ ក្នុងនាមខ្ញុំដែលជាប់អង្កេតពិនិត្យមើល។

**ស៖** អ៊ីចឹងដោយសារមូលហេតុមានការស្លាប់កម្មាភិបាលច្រើន ហើយលោកជាប់អង្កេត ទើបលោកឈប់ធ្វើមេភូមិ ឬក៏យ៉ាងម៉េច? លោកអាចបញ្ជាក់បានដែរ?

**ឆ៖** ដល់ពេលដែលខ្ញុំបាទ ដែលអង្គការរំសាយនោះ គឺដោយបញ្ហាដែលអង្គការមិនទុកចិត្តត្រង់រឿងថា កម្មាភិបាលដែលធ្វើការសុទ្ធតែក្បត់ទាំងអស់ទាន។

[០៩:២៨:១៩]

**ស៖** អរគុណ លោកសាក្សី។ សហសេវិកខ្ញុំនឹងមានសំណួរទៅលើបញ្ហានេះទៀត ប៉ុន្តែខ្ញុំនឹងសូមទៅសំណួរខាងមុខទៀត។ តើក្រោយឆ្នាំ -- ក្រោយថ្ងៃ -- ខែកក្កដា ឆ្នាំ៧៨ហ្នឹង លោកទៅនៅឯណា? ហើយធ្វើអ្វីដែរ?

**ឆ៖** ក្រោយឆ្នាំ -- ក្រោយខែ៧ ឆ្នាំ១៩៧៨ ខ្ញុំបាទ នៅភូមិព្រៃស្រង៉ែដដែលទាន។

**ស៖** ពេលនោះលោកធ្វើអ្វីដែរ?

**ឆ៖** គឺជាប្រជាជនសាមញ្ញធម្មតាទាន ធ្វើស្រែ ដកស្ទូងដូចគ្នាដូចឯង ដូចតែគ្នា។

**ស៖** តើលោកអាចជួយបញ្ជាក់បានដែរទេថា មេឃុំបល្ល័ង្គ និងគណៈស្រុក និងគណៈតំបន់

ឈ្មោះអីដែរ?

**ឆ៖** ក្រោយថ្ងៃ -- ក្រោយខែ៧មក ខ្ញុំបាទអត់ស្គាល់ទេមេឃុំបល្ល័ង្ក ព្រោះខ្ញុំបាទជាប្រជាជនសាមញ្ញ គេមិនឲ្យទៅប្រជុំនោះនឹងគេប្រចាំខែទេ ហើយចំពោះគណៈតំបន់នោះ ខ្ញុំស្គាល់តែគណៈតំបន់មុនៗ តែគាត់ស្លាប់អស់ហើយ។

[០៩:៣០:២១]

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា មេឃុំ គណៈស្រុក និងគណៈតំបន់ តាំងពីមុនដែលលោកទើបតែលោកឡើងធ្វើជាមេភូមិរហូតដល់ពេលឈប់ហ្នឹង ដែលលោកដឹងហ្នឹង តើគាត់មានឈ្មោះអីខ្លះ?

**ឆ៖** មេឃុំ គណៈកម្មការឃុំដែលខ្ញុំធ្វើការមក មានលោក ប៊ិន, លោក វុត, លោក លាក់, លោក ចាប, លោក ជិន, លោក ដុង។

**ស៖** ចុះចំណែកគណៈស្រុកវិញ លោក?

**ឆ៖** គណៈស្រុក គាត់មិនដឹងជាឈ្មោះអី ប៉ុន្តែគាត់ប្រើពាក្យថា “មូល” ឈ្មោះ មូល។

**ស៖** ចុះចំណែកភូមិភាគ គាត់ឈ្មោះអីដែរ? តំបន់ គណៈតំបន់ ហើយនិងគណៈភូមិភាគ លោកដឹងដែរទេ?

**ឆ៖** គណៈភូមិភាគ កាលហ្នឹងលោក ពក ហើយគណៈតំបន់ ខ្ញុំវង្វេងឈ្មោះហើយទាន។

**ស៖** លោកថា លោក ពក ហ្នឹង លោក កែ ពក ឬក៏យ៉ាងម៉េច?

**ឆ៖** កែ ពក។

**ស៖** អរគុណលោកសាក្សី។ តើជាលក្ខណៈបុគ្គល តើលោកមានស្គាល់លោក កែ ពក ដែរឬទេ?

**ឆ៖** លោក កែ ពក ខ្ញុំមិនបានស្គាល់ជិតស្និទ្ធលោកទេ គ្រាន់តែឃើញលោកជិះឡានកាត់ភូមិខ្ញុំ ហើយនិងទៅការដ្ឋាន មើលបានចម្ងាយប្រហែលជា៥០ម៉ែត្រ ៦០ម៉ែត្រប៉ុណ្ណឹងទេទាន។

[០៩:៣៣:០៣]

**ស៖** អរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំទៅមុខបន្តិចទៀត ទៅលើប្រធានបទមួយទៀត គឺប្រធានបទស្តីអំពីការប្រព្រឹត្តចំពោះប្រជាជនថ្មីវិញម្តង។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5255 ត្រង់ ERN ជាភាសាខ្មែរ 00239606 រហូតដល់ 07 និង ERN ជាភាសាអង់គ្លេស 00250043, ERN ជាភាសាបារាំង 00277225។ លោក

បានលើកឡើងថា ខ្ញុំសូមដកស្រង់ "ការជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ គឺជម្លៀសមកពីភ្នំពេញ។ អ្នកទាំងនោះគេហៅថា ពួក១៧មេសា ឬក៏ពួកថ្មី"។ សំណួរខ្ញុំចង់សួរថា តើនៅពេលណាដែលអ្នកទាំងនោះ បានមកដល់តំបន់របស់លោក?

**ឆ៖** អ្នក១៧មេសា ដែលបានមកដល់កន្លែងខ្ញុំនេះ នៅខែមេសា ប៉ុន្តែចុងខែបំផុត។ ខ្ញុំមិនចាំថ្ងៃទេ។

**ស៖** តើពួកថ្មីទាំងនោះ មានប៉ុន្មានគ្រួសារដែរ ដែលគេត្រូវបញ្ជូនមកភូមិឃុំរបស់លោកហ្នឹង?

**ឆ៖** អ្នកប្រជាជន១៧មេសា មានច្រើនណាស់ទាន មានដល់ទៅ៣០០គ្រួសារណោះ តែភូមិខ្ញុំនេះទទួល ១០០គ្រួសារទាន។

**ស៖** អរគុណលោកសាក្សី។ តើលោកដឹងទេថា ប្រជាជននៅក្នុងភូមិរបស់លោកត្រូវបានគេបែងចែកជាក្រុមដោយផ្អែកលើថា តើពួកគាត់ជាប្រជាជនមូលដ្ឋាន ឬក៏ប្រជាជនថ្មី ឬក៏ប្រជាជន១៧មេសា?

**ឆ៖** ចែកគ្នាអ៊ីចឹងមែនទាន ប៉ុន្តែចំពោះអ្នកស្រុក អ្នកភូមិមិនបានដាក់គាត់ជាប្រជាជនថ្មីទេ គឺធ្វើការដូចគ្នាចាស់និងថ្មី ធ្វើដូចតែគ្នា ធ្វើស្រែ ធ្វើប្រឡាយដូចគ្នា។

[០៩:៣៦:២៦]

**ស៖** សូមលោកជួយបញ្ជាក់មើលថា តើមានប្រជាជនប៉ុន្មានក្រុមដែលត្រូវគេបែងចែក មានក្រុមអីខ្លះ?

**ឆ៖** ខ្ញុំមើលដែល ១) ប្រជាជនពេញសិទ្ធិ, ២) ប្រជាជនត្រៀម, ៣) ប្រជាជនបញ្ញើ។

**ស៖** តើលោកអាចប្រាប់បានទេថា ក្នុងក្រុមនីមួយៗហ្នឹងខុសគ្នាយ៉ាងដូចម្តេចដែរ?

**ឆ៖** ចំពោះភូមិដទៃទៀត ខ្ញុំបាទមិនដឹងទេទាន បើនៅក្នុងព្រៃស្រង៉ែនេះអត់មានខុសគ្នាទេទាន ដូចគ្នា ដូចខ្ញុំបាទជម្រាបអ៊ីចឹង គឺធ្វើការសស្រាក់សស្រាំដូចតែគ្នា។

**ស៖** បើដូច្នេះហេតុអ្វីបានចាំបាច់ត្រូវធ្វើការបែងចែកជាក្រុមរហូតដល់បីក្រុម?

**ឆ៖** ខ្ញុំបាទមិនដឹងទេទាន អានេះជារឿងថ្នាក់លើ។

**ស៖** តើលោកដឹងទេថា អ្នកណាគេជាអ្នកប្រាប់លោកថា ត្រូវឱ្យបែងចែកប្រជាជនជាក្រុមយ៉ាងដូច្នេះ?

**ឆ៖** ពេលដែលគេហៅទៅប្រជុំនៅសង្កាត់ម្តងៗ គេប្រាប់អ៊ីចឹងតែម្តង។

**សៈ** សង្កាត់ដែលលោកនិយាយនៅពេលនេះ គឺជាឃុំ ឬយ៉ាងណា?

**ធៈ** សង្កាត់ដែលខ្ញុំធ្លាប់មាត់ហៅសង្កាត់ហ្នឹង គឺឃុំនុំងឯងទាន។

[០៩:៣៩:២០]

**សៈ** អរគុណលោកសាក្សី។ តើលោកអាចប្រាប់បានទេថា តើក្រុមគ្រួសាររបស់លោកស្ថិតនៅក្នុងក្រុមណាមួយក្នុងចំណោមក្រុមទាំងបីហ្នឹង?

**ធៈ** ក្រុមគ្រួសាររបស់ខ្ញុំស្ថិតនៅក្នុងប្រជាជនត្រៀម។

**សៈ** តើលោកអាចប្រាប់បានទេថា តើរវាងប្រជាជនទាំងបីក្រុមហ្នឹង ត្រូវបានទទួលការយកចិត្តទុកដាក់ដូចគ្នា ឬក៏ខុសគ្នាយ៉ាងណាដែរ?

**ធៈ** ប្រជាជនទាំងបីក្រុមនេះ នៅភូមិខ្ញុំ ដែលខ្ញុំមិនដឹងទេនៅភូមិដទៃ តែបើភូមិខ្ញុំ វាដូចតែគ្នាហ្នឹងទាន យកចិត្តស្មើគ្នា។

**សៈ** តើលោកអាចប្រាប់បានទេថា តើប្រជាជនថ្មីរស់នៅនិងហូបចុកដូចគ្នា នៅកន្លែងតែមួយជាមួយប្រជាជនមូលដ្ឋាន ឬយ៉ាងណា?

**ធៈ** កាលនោះយើងស៊ីរួម ហូបរួមៗទាំងអស់គ្នា។

**សៈ** ចុះចំណែកចំណីអាហារដែលគេផ្តល់ឲ្យរវាងអ្នកមូល -- អ្នកប្រជាជនចាស់ និងប្រជាជនត្រៀម និងប្រជាជនថ្មី តើដូចគ្នាដែរឬទេ? ឬក៏ខុសគ្នា?

**ធៈ** ការវាល់របបៗបបរ វាល់ចែកគ្នាដូចតែគ្នាហ្នឹងទាន។ បើវាបានពីរវែកៗដូចគ្នា មួយវែកៗដូចគ្នា។

**សៈ** តើលោកមានដឹងទេថា តើប្រជាជននៅក្នុងភូមិរបស់លោកមានអ្នកណាស្លាប់ដោយសារការអត់អាហារដែរឬទេ?

[០៩:៤២:២៨]

**ធៈ** នែ៎ ទេ ព្រោះវា ប្រជាជននៅភូមិខ្ញុំអ្នកអត់អាហារស្លាប់ គ្មានទេទាន ពីព្រោះអ្នកទាំងអស់នោះវាដូចតែគ្នា ហូបចុកដូចតែគ្នា ហើយក៏មកពីធ្វើការ ចូលតាមប្រឡាយទៅចាប់ត្រី ចាប់អីស៊ីខ្លះទៅហូបខ្លះទៅ។

**សៈ** អរគុណលោកសាក្សី។ រវាងប្រជាជនថ្មី និងប្រជាជនចាស់ នៅពេលដែលបានប្រព្រឹត្តកំហុស ឬក៏ប្រព្រឹត្តបទល្មើសអីតិចតួច តើត្រូវទទួលរងទណ្ឌកម្មដូចគ្នា ឬក៏ខុសគ្នាយ៉ាងណាដែរ?

**ឆ៖** នែ៎ ប្រជាជនចាស់ និងប្រជាជនថ្មីហ្នឹង កាលណាវាមានកំហុសទៅ អប់រំដូចតែគ្នា ស្ដីបន្ទោសដូចតែគ្នា។

**ស៖** បាទ នៅក្នុងកិច្ចសម្ភាសន៍របស់លោកមួយ ជាមួយនឹងការិយាល័យសហចៅក្រមស៊ើប គឺឯកសារ E3/5255 ត្រង់ ERN ជាភាសាខ្មែរ 00239911, ERN ជាភាសាអង់គ្លេស 00250047, ERN ជាភាសាបារាំង 00277229 រហូតដល់30។ ឆ្លើយទៅនឹងសំណួរថា "តើក្រុមប្រជាជនប្រភេទណា ដែលត្រូវចាប់ខ្លួននិងធ្វើបុក -- ធ្វើទុក្ខបុកម្នេញជាងគេ?" លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ "ប្រជាជនបញ្ញើ គឺងាយនឹងគេចាប់កំហុសយកទោសជាងប្រជាជនផ្សេងទៀត"។ តើលោកឆ្លើយតបយ៉ាងណាចំពោះអ្វីដែលបាន -- លោកបានលើកឡើងនេះ? សូមជួយពន្យល់ប្រាប់អង្គសវនាការផង។

[០៩:៤៥:១២]

**ឆ៖** ប្រជាជន១៧មេសា តែកាលណាប្រព្រឹត្តខុសហើយ ខុសតិចតួច មេភូមិដាស់តឿនថាជេរស្ដីទៅ តែបើខុសខ្លាំង មេភូមិជេរស្ដីមិនកើតទេទាន។ មិនអាចនឹងធានាបាន ព្រោះកំហុសដែលធ្វើទៅវាខុសធ្ងន់ទៅនោះ ក៏ប៉ុន្តែនៅក្នុងភូមិរបស់ខ្ញុំនេះ វាគ្មានប្រភេទបែបហ្នឹងទេ។

**ស៖** ខ្ញុំដូចជាមិនសូវយល់នូវអ្វីដែលលោកពន្យល់ ប៉ុន្តែខ្ញុំចង់បញ្ជាក់បន្តិចថានៅក្នុងកំណត់ហេតុដែលខ្ញុំបានអានអម្បាញ់មិញ។ ខ្ញុំសូមដកស្រង់ម្ដងទៀត គឺលោកឆ្លើយថា "ប្រជាជនបញ្ញើ គឺងាយនឹងគេចាប់កំហុសយកទោសជាងប្រជាជនផ្សេងទៀត"។ តើជាការពិតដែរឬទេ អ្វីដែលលោកលើកឡើង?

**ឆ៖** ប្រជាជនបញ្ញើកាលណាខុសនៅកន្លែងក្រៅពីភូមិ ទៅធ្វើការងារផ្សេងៗនៅក្រៅពីភូមិ ក្រៅពីកន្លែងរស់នៅ ពិបាកណាស់ ពិបាកនឹងគេចាប់កំហុស។

**ស៖** ខ្ញុំចង់ គ្រាន់តែចង់ឲ្យលោកបញ្ជាក់អំពីអ្វីដែលលោកលើកឡើងនេះថា ប្រជាជនបញ្ញើ គឺងាយនឹងចាប់កំហុសយកទោសជាងប្រជាជនផ្សេងទៀត។ តើជាការពិតដែរឬទេ? សូមឆ្លើយ។

**ឆ៖** ពិតណាស់ទានរឿងហ្នឹង។

**ស៖** អរគុណៗលោកសាក្សី។ តើលោកដឹងទេ ហេតុអ្វីបានជាប្រជាជនបញ្ញើហ្នឹងគឺជាគោលដៅនៃការចាប់កំហុស និងធ្វើទុក្ខបុកម្នេញយ៉ាងដូច្នេះ?

**ឆ៖** ខ្ញុំបាទមិនសូវច្បាស់ទេ ត្រង់ហ្នឹង។ ការងារហ្នឹងខ្ញុំបាទមិនសូវច្បាស់ទេ។

**ស៖** តើលោកដឹងរឿងដែលប្រជាជនបញ្ញើងាយនឹងចាប់កំហុសជាងប្រជាជនផ្សេងទៀតហ្នឹងតាមរបៀបណាដែរ?

**ឆ៖** តាមរបៀបគាត់មានពួកម៉ាកគាត់ណ៎ា មានពួកម៉ាកគាត់នៅភូមិក្រៅៗអ៊ីចឹង គាត់និយាយការងារអាថ៌កំបាំងទាំងឡាយរបស់គាត់ប្រាប់គេទាន។

**ស៖** តាមបទពិសោធន៍របស់លោក តើលោកដឹងថាមានការឃាត់ខ្លួន ការសម្លាប់ ឬក៏ការបាត់ខ្លួនដោយបង្ខំរបស់ប្រជាជន១៧មេសា ក្នុងរបបខ្មែរក្រហម ក្នុងភូមិរបស់លោកហ្នឹង កើតមានញឹកញាប់ដែរឬទេ?

**ឆ៖** មិនសូវមានទេទាន មិនសូវមានទេ។ វាមានតែដឹកឡានតែម្តងហ្នឹង។

[០៩:៤៩:៤៤]

**ស៖** អរគុណលោកសាក្សី។ ឥឡូវខ្ញុំដោយសារពេលវេលា ខ្ញុំទៅមុខកាន់ប្រធានបទថ្មីមួយទៀតស្តីអំពីការប្រព្រឹត្តទៅលើអតីតមន្ត្រី និងទាហាន លន់ នល់។ សំណួរខ្ញុំចង់សួរថា តើលោកអាចពន្យល់បានទេ នូវអ្វីដែលបានកើតឡើងចំពោះប្រជាជននៅក្នុងស្រុកបារាយណ៍របស់លោកទាំងមូលហ្នឹង នៅពេលដែលត្រូវបានគេកំណត់អត្តសញ្ញាណថាគាត់គឺជាអតីតទាហាន ឬក៏ជាអតីតមន្ត្រីរាជការរបបមុន? តើមានអ្វីកើតឡើងចំពោះគាត់?

**ឆ៖** សូមថាម្តងទៀតទាន។

**ស៖** ខ្ញុំចង់ឱ្យលោកជួយពន្យល់ថា ប្រជាជននៅក្នុងស្រុកបារាយណ៍របស់លោកហ្នឹង ទាំងមូលហ្នឹង នៅពេលដែលត្រូវបានគេកំណត់អត្តសញ្ញាណគាត់ថា គាត់ជាអតីតទាហាន ឬក៏មន្ត្រីរបប លន់ នល់ តើមានអ្វីកើតឡើងចំពោះគាត់ដែរ?

**ឆ៖** បើគាត់ទម្លាយខ្លួនគាត់ឱ្យគេដឹងហើយ អាហ្នឹងវា គេៗដឹងហើយ បើគាត់ប្រាប់គេខ្លួនឯងហើយ។

**ស៖** ចុះបន្ទាប់ពីគេដឹងហើយ តើមានអ្វីកើតឡើងចំពោះគាត់ដែរឬទេ?

**ឆ៖** តាមខ្ញុំធ្លាប់ឃើញមក កាលណាគេដឹងហើយ ខ្ញុំក្តី អ្នកស្រុកក្តី ដែលធ្លាប់ស្រឡាញ់ ធ្លាប់រាប់អាន ស្តាយ ប៉ុន្តែមិនដឹងជួយម៉េចទៀតទេ។ អាហ្នឹងវា តែកាលណាដឹងទៅ វាដឹងទៅដល់សន្តិសុខគេ គេមកចាប់ខ្លួនគេទៅ។

[០៩:៥២:៣៥]

**ស៖** តើគេចាប់យកទៅណាដែរ?

**ឆ៖** គេចាប់យកទៅដាក់សន្តិសុខហ្នឹងទាន គេដាក់សន្តិសុខរបស់គេ។

**ស៖** ឥឡូវខ្ញុំទៅកាន់សំណួរមួយទៀត ថានៅពេលដែលប្រជាជនថ្មីៗ ប្រជាជន១៧មេសា ដែលមកដល់ភូមិរបស់លោកហ្នឹង នៅចុងខែមេសា ដែលលោកនិយាយហ្នឹង។ តើពេលដែលគាត់មកដល់ហ្នឹង ពួកខ្មែរក្រហមមានព្យាយាមកំណត់អត្តសញ្ញាណគាត់ទេ? ថាតើក្នុងចំណោមប្រជាជនថ្មីហ្នឹងមានអ្នកណាខ្លះជាអតីតទាហាន អ្នកណាខ្លះជាអតីតមន្ត្រីរាជការរបប លន់ នល់ ដែរឬទេ?

**ឆ៖** កាលណាមកដល់កន្លែងដែលចែកប្រជាជនហ្នឹង គេហៅវត្តព្រៃតាត្រាវហ្នឹង គឺគេធ្វើស្ថិតិម៉្យាង គេធ្វើស្ថិតិ ហើយបានគេហៅមេភូមិមកទៅយក។ ទៅយកតាមគេចែកកំណត់ឲ្យទៅ ភូមិណាត្រូវបានប៉ុន្មានៗ។

[០៩:៥៥:២៤]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកមួយគឺឯកសារ E3/5255ដដែល។ ERN ជាភាសាខ្មែរ 00239907, ERN ជាភាសាអង់គ្លេស 00250044, ERN ជាភាសាបារាំង 00277225។ លោកបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ “នៅពេលគេជម្លៀសប្រជាជនថ្មីចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ គេមានបញ្ជីឈ្មោះបញ្ជូនមកខ្ញុំ ប៉ុន្តែក្រោយមកក្នុងឆ្នាំ៧៧ គេធ្វើបញ្ជីឈ្មោះមួយទៀត រួចបញ្ជូនមកខ្ញុំ ប្រាប់ថាឲ្យខ្ញុំត្រៀមអ្នកទាំងនោះដើម្បី ឡើងឡានទៅរស់នៅក្នុងភូមិថ្មី”។ សំណួរចង់សួរថាៗ សូមលោកជួយពន្យល់ថា តើបញ្ជីឈ្មោះនៅថ្ងៃទី១៧ មេសានោះ គេរៀបចំយ៉ាងដូចម្ដេច?

**ឆ៖** បញ្ជីឈ្មោះនោះ ខ្ញុំមិនដឹងទេ ព្រោះនៅឯសង្កាត់នោះទេទាន។ ខ្ញុំបានទទួលតែបញ្ជីឈ្មោះដែលគេធ្វើឲ្យទៅនៅភូមិថ្មី។

**ស៖** ចុះចំណែកបញ្ជីឆ្នាំ៧៧វិញនោះ តើយ៉ាងម៉េចដែរ អ្នកណាជាអ្នករៀបចំ ហើយអ្នកណាជាអ្នកប្រគល់ឲ្យលោក?

**ឆ៖** មិនៗដឹងមកពីត្រឹមណាទេ ប៉ុន្តែបញ្ជីហ្នឹង វាចេញមកតាមរយៈមេឃុំ។

**ស៖** លោកអាចប្រាប់បានទេ ថាតើអ្នកណាគេជាអ្នកចុះហត្ថលេខានៅលើបញ្ជីឈ្មោះហ្នឹង?

**ឆ៖** តាមបញ្ជីឈ្មោះហ្នឹង ហត្ថលេខានៃឈ្មោះនោះ មានឈ្មោះដែលមិត្ត -- សមមិត្តចាប។

**ស៖** នៅពេលហ្នឹង ចាប ហ្នឹង គាត់ជាមេឃុំឬយ៉ាងម៉េច?

**ឆ៖** ចាប ហ្នឹងជាមេឃុំទាន – ចាប។

[០៩:៥៧:៤៧]

**ស៖** អរគុណលោកសាក្សីជួយបំភ្លឺ។ ឥឡូវខ្ញុំទៅកាន់មួយសំណួរទៀត នៅក្នុងឯកសារសម្ភាស

របស់លោកដដែល គឺឯកសារ E3/5255/ -- 535255, ERN ជាភាសាខ្មែរ 00239907, ERN ជាភាសាអង់គ្លេស 00250044, ERN ជាភាសាបារាំង 00277225។ លោកបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ "មានការសម្លាប់ប្រជាជន១៧មេសា ដោយសារព័ត៌មានចេញពីពួកខ្លួន។ ពេលនោះពួកខ្មែរក្រហមបានដើរតួនាទី -- ដើរតួជាអ្នក១៧មេសា ដើម្បីសួររកអ្នកដែលធ្លាប់ធ្វើការក្នុងសម័យមុន។ ម្យ៉ាងទៀត ពួកខ្មែរក្រហមបានឲ្យខោអាវខ្មៅមួយកំប្លេ និងក្រមាក្រហមមួយដល់យុវជនម្នាក់ឈ្មោះ កៅ ជាអតីតគ្រូបង្រៀនជំនាន់ លន់ នល់ (បានស្លាប់ហើយ) តែជាអ្នក១៧មេសា ដើម្បីបំពាក់បំប៉នសតិ-អារម្មណ៍ គោលជំហរ ឲ្យរាយការណ៍អំពីសមាសភាព ឬបណ្ដាស័ក្តិដែលអ្នកទាំងនោះ ធ្លាប់បម្រើការក្នុងរបបមុន"។ តើលោកអាចៗពន្យល់នូវអ្វីដែលបាន -- លោកបានលើកឡើងនេះជូនអង្គសវនាការផងបានឬទេ?

**ឆ៖** តាមខ្ញុំបាទចាំមក កាលណោះពួកសន្តិសុខ គេយកអាវពណ៌ល្អ ដែលពណ៌អ្នកភ្នំពេញពាក់ គេពាក់ទៅ គេដើរសួររកថា គេបាត់ប្រពន្ធ ហើយគេជាអ្នក១៧មេសា គេពាក់ស័ក្តិ៣ អង្គការទទួលស្គាល់គេណាស់ បងប្អូនណាដែលមានបណ្ដាស័ក្តិប្រាប់ខ្ញុំ។ តែខ្ញុំអត់បានឮផ្ទាល់ទេណាទាន ឮគេនិយាយប្រាប់ទេ ឮអ្នកស្រុកគេនិយាយប្រាប់។ ពេលនោះខ្ញុំបាទប្រាប់ប្រជាជនខ្ញុំថា បើឃើញរបៀបហ្នឹង ពួកឯងទាំងអស់គ្នា កុំនិយាយអាចីកំបាំងខ្លួនឯងប្រាប់គេឲ្យសោះ។ ហើយចំពោះ មិត្តកៅ យុវជន កៅ ហ្នឹង គាត់ធ្វើនៅ -- ធ្វើគ្រូបង្រៀនកាលសម័យ លន់ នល់ មែន។ ពេលនោះ មិត្តចាប គាត់ឲ្យក្រមា ហើយនិងខោអាវថ្មីមួយកំប្លេ ក្រមាមួយ កង់មួយ ហើយបំពាក់បំប៉នអារម្មណ៍ឲ្យដើរស៊ើបសួរ រកអ្នកណាដែលមានបណ្ដាស័ក្តិ សូម្បីតែអ្នកចេះត្រឹមតែថ្នាក់បរិញ្ញាក៏ប្រាប់ដែរទាន សម្លាប់អស់។ នេះអ្នកចេះមួយសម័យនោះ តែមិនដឹងគាត់យ៉ាងម៉េចទេ ខ្ញុំដឹងដោយសារមេឃុំហ្នឹង គេហៅខ្ញុំទៅស្ដីឲ្យ។ គេថា ខ្ញុំស៊ុមគ្រលុំនឹងខ្លាំង។

[១០:០២:១៧]

**ស៖** ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ប្រាប់ថា តើនៅពេលដែលប្រជាជនថ្មីនោះ ឆ្លោយមាត់ប្រាប់មនុស្សដែលដើរតួនាទីជាអ្នក១៧មេសាក្តី ឬក៏ឆ្លោយមាត់ប្រាប់ កៅ ក្តីហើយត្រូវបានគេរាយការណ៍ទៅថ្នាក់លើនោះ តើមានអ្វីកើតឡើងចំពោះពួកគាត់ហ្នឹង?

**ឆ៖** ទានហើយបើគ្នាភ្លាត់មាត់អីចឹង មិនអាចនឹងជួយបានទេទាន។ គ្នាត្រូវស្លាប់ហើយ។

**ស៖** អរគុណលោកសាក្សី។ ឥឡូវខ្ញុំទៅកាន់មួយសំណួរទៀត ដោយសារពេលវេលាកាន់តែ

ខើចហើយ។ នៅក្នុងឯកសារដដែល និងERNដដែល នៅប្រយោគបន្ទាប់ លោកបាននិយាយថា ខ្ញុំសូមដកស្រង់៖ “នៅក្នុងភូមិរបស់ខ្ញុំមានបញ្ជីឈ្មោះ១៥គ្រួសារ ដែលថ្នាក់លើចុចឈ្មោះ ក្នុងបញ្ជីឈ្មោះដែលខ្ញុំបានជួយលាក់ហ្នឹងមានប្រាំបីគ្រួសារ ចំណែកប្រាំពីរគ្រួសារទៀតត្រូវគេយកឡានដឹក ដោយប្រាប់ថាឲ្យទៅនៅភូមិថ្មី។ ខ្ញុំគិតថា ភូមិថ្មីនោះជាកន្លែងសម្លាប់ ព្រោះខ្ញុំមិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញសោះ”។ លោកអាចជួយប្រាប់បន្តិចបានទេ ហេតុអ្វីក៏លោកជួយលាក់គ្រួសារប្រាំបីហ្នឹង?

**ឆ៖** គ្រួសារប្រាំបីហ្នឹង មិនមែនពិសេសជាងគេទេទាន ក៏ប៉ុន្តែវាស្រណុកលាក់។ ស្រណុកលាក់ត្រង់ថា គាត់ក៏មិនសូវមាត់រអិល ហើយគាត់ក៏មិនសូវខ្វល់នឹងអាគេសួរ គេនាំឲ្យនិយាយប៉ប៉ាច់ប៉ប៉ោច។ ប៉ុណ្ណឹងឯង។

**ស៖** លោក នៅការដកស្រង់ចុងក្រោយអម្បាញ់មិញ លោកនិយាយថា៖ “ខ្ញុំគិតថា ភូមិថ្មីនេះជាកន្លែងសម្លាប់ ព្រោះខ្ញុំមិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញសោះ។” សំណួរខ្ញុំចង់សួរថា ក្រៅពីព័ត៌មាន តើវាមានព័ត៌មានអ្វីផ្សេងទៀតដែរឬទេដែលនាំឲ្យលោកសន្និដ្ឋានថា មនុស្សទាំងអស់នេះត្រូវគេយកទៅសម្លាប់?

[១០:០៥:១៣]

**ឆ៖** បានជាខ្ញុំសន្និដ្ឋានថាអីចឹង ពីព្រោះកាលនោះវាខ្វះខោអាវស្លៀកពាក់ណាស់ទាន។ តែកាលណានេះ គេដឹកខោអាវហ្នឹងមកឲ្យមកវិញ ហើយខ្ញុំក៏សន្និដ្ឋានអីចឹងទៅ។

**ស៖** ដោយសារបញ្ហាពេលវេលា ខ្ញុំសូមទៅមុខទៀត ទៅដល់ប្រធានបទថ្មីមួយទៀតគឺនិយាយអំពីការប្រព្រឹត្តចំពោះជនជាតិចាមវិញម្តង។ នៅក្នុងកិច្ចសម្ភាសន៍មួយរបស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/5255 ត្រង់ ERN ជាភាសាខ្មែរ 00239911, ERN ជាភាសាអង់គ្លេស 00250047, ERN ជាភាសាបារាំង 00277229។ ឆ្លើយទៅនឹងសំណួរថា “តើប្រជាជនចាមដែលរស់នៅក្នុងភូមិរបស់លោកមានការចាប់ខ្លួនដែរឬទេ?” លោកឆ្លើយតបថា ខ្ញុំសូមដកស្រង់ “ជនជាតិចាមត្រូវបានចាត់ទុកថា ជាប្រជាជននៅក្រោមប្រជាជន១៧មេសាទៅទៀត។ ជនជាតិចាមត្រូវបង្ខំឲ្យហូបសាច់ជ្រូក។ សាសនាត្រូវបិទចោល មិនគោរព មិនឲ្យគោរពព្រះអ្វីទេ”។ សំណួរចង់សួរថា តើមានអ្វីកើតឡើងចំពោះព្រះវិហារ និងជនជាតិចាមដែលរស់នៅក្នុងភូមិឃុំរបស់លោកនោះ?

**ឆ៖** ចាម កាលនោះគាត់ (សុំទោស) ផឹកទឹក។ ចាមកាលនោះ ដែលនៅនឹងភូមិខ្ញុំហ្នឹង អីចឹងមែនទាន។ វាតឹងតែងមែន តែគ្រប់ភូមិ ចំពោះភូមិរបស់ខ្ញុំមិនបានធ្វើបាបគេទេ។ ព្រោះគាត់ថា សត្វទាំង

ឡាយ ដូចជាគោ ដូចអីដែលត្រូវការហូប បើគាត់មិនបានធ្វើ គឺគាត់មិនហូប។ ខ្ញុំថា ឃើញគាត់ចាស់មិនឲ្យគាត់ធ្វើ។

**ស៖** ខ្ញុំទៅកាន់មួយសំណួរទៀត គឺនៅក្នុងឯកសារ E3/5255 និង ERNដដែល ឆ្លើយទៅនឹងសំណួរបន្ទាប់ទៀត សួរថា៖ "តើមានលោកមានដឹងអំពីគោលនយោបាយលុបបំបាត់ជនជាតិចាមដែរឬទេ?" លោកឆ្លើយថា ខ្ញុំសូមដកស្រង់៖ "ខ្ញុំមិនដឹងដែរ ខ្ញុំគ្រាន់តែដឹងថា គេចង់ឲ្យមានតែជនជាតិខ្មែរមួយប៉ុណ្ណោះ"។ តើលោកដឹងរឿងនេះតាមរបៀបណាដែរ?

**ឆ៖** ខ្ញុំមិនដឹងតាមរបៀបណាទេ។ កាលនោះខ្ញុំនិយាយដោយឃើញការនេះ ក៏ប្រាប់គាត់ថា គេចង់ទុកតែខ្មែរ ក៏ប៉ុន្តែវាមិនបានដូចបំណងទេទាន គឺនៅដដែលដូចគ្នាហ្នឹង។

[១០:០៩:៣៣]

**លោក សេង លាង៖**

អរគុណលោកប្រធាន ខ្ញុំនៅមានប្រធានបទមួយចំនួនទៀត ប៉ុន្តែដោយសារបញ្ហាពេលវេលា ហើយសហការីខ្ញុំក៏មានសំណួរច្រើនដែរ ខ្ញុំចង់ទុកពេលវេលានេះ ជូនសហការីខ្ញុំ ដើម្បីសួរសំណួរបន្ត។ សូមអរគុណ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណលោកដែលបានអញ្ជើញមកទីនេះ ហើយបានពន្យល់ប្រាប់យើងអំពីការរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាក់ទងទៅនឹងខ្លួនលោកនិងអ្នកដទៃទៀត។ ឥឡូវនេះ ខ្ញុំចង់សាកសួរបន្តិចអំពីប្រវត្តិរបស់លោក។ តើលោករៀនសូត្រដល់កម្រិតណាដែរ?

**លោក ឱ ហួ៖**

**ឆ៖** លោកប្រុស ខ្ញុំមិនបានរៀនសាលាទេ ខ្ញុំបានបួសរៀនចំនួន១០ឆ្នាំដែរទ បួសរៀន១០ឆ្នាំដែរ។

**ស៖** នៅពេលខ្មែរក្រហមគ្រប់គ្រងតំបន់ដែលលោករស់នៅ តើពេលនោះលោកនៅជាព្រះសង្ឃនៅឡើយឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំបាទសឹកមកហើយទាន។ សឹកមកជាគ្រហស្ថហើយ។

**ស៖** ដូច្នេះ នៅក្នុងឆ្នាំ៧០ នៅពេលដែលខ្មែរក្រហមមកកាន់កាប់តំបន់របស់លោក តើលោកមានតួនាទីការងារជាអ្វីដែរ?

[១០:១១:១៧]

**ឆ៖** នៅឆ្នាំ១៩៧២ទាន ៧២ មុន ៧៥ ខ្ញុំអនុប្រធានភូមិ។ ដល់មកត្រឹមឆ្នាំ៧៥នេះឯង ខ្ញុំមេភូមិ។ ដល់មក៧៨ ខ្ញុំអង្គការរំសាយទាន។

**ស៖** សូមអរគុណ។ លោកនិយាយថា លោកមុនពេលដែលលោកធ្វើជាអនុប្រធានភូមិហ្នឹង តើលោកជាកសិករ ឬក៏លោកមានតួនាទីអ្វីដែរ?

**ឆ៖** កាលខ្ញុំធ្វើអនុប្រធានភូមិហ្នឹង ខ្ញុំបាទជាកសិករទេទាន។

**ស៖** នៅពេលដែលលោកក្លាយជាអនុប្រធានភូមិ ហើយបន្ទាប់មកជាប្រធានភូមិ តើលោកធ្លាប់ក្លាយជាសមាជិកបក្សដែរឬទេ?

**ឆ៖** ខ្ញុំមិនបានជាសមាជិកបក្សទេ គ្រាន់តែជាជនបង្គោលរបស់បក្ស។

**ស៖** លោកអាចពន្យល់បានបន្តិចទេ លោកនិយាយអំមិញហ្នឹងចង់មានន័យយ៉ាងម៉េចដែរ ខ្ញុំអត់យល់?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗឆ្លើយ។

[១០:១៣:០៨]

**លោក ឱ ហួ៖**

**ឆ៖** ជនបង្គោលរបស់បក្សហ្នឹង គឺជនដែលចម្រើន ដែលការងារឲ្យធ្វើឲ្យទៅបាន ដឹកនាំកម្លាំងទៅត្រង់ណាក៏បាន ធ្វើការកើត។ អាហ្នឹងគេហៅជនចម្រើនគេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ក្នុងពេលដែលលោកធ្វើជាមេភូមិក្នុងឆ្នាំ៧៥ ដល់ ៧៨ តើលោកទទួលបានការណែនាំអំពីការបំពេញការងារហ្នឹងដោយរបៀបណា? ពីអ្នកណាដែរ?

**ឆ៖** កាលដែលធ្វើការងារពីឆ្នាំ៧៥នោះ ទទួលការងារពីមេឃុំទៅទាន។

**ស៖** លោកនិយាយថាបានចូលរួមកិច្ចប្រជុំឃុំ ថាតើកិច្ចប្រជុំឃុំហ្នឹងគេធ្វើឡើងជាញឹកញាប់ ឬក៏ថាធ្វើ -- គេធ្វើ១ខែម្តង ១អាទិត្យម្តង ឬក៏១ឆ្នាំម្តង? តើលោកអាចប្រាប់ខ្ញុំបានទេ?

**ឆ៖** ជួនកាល១ខែប្រជុំម្តង ជួនកាលកន្លះខែប្រជុំម្តង មិនមានទៀងទេទាន។

**ស៖** ក្រៅពីសមាជិកគណៈកម្មការឃុំ តើមានអ្នកណាមកពីថ្នាក់លើចូលរួមក្នុងកិច្ចប្រជុំហ្នឹង

ដែរឬទេ?

[១០:១៥:០៨]

**ផ៖** ការប្រជុំហ្នឹង ជួនកាលមានថ្នាក់លើដែរទាន មកពីតំបន់ ឬក៏មកពីស្រុកមកទាន។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ លោករស់នៅក្នុងស្រុកបារាយណ៍ តើស្រុកបារាយណ៍ហ្នឹងមានលេខអីដែរឬទេ?

**ផ៖** ទាន ខ្ញុំអត់ដឹងទេ។

**ស៖** ចុះតំបន់វិញ តំបន់មានលេខប៉ុន្មានដែរ?

**ផ៖** តំបន់អង្កាល់ហ្នឹងមួយភូមិភាគកណ្តាលហ្នឹងគេចែកតំបន់ជាបី។ ហ្នឹងតាមគេប្រាប់ថាតំបន់ ៤១, ៤២, និង ៤៣។

**ស៖** តើភូមិរបស់លោកហ្នឹងនៅក្នុងតំបន់ទីប៉ុន្មានដែរ?

**ផ៖** នៅក្នុងតំបន់៤២ទាន។

**ស៖** លោកបាននិយាយថាលោកគឺជាសមាជិកស្នូល ជាជនបង្គោលរបស់បក្ស។ ហើយលោកក៏បាននិយាយថា លោកជាសមាជិកត្រៀម មិនមែនជាសមាជិកពេញសិទ្ធិទេ។ គ្រួសាររបស់លោកគឺជាសមាជិកត្រៀម មិនមែនជាសមាជិកពេញសិទ្ធិ។ ប៉ុន្តែលោកបានអាចពន្យល់បានទេ ហេតុអីបានជាគ្រួសាររបស់លោកបានឋានៈត្រឹមតែជាសមាជិកត្រៀម មិនបានឋានៈជាសមាជិកពេញសិទ្ធិ?

[១០:១៧:១៧]

**ផ៖** អានេះការសន្និដ្ឋានទាន។ ព្រោះពេញសិទ្ធិ គេកំណត់យកអ្នកដែលគ្មានអីសោះ ជាកសិករក្រីក្រ ដែលពីដើមគេហៅថា រកព្រឹកស៊ីព្រឹក រកល្ងាចស៊ីល្ងាច។ តែអ្នកមានរបស់របរស៊ីគ្រប់គ្រាន់ដល់ឆ្នាំ គេហៅថាអ្នកកណ្តាល។ ដល់អ្នកសល់ទៅទៀត អាហ្នឹងគេហៅថាអ្នកលើ។ ហ្នឹងតាមគេនិយាយប្រាប់ ដែលធ្វើវណ្ណៈភាពនោះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមៗ បាទអរគុណ។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ និងសាមសិបប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសនវការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់

សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់ និងសាមសិបប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨ នាទី ដល់ម៉ោង ១០:៣៨ នាទី)*

[១០:៣៨:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកបន្ថែមបន្តិចទៅលើសំណួរដែលលោកបានឆ្លើយកាលពីព្រឹកនេះ។ លោកបានបញ្ជាក់ថា លោកមានកូនចំនួនប្រាំបួន ប៉ុន្តែកូនបួនបានស្លាប់។ តើមានកូនណាម្នាក់ក្នុងចំណោមកូនទាំងបួននោះស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**លោក ឱ ហួ៖**

**ឆ៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កូនស្លាប់មួយដែរទាន ព្រោះវាៗនៅតូច ហើយវាមិន វាស៊ីបបរមិនកើត វាមិនចេះ វាមិនចង់ស៊ី ហើយវាឈឺផងទាន។ មិនអាចមើលកូនជា កូនក៏ស្លាប់ទៅ។

**ស៖** សូមអរគុណ។ ប្រហែលជាបន្តិចទៀតខ្ញុំនឹងសួរសំណួរនេះម្តងទៀត ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរសំណួរលោកទៅលើចំណុចផ្សេង។ លោកបញ្ជាក់ថា លោកបានទទួលបញ្ជីមួយនៅពេលដែលលោកធ្វើជាអ្នកមេភូមិគឺមានបញ្ជីឯកសារ១៥ ដែលត្រូវបញ្ជូនទៅភូមិថ្មី។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយទាន។

[១០:៤០:២២]

**ស៖** តើគ្រួសារទាំង១៥គ្រួសារហ្នឹង តើគាត់មានអ្វីដូចគ្នាទេ ទើបពួកគាត់មានឈ្មោះនៅក្នុងបញ្ជីតែមួយហ្នឹង? តើគាត់អាចនិយាយថាគាត់ស្ថិតក្នុងក្រុមតែមួយ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** អាហ្នឹងវាចូលក្នុងរឿងភរគេណាទាន កាលណោះ។ ភរថាផ្លាស់ទីលំនៅ គេសុំទៅនៅបងប្អូនគេ។

**ស៖** សូមអរគុណ។ ខ្ញុំយល់អំពីចំណុចនេះ ប៉ុន្តែបញ្ជីឈ្មោះគ្រួសារ ថាតើលោកដឹងទេថា ហេតុអ្វីបានជាគ្រួសារទាំង១៥ហ្នឹងត្រូវបានគេជ្រើសរើស? តើពួកគាត់ជាប្រជាជនថ្មី ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** គាត់ជាប្រជាជនថ្មីៗ។

**ស៖** តើលោកដឹងទេថា ពួកគាត់ទាំង១៥គ្រួសារហ្នឹងជាអ្នកមានបណ្ដាស័ក្តិ ជាអ្នកបណ្ដាស័ក្តិនៅក្នុងជួរយោធា ឬក៏ជួរអ្នករដ្ឋការ ឬក៏ពួកគាត់ជាអ្នកបញ្ញវន្ត ចេះដឹងអីដែរឬទេ?

**ឆ៖** អ្នកដែលគេឲ្យទៅនៅភូមិថ្មីទាន? លោកសួរម្ដងទៀតមើលទាន។

**ស៖** ខ្ញុំនិយាយអំពីគ្រួសារ១៥គ្រួសារនៅក្នុងបញ្ជី។

**ឆ៖** បញ្ជីដែលគេផ្ញើឲ្យទៅនៅភូមិថ្មីទាន ហ្នឹងគឺមន្ត្រីរាជការខ្លះ ទាហាន ប៉ូលិសខ្លះទាន។

**ស៖** មុននេះលោកបាននិយាយអំពីយុវជនម្នាក់ឈ្មោះ កៅ ដែលបានឲ្យខោអាវ ហើយនិងឲ្យកង់ ហើយមានការបញ្ជាឲ្យស្វែងរកអ្នកមានឋានន្តរសក្តិ។ តើលោកចាំទេ ថាគេបញ្ជាឲ្យមានឋានន្តរ -- ឲ្យស្វែងរកអ្នកមានឋានន្តរសក្តិកម្រិតណាដែរ?

[១០:៤៣:១៨]

**ឆ៖** គេយកត្រឹមបាក់ឌុបឡើងលើទាន។ យកត្រឹមថ្នាក់ បើយើងឥឡូវថាថ្នាក់ទី១២ឡើងលើ។

**ស៖** តើអ្នកដែលគេរកឃើញថាជាអ្នកជាប់បាក់ឌុប ឬក៏ថាជាអ្នកដែលមានឋានៈខ្ពស់នៅក្នុងរដ្ឋការ ជាមន្ត្រីរដ្ឋការ លន់ នល់ តើមានរឿងអ្វីកើតឡើងចំពោះអ្នកដែលគេរកឃើញនោះ?

**ឆ៖** តែកាលណាគេរកឃើញហើយ ពិបាកណាស់ទាន វាទៅជាគ្រោះអាក្រក់របស់គ្នាទៅហើយ។

**ស៖** តើអ្នកដែលគេរកឃើញហ្នឹងមានបាត់ខ្លួនទេនៅពេលក្រោយ?

**ឆ៖** បាត់ខ្លួនទាន។

**ស៖** ខ្ញុំនិយាយបន្តអំពីគ្រួសារ១៥។ តើលោកអាច -- ឥឡូវនេះខ្ញុំចង់និយាយអំពីគ្រួសារប្រាំពីរដែលលោកមិនអាចលាក់បាំងបាន។ ថាតើក្រុមគ្រួសារទាំងប្រាំពីរគ្រួសារហ្នឹងជាគ្រួសារនៅក្នុងវ័យពេញវ័យ ឧបមាថា អាយុ២០-៣០ឆ្នាំ ឬមួយក៏យ៉ាងម៉េចដែរ?

[១០:៤៥:១៦]

**ឆ៖** ចម្រុះ មិនៗចំពោះតែក្មេងទេ ចាស់ក៏មាន ព្រោះមួយគ្រួសារៗច្រើនដែរ។ ខ្លះមានសមាជិកប្រាំនាក់ ខ្លះប្រាំមួយនាក់អ៊ីចឹងទៅ ខ្លះប្រាំបីនាក់អ៊ីចឹង។

**ស៖** តើសូម្បីតែក្មេងៗក៏គេយកទៅដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោក -- តើនៅពេលក្រោយលោកធ្លាប់បានឃើញ ឬក៏បានជួបគ្រួសារទាំងប្រាំពីរគ្រួសារហ្នឹងម្តងទៀតទេ?

**ឆ៖** អត់បានដែលឃើញទេទាន។

**ស៖** លោកបាននិយាយអំពីខោអាវ ដែលគេបញ្ជូនត្រឡប់មកវិញ។ តើលោកអាចពន្យល់ឲ្យបានលម្អិតបន្តិចបានទេ ថាតើខោអាវដែលគេបញ្ជូនត្រឡប់មកវិញហ្នឹង ហេតុអ្វីបានលោអាចសន្និដ្ឋានថានៅពេលដែលឃើញខោអាវបញ្ជូនត្រឡប់មកវិញហ្នឹង លោកសន្និដ្ឋានថា មនុស្សហ្នឹងត្រូវបានគេសម្លាប់?

**ឆ៖** កាលណាគេយកទៅ គេផ្ញើខោអាវមកតាមភូមិវិញ ជួនកាលខោអាវហ្នឹងក៏វាដោយមកទៅ អ្នកខ្លះគេស្គាល់ទាន។ ស្គាល់ថាខោអាវអ្នកនេះ ខោអាវអ្នកនោះ ព្រោះកាលហ្នឹងវាខ្វះខោអាវស្លៀកពាក់ណាស់។

**ស៖** តើលោកអាចប្រាប់ទេថា ខោអាវដែលគេបញ្ជូនត្រឡប់មកវិញ គឺជាខោអាវដែលអ្នកទាំងប៉ុន្មានគ្រួសារហ្នឹងគាត់ស្លៀកពាក់នៅពេលដែលគាត់បាត់ខ្លួន? តើអ៊ីចឹងមែនទេ?

**ឆ៖** ខោអាវទាំងអស់ហ្នឹងមានខោអាវថ្មី ខោអាវចាស់អ៊ីចឹងដែរ មិនសុទ្ធតែចាស់ទាំងអស់ទេ។

[១០:៤៧:៤៥]

**ស៖** ខ្ញុំចង់សួរថា ខោអាវដែលគេបញ្ជូនត្រឡប់មកវិញគឺជាខោអាវអ្នកដែល -- គឺជាខោអាវដែលអ្នកដែលគេយកទៅហ្នឹងគាត់ស្លៀកពាក់ អ៊ីចឹងមែនទេ?

**ឆ៖** ហ្នឹងខោអាវដែលគេផ្ញើមកវិញហ្នឹង គឺខោអាវអ្នកធ្លាប់ពាក់ខ្លះ មិនធ្លាប់ពាក់ខ្លះ មិនដែលឃើញខ្លះ។ វាខោអាវចម្រុះទេទាន។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមប្តូរទៅប្រធានបទថ្មី គឺទំនប់១មករា។ លោកធ្វើការនៅក្នុងការដ្ឋានទំនប់១មករា អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបាទធ្វើការនៅតាមប្រឡាយទេទាន មិនមែនធ្វើការខាងទំនប់ទេ ធ្វើការប្រឡាយ ជីក

ប្រឡាយ។ ផុតពី១មករាមកប្រហែលជាបី ៤០០, ៥០០ម៉ែត្រ បានខ្ញុំចាប់ផ្ដើមជីកខាងហ្នឹង ព្រោះខាងប្រឡាយ គេខាងចល័ត។ គេកម្លាំងលេខ១ គេនៅខាងប្រឡាយ។

**ស៖** អ៊ីចឹងការងាររបស់លោកគឺត្រួតពិនិត្យទៅលើមួយកង អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំ ខែ -- ដូចថាខែប្រាំងធ្វើប្រឡាយ ដល់ខែវស្សាខ្ញុំទៅធ្វើស្រែទៅ ត្រួតតែមួយកង ប៉ុណ្ណឹងឯង។ ដឹងតែប្រាំងធ្វើប្រឡាយតែម្ដង ខែវស្សាធ្វើស្រែ។

**ស៖** តើលោកដឹងទេថា គេចាប់ផ្ដើមកសាងទំនប់១មករានៅពេលណា?

[១០:៥០:០២]

**ឆ៖** ១មករាហ្នឹង គឺដែលសមមិត្តប្រធានបក្សលោកទៅសម្ពោធនៅថ្ងៃ១ មករា លោក ប៉ុល ពត លោកទៅថ្ងៃ១ មករា។ បានថាទំនប់ហ្នឹងគេកំណត់ថាទំនប់១មករាតែម្ដង។

**ស៖** លោកថា ១ មករាហ្នឹង តើ ១ មករា ឆ្នាំណាដែរ? តើគេសម្ពោធហ្នឹង នៅក្នុងឆ្នាំណាដែរ?

**ឆ៖** ដែលបើកការដ្ឋាននៅថ្ងៃ១ មករា តែយើងជីកៗមុនណ៎ាទាន ជីកមុនបួនប្រាំ ជិតម៉ា -- ប្រហែលជិតកន្លះខែ ជីកមុនណ៎ា។ ដល់ថ្ងៃ១ មករាហ្នឹង លោកៗ ប៉ុល ពត លោកអញ្ជើញទៅៗបើកការដ្ឋាន។

**ស៖** អ៊ីចឹង ចង់ -- ខ្ញុំដឹងថាពិធីសម្ពោធ គឺនៅក្នុងថ្ងៃ១ មករា ប៉ុន្តែចុះគេចាប់ផ្ដើមជីកហ្នឹងនៅក្នុងឆ្នាំណាដែរ ឆ្នាំ៧៥, ៧៦, ៧៧?

**ឆ៖** ការជីកហ្នឹងគឺជីកនៅឆ្នាំ ដើមឆ្នាំ៧៦ ចុងឆ្នាំ -- ដើមឆ្នាំ៧៧ ចុងឆ្នាំ៧៦។

**ស៖** លោកបាននិយាយអំពីវិធីសម្ពោធ។ តើក្នុងពិធីសម្ពោធហ្នឹង មានថ្នាក់ដឹកនាំជាន់ខ្ពស់ណាផ្សេងចូលរួមដែរឬទេ?

**ឆ៖** បាទទាន ខ្ញុំមិនសូវស្គាល់ទេ ខ្ញុំមិនស្គាល់គេទេ ដែលលោក ប៉ុល ពត ដែលលោកអញ្ជើញទៅ ហើយនិងលោកប្រធានភូមិភាគដែលលោកទៅហ្នឹង គេគ្រាន់តែចង្អុលប្រាប់ថានោះ ន៏លោកសមមិត្ត ពក នោះ សមមិត្តដែល--។

**ស៖** លោកចង់និយាយថា កែ ពក ជាអ្នកប្រាប់លោកថាហ្នឹងគឺ ប៉ុល ពត អ៊ីចឹងមែនទេ?

**ឆ៖** គេមិនបានប្រាប់ថាអ៊ីចឹងទេទាន គេប្រើពាក្យ "អង្គការ" អង្គការមកៗជា -- អង្កាល់ហ្នឹង មិនដឹងនិយាយថាម៉េចទេទាន មិនដឹងនិយាយ បើឥឡូវគេថាអធិបតីហើយណ៎ា ប៉ុន្តែអង្កាល់នោះ មិនដឹងនិយាយថាម៉េចទេ ខ្ញុំវាភ្លេចអស់ហើយទាន។

[១០:៥៣:២៩]

**ស៖** សូមអរគុណ។ ទំនប់១មករាហ្នឹង ថាតើៗទំនប់ហ្នឹងទប់ទន្លេ ឬទប់ស្ទឹងអីដែរ? ប្រសិនបើទប់ទន្លេ ទប់ស្ទឹងហ្នឹង តើទន្លេស្ទឹងហ្នឹងឈ្មោះអីដែរ?

**ឆ៖** ទំនប់១មករានេះទប់ស្ទឹងជីនិតទាន ស្ទឹងជីនិត។ ហើយសព្វថ្ងៃ គេធ្វើទំនប់១មករាថែមទៀតហ្នឹង គេធ្វើស្រូវបានច្រើនណាស់។ គេធ្វើស្រូវពីទឹក១មករាហ្នឹង តែគេកែប្រែ អាទំនប់ដែលៗលោក ប៉ុល ពត លោកទៅនោះ អាហ្នឹងគេទុកចោលទេ តែគេមិនរើបំបែកទេ ទុកចោលទៅ ព្រោះអាហ្នឹងវាកែវាមិនកើត ព្រោះមនុស្សវាបោកគ្រាប់បែក បាក់ខ្ទេចខ្ទាំណាទាន ហើយគេធ្វើថ្មីទៀតនេះ ល្អរបស់គេដែរ។

**ស៖** ប្រសិនបើខ្ញុំស្តាប់មិនខុសទេ គឺទំនប់ហ្នឹងទប់ស្ទឹងជីនិត អ៊ីចឹងមែនទេ?

**ឆ៖** ទប់ស្ទឹងជីនិត ទប់ស្ទឹងជីនិតយកទឹកធ្វើស្រែ។

**ស៖** ថាតើទំនប់១មករា ហ្នឹងគេកសាងនៅក្នុងភូមិឃុំដែរ ឬក៏ប្រសិនបើលោកមិនស្គាល់ភូមិឃុំទេ អាចប្រាប់ថា តើទំនប់ហ្នឹងនៅក្នុងស្រុកអីដែរ?

**ឆ៖** ទំនប់១មករានេះនៅក្នុងឃុំបល្ល័ង្គ ហ្នឹងខាងត្បូង នៅឃុំបល្ល័ង្គ ខាងជើងនៅខាងឃុំកំពង់ថ្ម ហើយទៅជើងទៀតបានវាមានទំនប់មួយទៀត គេហៅថា ៦មករា។

**ស៖** សូមអរគុណលោក។ ដូច្នេះ ខ្ញុំចង់ដឹងថាតើពីទំនប់១មករា ទៅទំនប់៦មករា ហ្នឹងមានចម្ងាយប្រហែលប៉ុន្មានម៉ែត្រ ប៉ុន្មានគីឡូម៉ែត្រដែរ?

**ឆ៖** ទានខ្ញុំមិនបានវាស់ទេ ប៉ុន្តែតាមស្មាន ប្រហែលជា៤គីឡូ ឬទៅ៥គីឡូម៉ែត្រ។

[១០:៥៦:៣៤]

**ស៖** លោកបានបញ្ជាក់ថា លោកធ្វើការជីកប្រឡាយនៅក្បែរទំនប់ គឺភ្ជាប់ទៅនឹងទំនប់ គឺលោកជីកប្រឡាយនៅក្បែរហ្នឹង។ អ៊ីចឹងមានន័យថា គឺមានគម្រោងជីកប្រឡាយបន្តពីទំនប់មកអ៊ីចឹងមែនទេ? ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** យល់អ៊ីចឹងត្រឹមត្រូវហើយទាន ត្រឹមត្រូវគឺគេធ្វើទំនប់ ជីកប្រឡាយពីទំនប់ហ្នឹងមក យកទឹកពីទំនប់ហ្នឹងទៅឲ្យអ្នកខាងក្រោមធ្វើស្រែ គេធ្វើបានណាស់។

**ស៖** តើមានការភ្ជាប់ពីទំនប់១មករា ទៅ៦មករាទេ? តើមានប្រឡាយភ្ជាប់ពីទំនប់១មករា ទៅ៦មករាទេ?

**ឆ៖** ពី១មករា ទៅ៦មករាជាប់គ្នាទាន ជាប់គ្នារហូត ព្រោះ៦មករាក៏យកទឹកស្ទឹងជីនិត ១មករាក៏យកស្ទឹងជីនិត ប៉ុន្តែដល់៦មករាបានស្ទឹងមួយថ្មី ប៉ុន្តែស្ទឹងហ្នឹងវាចេញតិចៗទេ បានទឹកស្ទឹងជីនិតទៅ។

**ស៖** ក្រុមដែលធ្វើការទប់ទំនប់១មករាហ្នឹង គឺពួកគាត់ត្រូវទៅធ្វើការនៅ៦មករាតទៀត ឬមួយក៏ក្រុមការងារផ្សេងពីរពីគ្នា?

**ឆ៖** ការងារធ្វើ ខ្ញុំធ្វើតែខាងបារាយណ៍ ខាង១មករាទេទាន។ ខាង៦មករា គឺខាងសន្ទុក ខាងកំពង់ធំ គេធ្វើកាលហ្នឹង។ កាលហ្នឹងគេចែកត្រឹមស្ទឹងជីនិត ម្ខាង៤២ ម្ខាង៤៣។ អាហ្នឹងទៅខាង៤៣ទេ។

**ស៖** តើចម្ងាយពីភូមិលោកទៅទំនប់១មករាហ្នឹង មានចម្ងាយប៉ុន្មានដែរ?

**ឆ៖** ភូមិខ្ញុំពីដើមនៅព្រៃស្រង៉ែហ្នឹង វាជាប់នឹងប្រឡាយ១មករានេះឯង ជាប់គ្នាពីផ្ទះខ្ញុំទៅ១មករា ទៅដល់ស្ពានតែម្តង វា៣គីឡូ។

[១០:៥៩:២៩]

**ស៖** ដូច្នេះនៅពេលដែលលោកធ្វើការនៅទំនប់ហ្នឹង ថាតើលោកមានកូនក្រុម ឬក៏លោកត្រូវពិនិត្យមើលកូនក្រុមប៉ុន្មាននាក់ដែរ នៅក្នុងកងរបស់លោក?

**ឆ៖** កាលដែលធ្វើនៅក្នុងហ្នឹង វាមនុស្សច្រើនដែរទាន ប្រហែល១០០នាក់ដែរ។ ហើយការងារយកចិត្តទុកដាក់ មើលការខុសត្រូវកុំឲ្យគ្នាឈឺ គ្នាជា គ្នាឈឺថ្កាត់ណា។ បើកាលណាឈឺថ្កាត់បណ្តេញទៅសុំថ្នាំពេទ្យទៅ។ បើកាលនោះយើងគ្មានថ្នាំល្អទេ យើងប្រើថ្នាំដែលយើងផ្សំខ្លួនយើង អ្នកចេះថ្នាំផ្សំទៅ ដែលគេថាអាចម៍ទន្សោយ ធ្វើម៉េចទៅវា ប៉ុន្តែជាខ្លះដែរ។

**ស៖** សូមអរគុណលោក។ ខ្ញុំចង់ជម្រាបលោកថា លោកឆ្លើយសំណួរខ្ញុំឲ្យចំទៅ ព្រោះប្រសិនបើលោកនិយាយទៅដល់ចំណុចផ្សេង បន្តិចទៀតខ្ញុំសួរលោកចំណុចហើយ។ ប៉ុន្តែឥឡូវលោកនិយាយថាលោកបាន គឺអ្នកកូនក្រុមរបស់លោកមាន១០០នាក់។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកអាចប៉ាន់ប្រមាណមើល ថាតើមានមនុស្សប៉ុន្មាននាក់ធ្វើការទាំង -- មនុស្សប៉ុន្មាននាក់ដែលធ្វើការនៅទំនប់១មករាទាំងស្រុងតែម្តងនោះ?

**ឆ៖** ខ្ញុំឆ្លើយមិនរួចទេ។ ខ្ញុំឆ្លើយរួចទេ បើមនុស្សច្រើន ដឹងថាច្រើន។

**ស៖** ខ្ញុំយល់ថា លោកមិនអាចប្រាប់ឲ្យច្បាស់អំពីចំនួនទេ ប៉ុន្តែលោកអាចធ្វើការប៉ាន់ប្រមាណមើល អាចថា -- ឥឡូវលោកសាកល្បងប៉ាន់ប្រមាណមើល ថាតើមានមនុស្សប៉ុន្មាននាក់ដែរ ដែលធ្វើ

ការនៅទំនប់១មករានោះ?

**ឆ៖** ដូចស្មានមិនត្រូវទេ បើស្មាន វាមិនដឹងថាប៉ុន្មានទេ។ វាមនុស្សរាប់ម៉ឺននាក់ហ្នឹងបានធ្វើរួច។ ពាក្យថា "១មករា" ហ្នឹង វាតាំងពី០មករាមក វាជាប់រហូត។

**ស៖** សូមអរគុណលោក។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកទាំងភាសាអង់គ្លេស និងភាសាខ្មែរ នៅទំព័រទី១៥ -- ទំព័រទី៥ ហើយទំព័រទី៤ លោកបានស្មានថា ប្រហែលជាមានមនុស្ស ២០០.០០០នាក់ -- ២០.០០០នាក់ មកពីតំបន់៤២, ៤៣, ៤៤។ តើលោកគិតថា ចំនួនដែលលោកប៉ាន់ប្រមាណជាមួយអ្នកស៊ើបអង្កេតហ្នឹង វាត្រឹមត្រូវដែរឬទេ ដែលថាមានមនុស្សប្រហែល២០.០០០នាក់ មកពីតំបន់៤១, ៤២ និង៤៣នោះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក ឱ ហួ៖**

**ឆ៖** មនុស្សច្រើនណាស់ ប្រហែលប៉ុណ្ណឹងមែនទាន។ ខ្ញុំស្មានទេណាស់ ប្រហែលចូលដល់ ២០.០០០នាក់មែនហ្នឹង ព្រោះច្រើនណាស់។

[១១:០៣:៣០]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើទំនប់ហ្នឹងគេកសាងហើយនៅពេលដែលលោកធ្វើជាមេភូមិ ឬក៏នៅក្រោយទេ?

**ឆ៖** ទំនប់ហ្នឹងៗ គេ -- ខ្ញុំធ្វើមេភូមិហ្នឹង ទំនប់ហ្នឹងវាជីកដល់ត្រឹមកំប៉ើយ។ ដល់ឆ្នាំ៧៨ គេជីកពីកំប៉ើយមកបារាយណ៍ទៀត ១មករា ដូចគ្នាហ្នឹងឯង មកបារាយណ៍ទៀត មិនទាន់ហើយស្រួលបួលទេ ខ្ញុំអង្គការរំសាយទៅ។ ប៉ុន្តែមានបានប្រើប្រាស់បានស្រួលហើយ ស្រួលខ្លះៗហើយ។ អ្នកធ្វើស្រែប្រាំង ក៏បានធ្វើស្រែប្រាំងអីត្រឹមត្រូវរបស់គេ។

**ស៖** តើបើតាមដែលលោកដឹង គឺថាទំនប់១មករាហ្នឹង គេធ្វើចប់មុនពេលដែលដួលរលំរបប កម្ពុជាប្រជាធិបតេយ្យ អ៊ីចឹងមែនទេ?

**ឆ៖** ទំនប់១មករាហ្នឹង គេធ្វើវាមិនទាន់ស្រេចទេ ដែលប៉ុន្តែប្រើប្រាស់បាន៩០ភាគរយហើយ ទាន។ ដល់ដាច់មកបានវា -- គេធ្វើក្រោយនេះ គេធ្វើតែតាមដំណែលចាស់ទេ។

**ស៖** តើទំនប់នុំងមានបញ្ហាអីទេ នៅពេលដែលរដូវវស្សានុំង? តើមានទឹកភ្លៀងអីហូរបាក់ទំនប់នុំងទេ?

**ឆ៖** អង្កាល់ដែលធ្វើរួចអត់មានទេទាន អត់មានហូរបាកទេ គឺគេថែរក្សាណាស់។ ប្រធានភូមិភាគ គាត់ដាក់មនុស្សថែរក្សាប្រហែលជា១០០នាក់ នៅថែរក្សា។ ឃើញត្រង់ណាមិនស្រួលគាត់រៀបចំភ្លាម។

**ស៖** ខ្ញុំនឹងសួរឡើងវិញ តើលោកដឹងទេថា អ្នកណាជាអ្នកគ្រប់គ្រងគម្រោងសាងសង់នេះ?

**ឆ៖** ទានៗ ខ្ញុំមិនដឹងទេទាន។ សួរដល់ជ្រៅប៉ុណ្ណឹងខ្ញុំមិនដឹងទេ។

**ស៖** តើលោកដឹងទេថា តើ កែ ពក គាត់មានតួនាទីអីទេក្នុងការសាងសង់ទំនប់នេះ?

**ឆ៖** គាត់ទទួលពីថ្នាក់លើទៅ គាត់មើលការខុសត្រូវទំនប់ហ្នឹងទាំងស្រុង។ គាត់ពិនិត្យពិច័យខ្លួនគាត់ ចុះជាប់រាល់ថ្ងៃ ពីអង្កាល់ដែលនៅ។ ម៉ូយ៉ាងហោចណាស់ក៏មកម្តងដែរ។

[១១:០៧:៤៧]

**ស៖** សូមអរគុណ។ តើលោកដឹងទេថា តើគាត់មានអ្នកក្រោមបង្គាប់ណាដែរ ដែលអ្នកមើលការខុសត្រូវនៅទំនប់ហ្នឹង?

**ឆ៖** ខ្ញុំបាទ មិនដឹងទេទាន។ មិនដឹងទេ។

**ស៖** លោកសាក្សីខ្ញុំគិត -- លោកនិយាយថា ភូមិរបស់លោកស្ថិតនៅចម្ងាយ៣គីឡូម៉ែត្រពីទំនប់នេះ។ អ៊ីចឹងនៅពេលដែលលោកធ្វើការនៅទំនប់នោះ លោកមកសម្រាក -- ពេលយប់ឡើងនឹងមកសម្រាកនៅផ្ទះវិញ ឬក៏យ៉ាងម៉េច?

**ឆ៖** អត់សម្រាកផ្ទះទេទាន ធ្វើខ្ទមម៉ារីយ៉េអីដេកហ្នឹងទាំងអស់គ្នា ជិតផ្ទះមែន ប៉ុន្តែដេកហ្នឹងទាំងអស់គ្នា។ នែ៎ ដើម្បីនឹងធ្វើការងារ។ មកផ្ទះបានតែ១០ថ្ងៃម្តងទេ មក។

**ស៖** ដូច្នេះ គឺថាលោកនៅសម្រាកនៅកន្លែងធ្វើការហ្នឹង គឺនៅក្នុងរយៈពេល១០ថ្ងៃអីតែម្តង។ អ៊ីចឹងខ្ញុំចង់ដឹងថា តើកម្មករដែលធ្វើការនៅនុំងគាត់សម្រាកនៅការដ្ឋានហ្នឹងដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់សម្រាកដូចតែគ្នាហ្នឹង ដូចតែខ្ញុំអ៊ីចឹង។ គាត់ក៏សម្រាកហ្នឹង ខ្ញុំក៏សម្រាកហ្នឹង ដូចតែគ្នាហ្នឹង។

**ស៖** តើកម្មករដែលមានអាយុក្មេងជាងគេហ្នឹង គឺប្រហែលប៉ុន្មានដែរ ប្រហែលអាយុប៉ុន្មានដែរ?

**ឆ៖** អ្នកដែលធ្វើការនៅហ្នឹងច្រើនតែអាយុ១៨ឡើងទៅ អាហ្នឹងគេហៅចល័តហ្នឹងទាន។ អាហ្នឹងធ្វើអីទំនប់នោះទេ អ្នកដែលធ្វើនៅប្រឡាយនេះគឺអ្នកមានប្ដីមានប្រពន្ធ។

**ស៖** អ៊ីចឹងមានន័យថា អត់ៗមានកុមារធ្វើការនៅការដ្ឋានហ្នឹងទេមែនទេ ឬក៏ខ្ញុំស្ដាប់មិនច្បាស់?

[១១:១០:៥០]

**ឆ៖** អត់មានកូនក្មេងតូចៗទៅធ្វើការនៅហ្នឹងទេ។ កូនក្មេងតូចៗមានក្រុមគេ គេរើសអាចម៍គោ ដើររើសអីណោះទេ ផ្ទះឯក្រោយទេទាន។

**ស៖** អ៊ីចឹងមានន័យថាក្មេងៗធ្វើការផ្សេងមិនធ្វើការនៅការដ្ឋានសាងសង់ទំនប់ហ្នឹងទេ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទទាន អ៊ីចឹង។

**ស៖** តើកម្មករដែលធ្វើការនៅការដ្ឋានហ្នឹង ធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ?

**ឆ៖** យើងកាលណោះ យើងចុះម៉ោងបួនចុះ ម៉ោងបួនយប់ចុះ ធ្វើទាល់តែដល់ម៉ោងដប់មួយបានយើងឡើងមករកបបរទៅ។ ហើយម៉ោងពីរយើងចុះទៀត ទាល់តែដល់ម៉ោងប្រាំ បានយើងឡើងមករកបបរ។

**ស៖** ចុះក្រោយពីម៉ោងប្រាំហ្នឹង ពួកគាត់ធ្វើអីទៀត?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក ឱ ហួ៖**

**ឆ៖** ក្រោយពេលដែលម៉ោងប្រាំរួចទៅ ដែលពិសារួចទៅ ក្រោយមកទៀត យល់ឃើញថា ឲ្យវាឆាប់លឿនហ្នឹងក៏មានផែនការធ្វើយប់ទៀត ម៉ោងដប់បានយើងឈប់។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** អ៊ីចឹងមានន័យថា ធ្វើការពេលយប់ហ្នឹងតាំងពីម៉ោងប្រាំពីររហូតដល់ម៉ោងដប់យប់។ អ៊ីចឹងបើគិតទៅធ្វើការតាំងពីម៉ោងបួនរហូតទៅដល់ម៉ោងដប់មួយពេលព្រឹក ហើយបើយើងរាប់ទៅគឺប្រហែលជាមួយថ្ងៃធ្វើការ១៣ម៉ោងហើយ។ អ៊ីចឹង តើកម្មករហ្នឹងគាត់ទទួលបានប្រាក់ខែប៉ុន្មានដែរ?

[១១:១៣:៤៦]

**ឆ៖** ទាន និយាយប្រាប់ខែមិនម៉េចកើតកាលណោះ បានតែបបរគ្រប់គ្រាន់ទៅបានទៅហើយ។ វាអត់អី វាមានតែបបរទេ។

**ស៖** កម្មករដែលធ្វើការនៅការដ្ឋានហ្នឹងគាត់ធ្វើការដោយស្ម័គ្រចិត្ត ឬក៏គាត់មិនស្ម័គ្រចិត្តទេ គាត់ចង់ទៅធ្វើការផ្សេង ទៅធ្វើស្រែផ្សេង? ខ្ញុំចង់មានន័យថា គាត់ស្ម័គ្រចិត្តធ្វើ ឬក៏គេបង្ខំឲ្យគាត់ធ្វើ?

**ឆ៖** វាពិបាកនិយាយណាស់ទាន ថាស្ម័គ្រចិត្តក៏ថាមិនបាន ថាមិនស្ម័គ្រក៏ថាមិនបាន ព្រោះដំណើរត្រូវតែធ្វើ។ ស្ម័គ្រក៏ធ្វើ មិនស្ម័គ្រក៏ធ្វើ។

**ស៖** លោកសាក្សី ខ្ញុំឃើញលោកសើច នៅពេលដែលខ្ញុំសួរថាតើកម្មករទទួលបានប្រាក់ខែ ឬក៏អត់? អ៊ីចឹងខ្ញុំឃើញលោកសើចម្ដងទៀតហើយ នៅពេលដែលខ្ញុំសួរថាតើអ្នកធ្វើការហ្នឹងនៅទីនោះ គាត់ស្ម័គ្រចិត្ត ឬក៏អត់? ដូច្នេះយើងអាចនិយាយថា អ្នកធ្វើការនៅការដ្ឋាននោះត្រូវតែធ្វើការតាមការបង្គាប់ មែនទេ? ហើយប្រសិនបើមិនព្រមធ្វើទេ គឺប្រហែលជាអាចមានរឿងអ្វីកើតឡើងចំពោះពួកគាត់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយទាន។

**ស៖** លោកបានឆ្លើយថាមានតែមនុស្សធំទេ ដែលធ្វើការដ្ឋាន អត់មានកុមារទេ។ ហើយចុះគ្រួសារពួកគាត់មានប្រុសស្រី ឧទាហរណ៍ដូចជាប្ដីប្រពន្ធអ៊ីចឹង គាត់ត្រូវតែមានកូនបីបួននាក់ អ៊ីចឹងពេលដែលធ្វើការហើយ ប្ដីប្រពន្ធហ្នឹងជួបជុំគ្នាពេលយប់ឡើងហ្នឹង ហើយមានអាចនិយាយស្ដីអីជាមួយកូនបានទេ?

[១១:១៦:១៥]

**ឆ៖** មានពេលខ្លះ គឺបើអ្នកណាដែលគ្នាកូនច្រើន តូចៗច្រើនហ្នឹង គ្នាសុំមកដេកផ្ទះ ក៏អនុគ្រោះឲ្យមកដេកខ្លះទៅ។ នេះចំពោះភូមិខ្លះដែលនៅជិតៗហ្នឹងបង។ ដល់អ្នកដែលនៅឆ្ងាយមិនបានមកទេ គេរើសកម្លាំងហើយហ្នឹង ជាកម្លាំងដែលពេញ គ្មានកូនតូចៗទេ។

**ស៖** តើក្រុមគ្រួសារហូបបាយជុំគ្នាទេ ប្ដីប្រពន្ធអីហ្នឹង គាត់អាចហូបបាយជាមួយគ្នាទេ?

**ឆ៖** បើហូបបាយជុំគ្នាទាល់តែទៅធ្វើការដ្ឋានជាមួយគ្នា បើមិនធ្វើការដ្ឋានជាមួយគ្នាទេ មិនបានជួបជុំគ្នាទេ។

**ស៖** គឺថាពេលហូបបាយហ្នឹង គឺថាគេទទួលហូបជុំគ្នា តើអ៊ីចឹងមែនទេ?

**ឆ៖** ពេលហូបហ្នឹង គឺគេហូបរួមទាន គេហូបរួម គេដាំនឹងខ្ទះធំអ៊ីចឹងទៅ គេចែករបរគ្នាហ្នឹង។

បើថាមួយវែក ពីរវែកម្នាក់ យើងដួសពីរវែកៗម្នាក់ទៅ ឲ្យដូចៗគ្នាទៅ។ បើថាបាយក៏បាយទាំងអស់គ្នាទៅ បើថាបបរក៏បបរទាំងអស់គ្នាទៅ។

**ស៖** តើការងារហ្នឹងគឺលំបាកលំបិនទេ?

**ឆ៖** ការងារនោះ វាពិបាកក្រៃលែងពិបាកហើយទាន មិនស្រួលទេ។ ខែណោះកំពុងពេញក្តៅខែណោះហើយដែលកំពុងប្រយុទ្ធនោះ។ ក្តៅកាន់តែខ្លាំងប្រយុទ្ធកាន់តែខ្លាំង ព្រោះវាអត់ភ្លៀង។ អ៊ីចឹងវាស្បែកហ្នឹងវាទ្រាំនឹងថ្ងៃទៅហើយកាលណោះ។

[១១:១៩:០៦]

**ស៖** បបរដែលគេចែកទៅឲ្យកម្មករ ឬក៏អាហារដែលគេចែកហ្នឹង គឺតើវាមានលក្ខណៈគ្រប់គ្រាន់ទេ ដើម្បីឲ្យកម្មករអាចមានកម្លាំងធ្វើការទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក ឱ ហួ៖**

**ឆ៖** ខ្ញុំចេះតែភ្លេច។ បបរដែលគេឲ្យទៅហ្នឹងបានមួយគ្រប់មួយគ្រាន់ហ្នឹង មិនមានខ្វះទេ ព្រោះកម្លាំងហ្នឹងកម្លាំងពិសេស ក៏ប៉ុន្តែវាៗបបររាវ មិនមែនទេគឺបបររាងខាប់បន្តិច យើងថាដួសស្លឹកព្រាក៏បាន ចាប់នឹងដៃក៏បាន ប៉ុនវាបបរទេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើកម្មករមានសុខភាពល្អទេ ឬក៏ពួកគាត់មើលទៅអាចមានកង្វះអាហារូបត្ថម្ភ?

**ឆ៖** កម្មករ មិនមានសុខភាពទេទាន។ ប៉ុន្តែចេះតែខំធ្វើទាំងអស់គ្នាទៅណា ផឹកថ្នាំឬសឈើមើមឈើទាំងអស់គ្នាទៅ។ ថ្នាំយើងដាំនឹងឆ្នាំងធំៗ ហើយនៅកន្លែងការដ្ឋាន គឺយើងដាំឆ្នាំងធំមួយទៀតទៅទុកសម្រាប់ផឹកទាំងអស់តែគ្នាហ្នឹង។

[១១:២១:២១]

**ស៖** តើកម្មករត្រូវធ្វើការសម្រេចឲ្យបានតាមគោលដៅទេ ឧទាហរណ៍ដូចថា ក្នុងមួយថ្ងៃអ៊ីចឹងត្រូវសម្រេចឲ្យបានប៉ុន្មានម៉ែត្រគូបៗទេ?

**ឆ៖** តាមការងារដែលធ្វើនោះវាមិនបានគ្រប់ទាំងអស់ទេទាន ដាក់វាធូន់ពេកទៅ ក៏គ្នាធ្វើវាមិន

បានដែរទាន។ មួយថ្ងៃជួនកាលបាន១ម៉ែត្រគូប ជួនកាលបាន២ម៉ែត្រគូប ទៅតាមសាច់ស្ថានភាពដីទេ។

**ស៖** ប្រសិនបើមេ -- ថ្នាក់លើរបស់លោកដឹងថាមានកម្មករណាម្នាក់មិនអាចសម្រេចបានតាមគោលដៅដែលគេកំណត់ហ្នឹង តើគេនឹងធ្វើយ៉ាងម៉េចចំពោះកម្មករនោះ?

**ឆ៖** ត្រង់ចំណែកហ្នឹង បើមេភូមិចិត្តមិនល្អ ទៅរាយការណ៍ប្រាប់គេ គ្នាគ្រោះថ្នាក់ហើយ គេពិន័យហើយ។ តែបើយើងចិត្តល្អជាមួយគ្នាទៅ កុំមាត់កុំក ធ្វើទាំងអស់គ្នាទៅវាគង់តែនឹងបាន វារួចខ្លួនទាំងអស់គ្នាទៅណាទាន។

**ស៖** លោកសាក្សី ប្រសិនបើមេរបស់លោកនិយាយថា ក្រុមរបស់លោកនោះធ្វើការមិនល្អនោះ តើលោកមានភ័យខ្លាចទេនៅពេលដែលគាត់និយាយបែបហ្នឹង? លោកភ័យខ្លាចថាមានរឿងអ្វីកើតឡើងចំពោះលោកទេ? លោកមានភ័យខ្លាចទេប្រសិនបើធ្វើការមិនបានសម្រេចតាមគោលដៅនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ នេះជាសំណួរសួរឲ្យសាក្សីស្មាន។ យើងអាចនិយាយអំពីហេតុការណ៍ជាក់ស្ដែងណាមួយដែលកើតឡើង យើងមិនគួរសួរគាត់ឲ្យស្មានទេ។ ឧទាហរណ៍ថា ប្រសិនបើមានរឿងអ្វីកើតឡើងអីអ៊ីចឹង គឺជាការសួរឲ្យគាត់ស្មានហើយលោកប្រធាន។

[១១:២៤:២៧]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំនឹងរៀបចំសំណួរខ្ញុំឡើងវិញ។ ខ្ញុំសួរលោកថា តើលោកភ័យខ្លាចទេ -- ខ្ញុំសួរម្ដងទៀត។ លោកសាក្សីនៅពេលដែលលោកធ្វើការនៅទីនោះ តើលោកភ័យខ្លាចនឹងទទួលរងនូវហេតុការណ៍អាក្រក់ណាមួយកើតឡើងទេ ប្រសិនបើលោកមិនអាចសម្រេចបានតាមគោលដៅដែលគេកំណត់នោះ?

**លោក ឱ ហួ៖**

**ឆ៖** ទាន បើកាលណាក្រុមធ្វើវាមិនបាន វាប្រឈមមុខនឹងប្រធានហើយបាទ។ ប្រធានត្រូវតែដោះស្រាយធ្វើរឿងហ្នឹង ប្រាប់ថ្នាក់លើឲ្យតាមលក្ខណៈស្រួលបួលទៅ ឲ្យគាត់យល់ស្រួលបួល លើកហេតុផលឲ្យគាត់យល់ស្រួលបួលទៅ អាហ្នឹងបានរួចខ្លួន។

**ឆ៖** លោកសាក្សី ឥឡូវនេះខ្ញុំចង់សួរលោកឲ្យពន្យល់អំពីចំណុចមួយដែលលោកបានឆ្លើយនៅ

ក្នុងកិច្ចសម្ភាសន៍កាលពីឆ្នាំ២០០៨ ជាភាសាបារាំងគឺ 00272727, ជាខ្មែរ 00239909។ នៅខាងក្រោមទំព័រជាភាសាអង់គ្លេស លោកនិយាយថា "ថ្នាក់លើកំណត់ផែនការឲ្យមកថ្នាក់ក្រោម បន្ទាប់មកទៀតថ្នាក់ៗក្រោមត្រូវតែធ្វើរបាយការណ៍ទៅថ្នាក់លើ។ ថ្នាក់លើចុះមកត្រួតពិនិត្យ ហើយបើគេដឹងថាមិនអាចសម្រេចបានតាមគោលដៅទេ គេចោទថ្នាក់ក្រោមថាក្បត់ រួចយកទៅសម្លាប់។ ជួនកាលថ្នាក់កណ្តាលចាប់ថ្នាក់ក្រោមទៅសម្លាប់ផងដែរ។ ជាពិសេសមេក្រុមភាគច្រើនជាអ្នករាយការណ៍ចាប់កូនក្រុមរបស់ខ្លួន ដោយចោទថាខ្មាំង"។ លោកសាក្សី ខ្ញុំចង់ឲ្យលោកពន្យល់នូវចម្លើយរបស់លោកដែលខ្ញុំបានអានអម្បាញ់មិញនេះ លោកនិយាយអំពីកាល -- ពីឆ្នាំ២០០៨ ហ្នឹង តើចម្លើយហ្នឹងត្រឹមត្រូវទេ?

**ឆ៖** សូមសួរម្តងទៀតទាន ខ្ញុំស្តាប់មិនសូវបាន។

**ស៖** កាលពីឆ្នាំ២០០៨នោះ តើចម្លើយរបស់លោកឆ្លើយហ្នឹងគឺត្រឹមត្រូវទេ លោកនិយាយថា "ក្រោយពីថ្នាក់លើពិនិត្យឃើញថាការងារមិនចប់តាមផែនការ ពេលនោះថ្នាក់លើចោទថ្នាក់ក្រោមថាក្បត់ រួចយកទៅសម្លាប់"។ ខ្ញុំចង់ដឹងថាចម្លើយហ្នឹងត្រូវទេ ចម្លើយដែលលោកឆ្លើយកាលពី២០០៨នោះ?

[១១:២៧:៤៧]

**ឆ៖** អ៊ីចឹង។

**ស៖** តើអ្នកណាជាអ្នកសម្លាប់ហ្នឹង? ជាអ្នកមកពីស្រុក ជាអ្នកមកពីតំបន់ ឬអ្នកណាជាអ្នកដែលលោកថា យកមកៗសម្លាប់នោះ?

**ឆ៖** អានេះ វាមិនដឹងអ្នកណាទេណាទាន ប៉ុន្តែតែកាលណាអ៊ីចឹង គេចាប់យកទៅដាក់សន្តិសុខ តែដាក់សន្តិសុខ វាមិនដែលឃើញ -- វាតិចណាស់អ្នករួចមកវិញនោះ។

**ស៖** តើមន្ទីរសន្តិសុខហ្នឹងជាៗកន្លែងអីដែរ? ជាៗវត្តចាស់ ឬក៏ជាកន្លែងអី?

**ឆ៖** មន្ទីរសន្តិសុខហ្នឹងដែលក្រោយពេលដែលគេឲ្យលោកផ្សឹកអស់ទៅ គេយកកន្លែងហ្នឹងឯងយកវត្តធ្វើកន្លែងសន្តិសុខ។

**ស៖** នៅក្នុងចម្លើយដែលខ្ញុំអានអម្បាញ់មិញនេះ គឺមានពាក្យមួយដែលខ្ញុំចាប់អារម្មណ៍ ហើយខ្ញុំចង់បានការពន្យល់ពីលោកៗឆ្លើយថា "ជួនកាលការងារមិនចប់តាមផែនការ ហើយថ្នាក់លើចោទថ្នាក់ក្រោមថាក្បត់។" នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើនៅពេលដែលគេចោទថាជាអ្នក -- ជាជនក្បត់ ឬជាខ្មាំងនោះ តើគេមានហេតុផលអីខ្លះ? ឧទាហរណ៍ដូចថានៅពេលដែលយើងរែកដី មិនគ្រប់គ្រាន់អីអ៊ីចឹង តើគេចោទយើងថាជាខ្មាំងដែរទេ?

**ឆ៖** បើគេធ្វើបានហើយ យើងធ្វើមិនបាន ពិបាកណាស់ទាន គេចោទយើងថាខ្មាំង ជួនកាលគេយកប្រធានហ្នឹងទៅ។

**ស៖** សូមអរគុណ។ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សំដៅទៅលើពាក្យ “ខ្មាំង” អ្នកដែលមិនសម្រេចបានតាមផែនការ អ្នកដែលរែកដីមិនបានតាមផែនការហ្នឹង តើគេអាចចាត់ទុកថាជាខ្មាំងទេ?

**ឆ៖** ទាន តាមគេនិយាយគេថា អាហ្នឹងវាចូលខ្មាំងសន្តិសម្ព័ន្ធ សន្តិអីគេណា ខ្មាំងបង្កប់ គេថាយើងឲ្យស្មុះចលនា។

[១១:៣១:២៥]

**ស៖** ខ្ញុំនៅសល់ប៉ុន្មាននាទីទៀតទេមុនពេលសម្រាក។ ឥឡូវនេះខ្ញុំចង់សួរលោកថា តើមានហេតុការណ៍អ្វីកើតឡើងទេ លោកដឹងទេនៅហ្នឹងថាមានហេតុការណ៍អ្វីដែលធ្វើឲ្យមានអ្នកកម្មករស្លាប់ទេ អាចមានគ្រោះថ្នាក់អ្វីកើតឡើងទេ នៅពេលដែលសាងសង់ទំនប់នោះ ហើយមានអាចបណ្តាលឲ្យកម្មករស្លាប់ទេ?

**ឆ៖** កងខ្ញុំដែលធ្វើនោះមិនមានទេ ដែលគេយកទៅនៅពេលដែលធ្វើ តែវាច្រើនបាក់ដីសង្កិនងាប់។

**ស៖** ដូច្នេះ គឺមានកម្មករស្លាប់នៅពេលដែលបាក់ដី ហើយដីហ្នឹងសង្កត់លើមនុស្សដែលរស់ហ្នឹង ដែលបណ្តាលឲ្យស្លាប់ អ៊ីចឹងមែនទេ?

**ឆ៖** បាទទាន អ៊ីចឹងហើយ ព្រោះអានេះមនុស្សវាចង់ឈ្នះគ្នាក៏កាយទៅ ក៏ចាក់ពីដែកស្បែងពីលើទៅ ក៏គាស់ទៅ។ ក៏ប៉ុន្តែដល់មិនបានគាស់ មិនបានគាស់ មនុស្សវាអន់ យប់ធ្វើការយប់ វាអន់វាទៅជ្រកហ្នឹង ហើយមិនដឹងអាដីពីលើ ដល់តែជ្រកៗទៅ អាដីហ្នឹងបាក់មកសង្កិនងាប់ទៅ មិនដឹងធ្វើម៉េច។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ អ៊ីចឹងអ្នកដែលស្លាប់ហ្នឹងត្រូវ -- គឺបានន័យថាគាត់ស្លាប់ គាត់កប់ដីទាំងរស់អ៊ីចឹងមែនទេ? ហើយនៅពេលដែលគាត់ស្លាប់ទៅ តើគ្រួសារគាត់ ឬក៏សមាជិកគ្រួសារហ្នឹងមានទទួលបានការសង ឬក៏ការប៉ះប៉ូវអ្វីដែរឬទេ?

**ឆ៖** កាលអ្នកធ្វើការនឹងបាក់ដីសង្កិនស្លាប់ទៅ វាគ្មានប៉ះប៉ូវអីទេទាន គ្មានប៉ះប៉ូវអង្ករ១គីឡូ ២គីឡូអីទេ គ្មានទេ បើស្លាប់នោះស្លាប់ទៅហើយ។ អ៊ីចឹងវាគ្មានអីសង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោក ឱ ហូ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះ

ប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះនៅរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយ និងសាមសិបនាទីរសៀល។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅបន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនេះនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ។

*(សវនាការសម្រាកពីម៉ោង ១១:៣៤នាទី ដល់ម៉ោង ១៣:៣០នាទី)*

[១៣:៣០:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយសូមបញ្ជាក់សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺមានរយៈពេលមួយវគ្គសវនាការនៅរសៀលនេះទៀត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី តើលោកសាក្សីអាចប្រាប់បានទេថាតើវាមានចម្ងាយប្រហែលប៉ុន្មានដែរ ពីភ្នំពេញទៅការដ្ឋានសាងសង់ទំនប់១មករា? តើលោកអាចប៉ាន់ប្រមាណថា តើមានចម្ងាយជាប្រហែលប៉ុន្មានគីឡូម៉ែត្រ ឬក៏ថាបើកឡានវិញតើត្រូវអស់ប៉ុន្មានម៉ោងដែរ? តើលោកអាចប្រាប់ខ្ញុំបានទេ ពីភ្នំពេញទៅទំនប់១មករា?

**លោក ឱ ហួរ៖**

**ឆ៖** ពីភ្នំពេញទៅ១មករា វាមានចម្ងាយប្រហែលជា១១៥គីឡូ ខ្ញុំស្មានទេ ប៉ុន្តែបើខ្វះៗតិច បើលើសៗតិច។

**ស៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកដឹងទេថា ត្រូវការពេលប្រហែលប៉ុន្មាន ប្រសិនបើយើងធ្វើដំណើរតាមរថយន្តពីភ្នំពេញទៅទំនប់១មករា?

**ឆ៖** សព្វថ្ងៃបើសិនណាជាយើងទៅ បើផ្លូវវាគេទើបតែធ្វើថ្មីអ៊ីចឹង វាពិបាកដែរ វាមិនទាន់រួច វាអាចយូរដែរ តែវាប្រហែលជាខ្ទង់ពីរម៉ោង បីម៉ោង បើបើកឲ្យស្រួល។ បើបើកលឿនដូចកាលមុន ដែលផ្លូវវាស្រួលនោះ ពីរម៉ោង។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់ឃើញមានអ្នកទៅពីភ្នំពេញទៅទស្សនកិច្ចនៅទំនប់១មករាដែរឬទេ?

**ឆ៖** អ្នកទៅទស្សនកិច្ចមានដែរទាន មាន។ សម្បូរខាងចិន កូរ៉េ គេទៅ ប៉ុនបើប្រជាជនមិនសូវមានទេទាន។

[១៣:៣៤:០២]

**ស៖** លោកសាក្សី ថាតើលោកធ្លាប់ឃើញគេថតខ្សែភាពយន្ត ឬក៏ថតវីដេអូនៅការដ្ឋានទំនប់នោះដែរឬទេ នៅពេលនោះ?

**ឆ៖** អង្កាល់ដែលគេបើកការដ្ឋានដំបូងដៃ គេថតដែរលោក គេថតដាក់ធ្វើជាវីដេអូ ធ្វើជាកុនដែលឲ្យប្រជាជនរែកដីទៅ គេថត។

**ស៖** លោកបានប្រាប់យើងរួចទៅហើយ ដែលថាមានម្តងនុ៎ង កែ ពក ប្រាប់ថាអង្គការមកធ្វើទស្សនកិច្ចនៅទំនប់។ តើលោកចាំទេ ថាមានពេលផ្សេងទៀត ដែលមេដឹកនាំមកពីភ្នំពេញហ្នឹង គាត់ទៅធ្វើទស្សនកិច្ចនៅទំនប់១មករានុ៎ងទេ?

**ឆ៖** ខ្ញុំមិនចាំទេទាន ព្រោះដែលគេមកខ្ញុំស្គាល់គេមិនអស់ ជួនកាលគេប្រាប់ទៅក៏វាមិនទៀងៗនៅត្រង់មិនស្គាល់តែម្តង។ អ្នកប្រាប់ក៏មិនស្គាល់ខ្ញុំ ខ្ញុំក៏មិនអាចឆ្លើយបានទេទាន។

**ស៖** សូមអរគុណលោកសាក្សី ដែលលោកបានផ្តល់ចម្លើយដ៏ច្បាស់ ហើយក្បោះក្បាយបែបនេះ។ មុនពេលដែលមានការថតភាពយន្តអំពីការសម្ពោធ ឬក៏ការថតភាពយន្តអំពីជនបរទេស តើគេមានណែនាំលោកត្រូវធ្វើយ៉ាងម៉េចជាមួយអ្នកដែលទៅទស្សនកិច្ចនៅទីនោះទេ?

**ឆ៖** ខ្ញុំបាទ មិនដឹងទេទាន។ ប៉ុន្តែគ្រាន់តែថា បើគេមកថត គេឲ្យយើងសម្រុករែកដី រត់ទៅ មេក្រុមដែលធ្វើការហ្នឹងនាំមុខគេទៅ រត់ រែករត់ទៅ កុំឈប់។

[១៣:៣៦:៣៩]

**ស៖** សូមអរគុណ។ ប្រសិនបើខ្ញុំមានពេល ខ្ញុំនឹងបង្ហាញឯកសារមួយ ប៉ុន្តែមិនប្រាកដ។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើចំណុចមួយចំនួនដែលលោកបាននិយាយនៅក្នុងកិច្ចសម្ភាសន៍ឆ្នាំ២០០៨របស់លោក។ ទី១ គឺនៅទំព័រទី៤, ទី៥ ភាសាបារាំង ខ្មែរមានលេខ 00239909 នៅក្នុងចម្លើយគឺលោកឆ្លើយថា "វុត ធ្លាប់ប្រាប់ខ្ញុំថា -- វុត ធ្លាប់ប្រាប់ខ្ញុំថា បើសិនជានរណាខ្ជិលច្រអូស ត្រូវរាយការណ៍ទៅថ្នាក់លើ។ ដូចជាថា គ្រុនញាក់ គ្រុនញ័រ គ្រុនត្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនសតិអារម្មណ៍"។ តើលោកអាចពន្យល់បានទេ ថាតើ វុត ប្រាប់លោកថាយ៉ាងម៉េចដែរ ទាក់ទងនឹងពាក្យថា "គ្រុនញាក់ គ្រុនញ័រ គ្រុនត្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនសតិអារម្មណ៍" ហ្នឹង?

**ឆ៖** នេះជាការដែលគេតែងតែប្រជុំនិយាយអ៊ីចឹងឯង។ អ្នកណាមានសតិអារម្មណ៍ខ្ជិល ឬក៏គេច គេថាវា "គ្រុនអាត្រាក់ទ័រ គ្រុនឡាន" អ៊ីចឹងមែនទាន។ ថាអ៊ីចឹងមែន។

**ស៖** តើមានន័យថាយ៉ាងម៉េចដែរ នៅពេលដែលនិយាយថា "គ្រុនឡាន គ្រុនត្រាក់ទ័រ" ហ្នឹងតើគាត់ហ្នឹងគ្រុនក្តៅខ្លួនខ្លាំង ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** មនុស្សអង្គាល់នុំងគ្នាឈឺមែន គ្នាឈឺមែន ប៉ុន្តែអ្នកថាចេះតែថាទៅ។ ចេះតែថាដោយការមិនពេញចិត្ត ដោយគំនិតរបស់ខ្លួនអាម៉េចៗខ្ញុំមិនអាចដឹងទេណា ប៉ុន្តែថាគ្នាខ្ជិល ថាគ្នាច្រអូសអ៊ីចឹងទៅ។ គេហៅថា "គ្រុនអាត្រាក់ទ័រ" ហើយគេឲ្យរាយការណ៍ អ្នកណារាយការណ៍ទៅក៏ខុសទៅ បើយើងមិនរាយការណ៍វាល្អជាងរាយការណ៍។

[១៣:៣៩:៤៨]

**ស៖** សូមអរគុណដែលបញ្ជាក់ទៅលើចំណុចនេះ ហើយនៅទំព័របន្ទាប់ទៀត លោកបានឆ្លើយថា គឺទំព័រអង់គ្លេសជាភាសាអង់គ្លេសទំព័រលេខ៥ បារាំងក៏លេខ៥ ហើយខ្មែរមានលេខ 00239910។ លោកបាននិយាយថា ដោយសារតែមិនមានអាហារគ្រប់គ្រាន់ ប្រជាជន -- ដោយសារតែមិនមានអាហារគ្រប់គ្រាន់ ប្រជាជនគឺមានជំងឺ ហើយមានបញ្ហាសុខភាព គ្មានអនាម័យ។ ហើយលោកបានរៀបរាប់ពីកន្លែងដែលប្រជាជន "គឺថាពួកគេស្នាក់នៅក្បែរទំនប់តែម្តង បុរស ស្ត្រីដេកដាច់ពីគ្នា ហើយពួកគេរស់នៅគ្មានអនាម័យខ្វះបង្គន់អនាម័យ ហើយគ្មានសាប៊ូប្រើប្រាស់ ហើយពួកគេងូតទឹកនៅស្ទឹងជីនិត"។ តើលោកអាចពន្យល់បានទេថាតើលក្ខខណ្ឌអនាម័យនៅកន្លែងការដ្ឋានហ្នឹងវាមានលក្ខណៈបែបណាដែរ?

**ឆ៖** នៅក្នុងការដ្ឋាននោះវាគ្មានអនាម័យទេទាន មួយសម័យនោះគ្មានទេ ងូតទឹកពីលើពីក្រោម ហើយការបត់ជើងតូចធំហ្នឹងវាបង្គន់ៗជីកមែន ជីកអនាម័យមែន ប៉ុន្តែដល់ជុះទៅវាពេញទាំងព្រៃហ្នឹង

ហើយម៉្លោះហើយរុយ បើខៀវប៉ុនដូចថាសឹងតែប៉ុនចង្កឹះ។ ពេលហូបបាយម្តងៗ បើមិនយករុយបក់ទេ អាចម៍រុយពេញតែម្ហូបហ្នឹង។ វាអត់អនាម័យទេ។

[១៣:៤១:៥៨]

**ស៖** តើប្រជាជនមានទទួលបានមុងសម្រាប់សម្រាកដែរឬទេ?

**ឆ៖** គ្មានទេទាន គ្មាន។

**ស៖** តើប្រជាជនមានស្បែកជើងពាក់ទេ នៅពេលនោះ?

**ឆ៖** ស្បែកជើងមានទាន ស្បែកជើងកង់ឡានយើង អាឡានដែលវាដែលនេះទៅ យើងចៀរធ្វើស្បែកជើងពាក់ទៅពេលនោះ។

**ស៖** លោកបាននិយាយអំពីការប្រជុំដែលគេជជែកគ្នាអំពីប្រជាជនដែលខ្ជិលច្រអូសនោះ។ ថាតើការប្រជុំហ្នឹង ប្រជុំតែជាមួយលោកដែលជាមេភូមិ ឬមួយក៏ជាការប្រជុំជាមួយនឹងកម្មករប្រជាជនទូទៅ ដើម្បីពួកគាត់ចូលរួមដែរ?

**ឆ៖** ប្រជុំនេះគឺមិនប្រជុំសម្ងាត់ទេទានទាំងអស់គ្នា ឲ្យឮទាំងអស់គ្នា។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំនិយាយអំពី -- មិនមែននិយាយអំពីមេទេ ខ្ញុំនិយាយអំពីកម្មករ។ ថាតើប្រជាជន ឬក៏កម្មករហ្នឹងត្រូវចូលរួមវគ្គរៀនសូត្រជីវភាព ឬក៏រៀនសូត្រមនោគមន៍វិជ្ជាជាទូទៅអំពីខ្មែរក្រហមដែរឬទេ?

[១៣:៤៣:៤១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការជំទាស់ ដោយសារតែខ្ញុំមិនច្បាស់។ ថាតើសំណួរហ្នឹងគាត់មានគោលដៅអ្វី? ព្រោះថាសំណួរនិយាយអំពីមនុស្ស២០នាក់ ដែលស្ថិតនៅក្រោមការគ្រប់គ្រប់របស់គាត់ ឬមួយក៏គាត់ចង់សួរអំពីស្ថានភាពរបស់កម្មករ២០.០០០-៣០.០០០នាក់នោះ។ ព្រោះថាសាក្សីគាត់អត់អាចផ្តល់សក្ខីកម្មអំពីអ្វីដែលជាទូទៅនោះទេ ដូច្នេះខ្ញុំគិតថា សំណួររបស់ព្រះរាជអាជ្ញាគឺហាក់ដូចជាសួរអំពីមនុស្ស២០-៣០នាក់ដែលនៅក្រោមការគ្រប់គ្រងរបស់សាក្សីប៉ុណ្ណោះ។ ប្រសិនបើ

មិនសួរអំពី២០នាក់ហ្នឹងទេ គឺថាពេលនោះសាក្សីគាត់នឹងឈានទៅដល់ការទាយស្មានហើយ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំសូមធ្វើការឆ្លើយតប។ គឺថា ខ្ញុំអាចបំបែកសំណួរនេះដើម្បីសួរឲ្យបានច្បាស់ ប៉ុន្តែគាត់យល់ច្បាស់អំពីក្រុមរបស់គាត់។ ដូច្នេះ ខ្ញុំសូមចាប់ផ្តើមជាមួយក្រុមដែលលោកសាក្សីគាត់ជាអ្នកត្រួតពិនិត្យមើល។

[១៣:៤៥:០២]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកឆ្លើយនៅពេលនេះ នៅថ្ងៃនេះថាមានមនុស្សប្រហែលជា១០០នាក់ក្រោមការគ្រប់គ្រងរបស់លោក។ ដូច្នេះខ្ញុំចង់ថា តើមនុស្ស១០០នាក់ដែលក្រោមការគ្រប់គ្រងរបស់លោកហ្នឹងចូលរួមក្នុងការប្រជុំនយោបាយដែលនិយាយអំពីមនោគមន៍វិជ្ជារបស់ខ្មែរក្រហមដែរឬទេ?

**លោក ឱ ហួ៖**

**ឆ៖** គាត់បានទៅប្រជុំដែរទាន ប្រជុំដែលពួកអង្គការគាត់មកពីខាងលើមកហ្នឹង ពីខាងសង្កាត់មក គាត់ប្រជុំណែនាំ។

**ស៖** ដូច្នេះអ្នកដែលមកពីថ្នាក់ឃុំ គេមកបង្រៀន។ តើអ៊ីចឹងមែនទេ?

**ឆ៖** មិនមែនបង្រៀនជារបៀបសាលាទេ បង្រៀនមកប្រជុំរបៀបពន្យល់។

**ស៖** តើអ្នកពីឃុំហ្នឹង គេពន្យល់អ្វីដែរ?

**ឆ៖** ពន្យល់ៗពីរឿងធ្វើការងារហ្នឹងឯងទាន ឲ្យប្រឹងធ្វើដើម្បីប្រឡាយទៅ យើងនឹងធ្វើស្រែ។ គាត់ពន្យល់ណែនាំអំពីការធ្វើប្រឡាយហ្នឹង បើកាលណាធ្វើខំធ្វើទៅវាឆាប់បានប្រឡាយ នឹងបានធ្វើស្រែបានច្រើន។

[១៣:៤៦:៥៨]

**ស៖** តើការប្រជុំហ្នឹង ប្រជុំតែក្នុងក្រុមរបស់លោក ឬក្រុមផ្សេងៗទៀតដែលធ្វើការនៅទំនប់១មករាដែរ? បើសិនជាលោកដឹង សូមប្រាប់ បើលោកអត់ដឹងទេ ប្រាប់ខ្ញុំថាអត់ដឹងទៅ។

**ឆ៖** ទាន ខ្ញុំមិនច្បាស់ទេទាន មិនដឹងទេ ការងារហ្នឹង។ ខ្ញុំដឹងតែក្នុងក្រុមខ្ញុំទេ។

**ស៖** នៅពេលដែលពួកគេពិភាក្សាអំពីការងារ ថាតើថ្នាក់តំបន់ គេមាននិយាយអំពីបញ្ហាខ្មាំងដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលទៅជួបនឹងតំបន់ផង មិនដែលបានជួបពួកគាត់ទេ។

**ស៖** ខ្ញុំចង់សួរលោក លោកនិយាយថាថ្នាក់ឃុំមកនិយាយពន្យល់ទៅដល់ប្រជាជន។ ថាតើថ្នាក់ឃុំហ្នឹងបាននិយាយអំពីបញ្ហាស្វែងរកខ្មាំងនៅក្នុងចំណោមជួរប្រជាជនដែរឬទេ?

**ឆ៖** គាត់និយាយដែរទាន គាត់និយាយថាខ្មាំងត្រូវតែយកចេញ ព្រោះកាលណាយើងធ្វើក្តៅទៅដង្កូវវាចេញពីសាច់ហើយ ឆ្កឹះវាចេញម្តងមួយៗ។

**ស៖** លោកសាក្សី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើនៅក្នុងភូមិរបស់លោកមានការរៀបអាពាហ៍ពិពាហ៍ដែរឬទេ?

**ឆ៖** មានដែរទាន ដែលចុងឆ្នាំ១៩៧៧ មានរៀបអាពាហ៍ពិពាហ៍ដែរ។

**ស៖** សូមអរគុណ។ ចាប់ពីដើម -- ចាប់ពីឆ្នាំ៧៥ ដល់ចុងឆ្នាំ៧៧ តើគេហាមឃាត់មិនឱ្យរៀបការអ៊ីចឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៣:៤៩:៥៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានបញ្ហាទាក់ទងទៅនឹងការសួរអំពីការរៀបអាពាហ៍ពិពាហ៍ ព្រោះគាត់ជាសាក្សីថ្មីនៅក្នុងផ្នែកថ្មីនេះ។ គាត់និយាយអំពីទំនប់១មករា ហើយគាត់មានតួនាទីនៅក្នុងការកសាងទំនប់ ដែលគាត់មាន ដូចជាប្រធានកងមានប្រជាជនប្រហែលជា២០នាក់។ ខ្ញុំគិតថាការសួរពីប្រវត្តិមិនមានបញ្ហាអ្វីនោះទេ អំពីតួនាទីគាត់ក៏មិនអីដែរ។ ប៉ុន្តែឥឡូវនេះ យើងបែរជាងាកមកសួរអំពីការគ្រប់គ្រង ការចាត់ចែងទៅលើការរៀបការ ហើយនិងសួរអំពីអ្វីដែលកើតឡើងនៅក្នុងភូមិរបស់គាត់។ ដូច្នេះខ្ញុំគិតថាដូចជាមិនដឹងថាតើវាមានមូលហេតុអ្វី ឬក៏មានគោលដៅអ្វីដែលត្រូវធ្វើបែបនេះទេ ព្រោះធ្វើបែបនេះ វាហាក់ដូចជាការបើកចំហទៅដល់មូលដ្ឋាន ទៅដល់ចំណុចថ្មីនៃប្រធានបទ។ ព្រោះថាយើងអាចនិយាយអំពីទំនប់១មករា និយាយអំពីតួនាទីរបស់គាត់ ប្រាកដណាស់ ការសួរបែបនេះវាស្ថិតនៅក្នុងវិសាលភាព ប៉ុន្តែខ្ញុំគិតថាវាជាការសមស្របជាង ប្រសិនបើយើងផ្តោតទៅលើតែផ្នែកនេះ គឺ

ផ្តោតទៅលើសក្ខីកម្មរបស់គាត់ តែទៅលើផ្នែកនេះ។ ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតឲ្យសួរទៅលើវិសាលភាពផ្សេងៗទៀត ខ្ញុំគិតខ្ញុំក៏នឹងធ្វើដូច្នេះដែរ ហើយវាជាការចំណាយពេលទៅលើផ្នែកផ្សេងៗទៀតផងដែរ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថាអង្គជំនុំជម្រះអាចបញ្ជាក់ឲ្យបានច្បាស់ ដែលថាសាក្សីគឺគាត់អាចសាកសួរ -- យើងអាចសាកសួរបានអំពីចំណុចជាច្រើន ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់ហើយ។ ដូចជាថា គាត់ធ្លាប់និយាយថា គាត់ធ្លាប់រៀបចំអាពាហ៍ពិពាហ៍នៅក្នុងភូមិរបស់គាត់។ ដូច្នេះ ខ្ញុំគិតថាវាមិនមានបញ្ហាអ្វីទេ ប្រសិនបើមេធាវីការពារក្តី គាត់ចង់និយាយអំពីគោលនយោបាយរៀបអាពាហ៍ពិពាហ៍ផងដែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥២:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះអាចសួរបាន សូមព្រះរាជអាជ្ញាបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ឥឡូវនេះ ខ្ញុំសូមធ្វើការដកស្រង់ចេញពីកិច្ចសម្ភាសន៍ឆ្នាំ២០០៨របស់លោក គឺខ្មែរមានលេខ 00239911 គឺទំព័រទី៦ជាភាសាអង់គ្លេស និងភាសាបារាំង គឺអង់គ្លេសទំព័រ៦ បារាំងទំព័រ៧។ លោកបាននិយាយថា គេសួរលោកអំពីការរៀបការ ហើយលោកនិយាយថា៖ “ចាប់តាំងពីឆ្នាំ៧៥ ដល់ឆ្នាំ១៩៧៧ នៅក្នុងឃុំរបស់ខ្ញុំគេមិនអនុញ្ញាតឲ្យមានការរៀបការទេ តែចាប់ពីខែកញ្ញា ឆ្នាំ៧៧ទៅ ទើបគេអនុញ្ញាតឲ្យមានការរៀបការ។ ប្រធានភូមិជាអ្នករៀបចំឲ្យបុរសនៅក្នុងភូមិរៀបការជាមួយស្ត្រីដែលនៅក្នុងភូមិជាមួយគ្នា ព្រោះខ្លាចស្ត្រីនៅក្នុងភូមិរបស់ខ្លួននៅសល់។ ខ្ញុំធ្លាប់បានចាត់ចែងរៀបការឲ្យពួកគេ ជួនកាលរៀបការម្តងៗមានប្រហែល៣០ទៅ៤០គូ”។ ដូច្នេះ លោកសាក្សីថា តើអ្វីដែលលោកបានប្រាប់អ្នកស៊ើបអង្កេតនៅក្នុងឆ្នាំ២០០៨ គឺជាចម្លើយដែលត្រឹមត្រូវ គឺជាការរៀបរាប់អំពីការគោលនយោបាយរៀបអាពាហ៍ពិពាហ៍នៅក្នុងឃុំរបស់លោកនៅសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១៣:៥៤:២០]

**លោក ឱ ហួ៖**

**ឆ៖** ត្រូវហើយលោកមេ -- លោកអ៊ីចឹង។

**ស៖** នៅពេលគេអនុញ្ញាតឲ្យរៀបការ លោកបានបញ្ជាក់ថាជួនកាលរៀបការម្ដងៗមានប្រហែល៣០ ទៅ៤០គូ ថាតើអ្នកណាជាអ្នករៀបចំការរៀបការនោះ?

**ឆ៖** ការរៀបការហ្នឹង គឺខាងឃុំ គេមកឈរជាឪពុកម្ដាយ។ ភូមិគ្រាន់តែនាំឲ្យគេទេ ប៉ុន្តែក្នុងស្ត្រីដែលនៅក្នុងភូមិយើង យើងឲ្យបុរសនៅក្នុងភូមិយើងហ្នឹង ដែលគាត់ត្រូវរ៉ូវគ្នាដូចថា គាត់ពេញចិត្តនឹងគ្នា តែយើងប្រើពាក្យថា "ការចាត់តាំងរបស់អង្គការ"។

**ស៖** លោកសាក្សី តើគោលនយោបាយរបស់អង្គការទាក់ទងទៅនឹងការរៀបការមានលក្ខណៈយ៉ាងដូចម្ដេចដែរ? តើមានគោលនយោបាយហាមឃាត់មិនឲ្យមានការរៀបការដែរឬទេ?

**ឆ៖** វាមិនទាន់ចប់សង្គ្រាម អង្គការមិនឲ្យរៀបការទេ ព្រោះត្រូវការយុទ្ធជន យុទ្ធនារីទៅច្បាំង។ ដល់ពេលដាច់ហើយ រៀបការដែរ តែរៀបការអ្នកពិការ ឯប្រជាជននៅតាមភូមិមិនទាន់បានរៀបការទេ។

**ស៖** ថាតើអ្នកណាជាអ្នកជ្រើសរើស? ថាតើអ្នកណាជាអ្នកសម្រេចថា បុរសនេះត្រូវរៀបការជាមួយនារីនោះ? ហើយតើគេមានលក្ខណៈអ្វីដែរក្នុងការជ្រើសរើសគូនោះ?

**ឆ៖** នៅភូមិគេដទៃ ខ្ញុំបាទមិនដឹងទេណា៎ ប៉ុន្តែបើនៅក្នុងភូមិខ្ញុំ បុរសនោះគ្នាប្រាប់ ថាខ្ញុំស្រឡាញ់នារីនោះ ឬនារីប្រាប់ថា ខ្ញុំស្រឡាញ់បុរសនោះ។ ហ្នឹងត្រូវការរាយការណ៍ទៅខាងលើ ឲ្យគេមករៀបចំឲ្យ។

[១៣:៥៧:៣៣]

**ស៖** នៅពេលដែលលោករាយការណ៍អំពីគូដែលគ្រោងនឹងរៀបការទៅថ្នាក់លើនោះ តើថ្នាក់លើ -- តើលោកចាំបាច់ត្រូវទទួលការអនុម័តយល់ព្រមពីថ្នាក់លើ ទើបពួកគេអាចរៀបការបានឬទេ?

**ឆ៖** បើខាងលើនោះ គេទទួលរ៉ៃ ប្រវត្តិរូបពីយើងហើយ គេកំណត់កន្លែងរៀបការហើយទាន។

**ស៖** ដោយសារខ្ញុំជិតអស់ពេលហើយ ដូច្នេះខ្ញុំសូមបន្តទៅមុខទៀត។ ខ្ញុំសួរលោកទៅលើចម្លើយមួយទៀតទាក់ទងទៅនឹងសំណួរដែលលោកផ្ដល់នៅក្នុងទំព័រ៥ ភាសាបារាំង និងអង់គ្លេស ខ្មែរមានលេខ 00239909។ អ្នកស៊ើបអង្កេតបានសួរលោក៖ "ថាតើលោកបានឃើញមានការចាប់មនុស្សដោយផ្ទាល់ភ្នែកទេ?" ហើយលោកបានឆ្លើយថា៖ "បាទ ខ្ញុំឃើញ ប៉ុន្តែខ្ញុំមិនអាចធ្វើអ្វីបានទេ ព្រោះការ

ចាប់នេះ ដូចជាបំបាក់ស្មារតីអ្នកផ្សេងទៀត។ អ្នកដែលគេចាប់យកទៅបាត់នោះមានជាច្រើននាក់ តែខ្ញុំមិនចាំឈ្មោះទេ។ ក្រោយមកទៀតឈ្មោះ ប៊ិន និងឈ្មោះ វុត ត្រូវបានគេចាប់យកទៅវត្តបារាយណ៍ជាន់ដែក ហើយអ្នកទាំងនោះមិនឃើញត្រឡប់មកវិញទេ។ ខ្ញុំដឹង ដោយសារខ្ញុំស្គាល់មុខសន្តិសុខ ដែលជាអ្នកធ្វើការនៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក។" ហើយពីរបីជួរខាងក្រោម លោកបាននិយាយថា៖ "គាត់គឺ សមមិត្តម៉ៅ (ស្លាប់ចុងឆ្នាំ១៩៧៧ ដោយសារគេសម្លាប់)។" លោកសាក្សី អ្នកដែលត្រូវបានគេចាប់ខ្លួននោះ គឺស្ថិតនៅក្នុងជួរមេដឹកនាំ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនទាន។

[១៤:០០:០៨]

**ស៖** តើគេចាប់ ប៊ិន ហើយនិង វុត ហ្នឹង ដោយសារហេតុផលអ្វី? ហើយចុះសមមិត្ត ម៉ៅ ហ្នឹង គេចាប់ដោយសារហេតុផលអ្វីដែរ លោកដឹងទេ?

**ឆ៖** ខ្ញុំមិនដឹងទេទាន ព្រោះការងារហ្នឹងវាធំហួសខ្ញុំដឹងទៅហើយ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក ក៏លោកនិយាយថា ប្រធានភូមិភាគ៤០ បាននិយាយថា ឈ្មោះ ចាន់ បានប្រកាសថាស្លាប់ ហើយស្លាប់នៅឆ្នាំ២០០៨។ ហើយឈ្មោះ ស៊ីម គឺជាគណៈតំបន់ ហើយគណៈតំបន់ហ្នឹងក៏ស្លាប់ទៀត ហើយឃុំបល្ល័ង្កគឺឈ្មោះ ប៊ិន ដែលយើងកំពុងតែពិភាក្សាហ្នឹង ទាំងអស់គ្នាហ្នឹងសុទ្ធតែស្លាប់ហើយ។ ហើយលោកនិយាយថា ពួកស្លាប់ ប៉ុន្តែលោកចង់ប្រាប់ ថាតើគាត់ស្លាប់ហ្នឹង ស្លាប់ដោយសារអ្វី? ស្លាប់ដោយសារបាត់ខ្លួន ឬក៏ដោយសារអ្វីដែរ លោកអាចប្រាប់បានទេ?

**ឆ៖** ដាក់សន្តិសុខទេ។ គេយកទៅសម្លាប់តែម្តង--

**ប្រធានអង្គជំនុំ៖**

លោកឆ្លើយម្តងទៀត។ អំមិញឆ្លើយ មិនទាន់ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ ស្តាប់អត់បានអស់សេចក្តីទេ។

**លោក ឱ ហួ៖**

**ឆ៖** អត់ទោស វានិយាយទៅវាភ្លេចមើលអាក្រហម។ ប៊ិន និង វុត និងមិត្ត ម៉ៅ អីហ្នឹង ដែលស្លាប់ហ្នឹង ស្លាប់ហ្នឹងគេចាប់យកទៅ តែខ្ញុំមិនដឹងទេទាន មិនដឹងថា រឿងអីៗ ខ្ញុំមិនដឹងទេ ព្រោះវាហួសសមត្ថភាពខ្ញុំទៅហើយ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំព្យាយាមលើកយកប្រធានបទមួយទៀតដោយសង្ខេប នៅទំព័រទី៦ ភាសាអង់គ្លេសរបស់លោក ភាសាអង់គ្លេស -- ភាសាបារាំងលេខ៧ និងខ្មែរមានលេខ 00239911។ គេសួរអំពីជនជាតិចាម នៅក្នុងតំបន់របស់លោក។ មុននឹងខ្ញុំអានចម្លើយរបស់លោក ខ្ញុំចង់សួរលោកថា តើនៅក្នុងខេត្តកំពង់ធំ មានសហគមន៍ជនជាតិចាមធំរស់នៅដែរឬទេ មុនពេលដែលខ្មែរក្រហមចូលមកកាន់នោះ?

[១៤:០៣:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ ព្រោះគាត់សួរឱ្យសាក្សីធ្វើការទាយស្មាន។ គាត់អាចសួរសាក្សីឱ្យឆ្លើយអំពីអ្វីនៅក្នុងភូមិរបស់គាត់ ប៉ុន្តែគាត់មិនអាចដឹងអំពីអ្វីកើតឡើងនៅក្នុងខេត្តកំពង់ធំ ឬក៏ប្រជាជនកំពង់ធំទាំងអស់នោះទេ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំគិតថា សាក្សីគាត់អាចដឹងច្រើនអំពីអ្វីដែលកើតឡើងចំពោះប្រជាជននៅក្នុងខេត្តរបស់គាត់។ ដូច្នេះ យើង -- គេអាចសួរខ្ញុំបានអំពីអ្វីដែលកើតឡើងនៅក្នុងប្រទេសខ្ញុំ អំពីជនជាតិភាគតិចនៅក្នុងប្រទេសខ្ញុំ។ ដូច្នេះ ខេត្តកំពង់ធំ គឺជាខេត្តរបស់គាត់ ហើយគាត់រស់នៅក្នុងខេត្តកំពង់ធំពេញមួយជីវិតរបស់គាត់។ ដូច្នេះ ប្រសិនបើសាក្សីគាត់ដឹង គាត់អាចប្រាប់ បើថាមិនដឹងទេ ក៏ប្រាប់ថាមិនដឹង វាជារឿងធម្មតា។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី ហើយអង្គជំនុំជម្រះត្រូវការស្ដាប់ចម្លើយតបរបស់សាក្សី ចំពោះសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ។ សាក្សីឆ្លើយតបនឹងសំណួរ បើសិនជាសាក្សីចាំនូវសំណួរដែលបានសួរដោយអម្បាញ់មិញនេះ ដោយសារសហព្រះរាជអាជ្ញាអន្តរជាតិ។

[១៤:០៤:២៦]

**លោក ឱ ហួ៖**

**ឆ៖** ខ្ញុំចាំមិនអស់ទេទាន ព្រោះនៅកន្លែងហ្នឹង ខ្ញុំចាំតែកន្លែងមួយ គេហៅថា ត្រពាំងឈូក ចាម នៅមួយភូមិ ប៉ុនក្រៅដទៃទៀត ខ្ញុំមិនដឹងទេ វា។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណលោកសាក្សី។ ភូមិដែលលោកបាននិយាយ ថាតើជាភូមិដែលមានប្រជាជនចាមរស់នៅច្រើន អ៊ីចឹងមែនទេ?

**ឆ៖** ភូមិត្រពាំងឈូក ដែលខ្ញុំពិនិត្យមើល វាប្រហែលជា អង្កាល់នោះប្រជាជនប្រហែលជា ១០០ ទៅ១៥០គ្រួសារប៉ុណ្ណោះទេ ទាន។ វាបីភូមិ។

**ស៖** តើក្នុងភូមិហ្នឹងមានប្រជាជនចាមច្រើនទេ? តើលោកអាចប៉ាន់ប្រមាណថាតើមានប្រជាជនចាមប៉ុន្មាននាក់ដែរ ប៉ុន្មានគ្រួសារ ប៉ុន្មាននាក់ដែរ នៅក្នុងភូមិនោះ?

**ឆ៖** ខ្ញុំមិនដឹងទេទាន វាស្មានពិបាកស្មានណាស់ ព្រោះនៅវាឆ្ងាយគ្នាដែរ ប្រហែលជា៤-១០គីឡូពីគ្នាទៅហើយ ខ្ញុំមិនដឹង។ ប៉ុន្តែដឹងថា ចាមនៅហ្នឹងវាបីភូមិដែរទេ។

**ស៖** ថាតើប្រជាជនចាមគាត់តើរបៀបស្លៀកពាក់របស់ជនជាតិចាមខុសពីប្រជាជនទូទៅដើម្បីធ្វើឲ្យលោកដឹងបានដែរឬទេថា អ្នកណាជាចាម អ្នកណាមិនមែនជាចាមនោះ?

**ឆ៖** បើគាត់មិននិយាយមិនដឹងទេទាន អង្កាល់នោះ។

[១៤:០៦:៣៩]

**ស៖** តើជនជាតិចាមគេនិយាយភាសាផ្ទាល់ខ្លួនរបស់ពួកគេទេ?

**ឆ៖** និយាយ គាត់និយាយភាសាខ្មែរហ្នឹងឯង ប៉ុន្តែចាម តែគាត់និយាយឡើងវាបង្ហួសខុសគ្នាពីខ្មែរទាន អត់ដូចគ្នាទេ យើងដឹងសម្គាល់ថា ចាម។

**ស៖** នៅទំព័រ៦ អង់គ្លេសភាសា, ៧បារាំង និងខ្មែរមានលេខ 00239911 លោកបាននិយាយដូចតទៅនេះ។ ខ្ញុំចង់អានឲ្យលោកស្តាប់ ហើយលោកអាចប្រាប់ខ្ញុំផង។ លោកនិយាយថា ជនជាតិចាមត្រូវបានចាត់ទុកជាប្រជាជនដែលនៅក្រោមប្រជាជន ១៧មេសា ទៅទៀត។ ជនជាតិចាមត្រូវបង្ខំឲ្យហូបសាច់ជ្រូក សាសនាត្រូវបានបំបិទចោល មិនឲ្យគោរពព្រះអ្វីទេ។ ថាតើលោកបានស្តាប់ឮ ឬក៏បានមើលឃើញអ្វីដែលធ្វើឲ្យលោកឆ្លើយជាមួយអ្នកស៊ើបអង្កេតបែបនេះ?

**ឆ៖** ខ្ញុំឃើញថា កាលនោះគាត់គេមិនឲ្យនៅនឹងភូមិរបស់គាត់ទេ។ គេយកទៅដូចជា ប្រជាជន ១៧មេសា ហ្នឹងដែរទាន។ ដាក់ឯនេះបន្តិច ដាក់ឯនោះបន្តិចទៅ ហើយភូមិនេះពីរបីនាក់ ភូមិនោះពីរបីនាក់ទៅ។ ហើយអ្នកណាចេះដំដែកទៅក៏គេស្រឡាញ់រាប់អានទៅ ក៏ប៉ុន្តែការងារដែលគ្នាវាតមសាច់ជ្រូកទៅបង្ខំឲ្យគ្នាស៊ីសាច់ជ្រូកទៅ។ ហើយវាជួនកាលក៏គ្នាមិនស៊ីទេ រកអំបិលស៊ីទៅ ហើយសាសនាទាំង

ឡាយវាអស់ហើយទាន ទាំងចាម ទាំងខ្មែរ គ្មានសាសនាទេ។ សឹកអស់រលីង លោកក៏សឹក ចាមក៏ឈប់ថ្វាយបង្គំ ឈប់អីអស់។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកសាក្សី។ ហើយខ្ញុំសូមបញ្ចប់ការសួររបស់ខ្ញុំ ហើយខាងដើមបណ្តឹងរដ្ឋប្បវេណី គាត់នឹងបន្តការសាកសួរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមការអនុញ្ញាតប្រគល់វេទិកានេះ ជូនសហភាតារបស់ខ្ញុំ គឺលោកមេធាវី ហុង គឹមសួន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១៤:០៩:៣៨]

**លោក ហុង គឹមសួន៖**

បាទ ជាដំបូង ខ្ញុំបាទសូមគោរពលោកប្រធាន លោកស្រី លោកចៅក្រមជំនុំជម្រះជាទីគោរព និងអង្គសវនាការជាទីគោរព។ ខ្ញុំបាទ មេធាវី ហុង គឹមសួន ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី មានសំណួរខ្លះៗបន្ថែមទៅលើសំណួរ ដែលសហព្រះរាជអាជ្ញាបានសាកសួរអម្បាញ់មិញទៅលើសាក្សីដូចតទៅនេះ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សួស្តីលោកសាក្សី! ខ្ញុំសូមសួរទាក់ទងជាមួយនឹងប្រជាជនចាស់ ប្រជាជនថ្មីបន្តិច។ ពីព្រឹកមិញ លោកបានឆ្លើយជាមួយសហព្រះរាជអាជ្ញាហើយ អំពីប្រជាជនចាស់ ឬប្រជាជនថ្មី ប្រជាជនបញ្ញើ។ ខ្ញុំចង់សូមឲ្យលោកបញ្ជាក់ថា តើពាក្យថា "ប្រជាជនពេញសិទ្ធិ, ត្រៀម, ផ្ញើ ឬបញ្ញើ" វាខុសគ្នានឹងប្រជាជនចាស់ ប្រជាជនមូលដ្ឋាន ឬជាប្រជាជន១៧មេសាយ៉ាងម៉េច លោកអាចបញ្ជាក់បន្តិចសិនបានទេ?

**លោក ឱ ហួ៖**

**ឆ៖** សូមជម្រាបប្រសាសន៍លោក ប្រជាជនពេញសិទ្ធិគឺប្រជាជននោះដែលជាប្រជាជនក្រីក្រ ហើយពីដើមឡើយគាត់ខ្វះខាត រកតែអង្ករច្រកគ្មាន ហើយគាត់នៅក្នុងភូមិរបស់យើង។ អាហ្នឹង គេចាត់ទុកថា ជាប្រជាជនពេញសិទ្ធិ។ អ្នកដែលមានរបស់ស៊ីគ្រប់គ្រាន់រហូតមួយឆ្នាំៗ អាហ្នឹង គេហៅថាប្រជាជនត្រៀម។ អ្នកដែលទើបនឹងមកពីភ្នំពេញ និងចាមដែលជម្លៀសពីភូមិគាត់ទៅ គេទុកថាជាប្រជាជនផ្ញើ។

[១៤:១១:៣៦]

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមសួរទាក់ទងជាមួយនឹងការគ្រប់គ្រងក្នុងនាមលោកជាប្រធានភូមិ ដែលលោកបានជម្រាបជូនអង្គសវនាការពីព្រឹកថាលោកជាប្រធានភូមិក្រោយឆ្នាំ១៩៧៥ ហើយលោកបានជម្រាបជូនអំពីថា លោកបាន -- ភូមិរបស់លោកបានទទួលប្រជាជនមកពីភ្នំពេញប្រហែលជា១០០គ្រួសារ ព្រឹកមិញនេះ។ អ៊ីចឹង តើការកំណត់អំពីវណ្ណភាព ឬអ្នកដែលធ្វើការងារ និងកម្មករ ឬពួកនិស្សិត បានដោយប្រភេទណាបាទ?

**ឆ៖** ប្រជាជនដែលមកពីភ្នំពេញ មិនបានរើសថាវណ្ណភាពអីទេ គឺទុកថាជាប្រជាជន១៧មេសាទាំងអស់តែម្តង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលទៅក្នុងអង្គហេតុនៃការលើក ឬក៏ជីកប្រឡាយទំនប់១មករា និង៦មករាតែម្តង។ លោកជាមេភូមិ ហើយជាមេក្រុមដឹកនាំកម្លាំង ឬកម្មករទៅធ្វើការលើកទំនប់ជីកប្រឡាយ១មករា។ តើរបៀបនៃការជ្រើសរើស ឬការចាត់តាំងយកកម្លាំង ឬយកមនុស្សពីក្នុងភូមិ តើនរណាជាអ្នកមានអំណាច ឬមានសិទ្ធិក្នុងការចាត់ចែង ឬតម្រូវយកកម្លាំងទាំងនោះ?

**ឆ៖** នែ៎ តម្រូវចាត់ចែងកម្លាំងនោះ គឺឃុំគេសម្រេចឲ្យយកប៉ុណ្ណេះប៉ុណ្ណោះទៅ។ ភូមិណាត្រូវយកប៉ុន្មាន ថាយក១០០នាក់ យក១០០នាក់ទៅ ក្នុងពេលធ្វើប្រឡាយហ្នឹង ក្នុងរដូវប្រាំង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង វិធីនៃការជ្រើសរើសយកកម្លាំង ឬយកមនុស្សចេញពីភូមិ តើលោកសម្រេចជ្រើសរើសដោយរបៀបណា? មានន័យថា លោកជ្រើសរើសអ្នកពេញកម្លាំង គេហៅកម្លាំងយ៉ាងម៉េច ទី១ ទី២ ទី៣ ឬកម្លាំងខ្លាំងខ្សោយយ៉ាងម៉េច លោកអាចជម្រាបជូនបានទេ?

[១៤:១៤:២៨]

**ឆ៖** ទាន នែ៎កម្លាំងពេញដែលមិនទាន់មានប្រពន្ធ មិនទាន់មានប្តី អាហ្នឹងជាកម្លាំងចល័តទេ

ទាន យើងមិនអាចចាត់ប្រើគេទេ។ វាមានក្រុមចល័តគេ បាទ គេមានក្រុមចល័តគេទេ។ ឯខ្ញុំនេះ មានតែប្រជាជនដែលមានប្ដី មានប្រពន្ធ។

**ស៖** បាទ សូមអរគុណ។ សូមសួរលោកថា តើនៅក្នុងភូមិរបស់លោក ពេលដែលជ្រើសរើសកម្លាំងចល័តក៏ដោយ ឬក៏កម្លាំងខាងមានប្ដី មានប្រពន្ធក៏ដោយ តើពេលហ្នឹងមានប្រជាជនប៉ុន្មានគ្រួសារនៅក្នុងភូមិរបស់លោក រួមទាំងប្រជាជនចាស់ និងប្រជាជនថ្មី?

**ឆ៖** ប្រជាជនចាស់មានចំនួន១០០គ្រួសារ ហើយប្រជាជនថ្មីថែម១០០គ្រួសារមកទៀតមក២០០គ្រួសារ។

**ស៖** បាទ សូមអរគុណ។ តើការជ្រើសរើសកម្លាំងរបស់ក្រុមលោក ប្រជាជនចាស់ និងប្រជាជនថ្មី។ ប្រជាជនពីរប្រភេទនេះ ប្រជាជនផ្នែកណាមួយដែលតម្រូវទៅលើកទំនប់ ឬជីកប្រឡាយច្រើនជាងគេ?

**ឆ៖** ក្នុងភូមិរបស់ខ្ញុំដូចតែគ្នាទេ អ្នកណាមិនចេះធ្វើការងារផ្សេងទៅជីកប្រឡាយទៅ អ្នកណាចេះឡើងត្នោតក៏នៅឡើងត្នោតទៅ។ វាអត់មានថា អ្នកឡើងត្នោតក៏ទៅនោះ អត់ទេ អ្នកឡើងត្នោតឡើងតែត្នោតទៅ ហើយអ្នកដែលមិនឡើងត្នោតក៏ទៅៗ។ ប្រជាជនថ្មី និងប្រជាជនចាស់ដូចតែគ្នាហ្នឹងឯងទៅទាំងអស់គ្នាហ្នឹង។

[១៤:១៦:៣៧]

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកបញ្ជូនកម្លាំង ឬដឹកនាំកម្លាំង ដឹកនាំមនុស្ស ក្រុមលោកទៅធ្វើការងារលើកទំនប់ ជីកប្រឡាយ តើមានផ្ដល់ជាសម្ភារៈ ឬឧបករណ៍ឲ្យកងមនុស្សដែលជាកូនក្រុមរបស់លោកយ៉ាងម៉េចដែរ?

**ឆ៖** សម្ភារៈហ្នឹងលោកសួរអំពីរឿងបង្គី ចប ឬក៏សម្ភារៈ លោកសួរអំពីអីទាន? សូមសួរម្ដងទៀតមើល។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមញែកចេញជាពីរ។ ទី១ សម្ភារៈសម្រាប់លើកទំនប់ ជីកប្រឡាយ តើខាងណាអ្នកចែកឲ្យ? ហើយទី២ ទាក់ទងជាមួយនឹងម្ហូបអាហារ សម្លៀកបំពាក់ ថ្នាំសង្កូវជាដើម តើអ្នកណាជាអ្នករៀបចំឲ្យ?

**ឆ៖** ចប បង្គី គឺឃុំគេអ្នកឲ្យ តែគេគិតស្រូវ គេគិតថ្លៃស្រូវ។ ក្នុងចបមួយគេគិត ខ្ញុំមិនចាំដូចជា១៥គីឡូអីចេះក៏មិនដឹង ៣០គីឡូអីចេះក៏មិនដឹង។ ខ្ញុំភ្លេចត្រង់ហ្នឹងណាទាន។ ហើយខោអាវគេឲ្យ តែគិត

ជាលុយដែរទាន ចំពោះហ្នឹង ចំពោះដែលសម្ភារៈស្លៀកពាក់។ ចំពោះចប បង្គី យើងបោចរពាក់ធ្វើខ្លួនឯងដែរទេទាន ចំពោះបង្គី។

[១៤:១៨:២២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំទើបនឹងឮសួរលោកមានប្រសាសន៍ថ្ងៃនេះអំពីការដោះដូរជាមួយនឹងចប នឹងស្រូវ ឬក៏ខោអាវជាមួយនឹងទឹកប្រាក់ជាដើម។ លោកអាចពន្យល់ឲ្យជាក់លាក់បន្តិចបានទេកន្លែងហ្នឹង តើការដូរដោះដូរ ឬគិតជាតម្លៃយ៉ាងម៉េច? អ្នកណាអ្នកកាត់ថ្លៃ អ្នកណាអ្នកឲ្យ អ្នកណាអ្នកទិញ អ្នកណាអ្នកលក់ អ៊ីចឹង?

**ឆ៖** ទានការដែលធ្វើស្រែមួយឆ្នាំៗ យើងវាអត់ដែលថា អង្គការយកស្រូវទៅ គឺយកទៅអាថ្ងៃដែលយើងទិញនោះឯង អាថ្លៃយើងទិញចប និងខោអាវស្លៀកពាក់នុំងឯង--

**ស៖** បាទ សូម--

**ឆ៖** នៅខាងពាណិជ្ជ គេៗសរសេរឲ្យទៅ ហើយយករបស់ហ្នឹងទៅមើលទៅ បូកប៉ាន់ទៅភូមិយើងវាត្រូវប៉ុន្មានតោន។

**ស៖** បាទៗ សូមអរគុណ។ អ៊ីចឹងខ្ញុំមិនចង់ដឹងរឿងដោះដូរហ្នឹងទៀតទេ ខ្ញុំចង់សួរលោកបន្តទៀត ទាក់ទងជាមួយនឹងមនុស្ស ឬក៏យុវជន ឬក៏យុវនារី ឬក៏យុវវ័យកណ្ដាលដែលលោកគ្រប់គ្រងនេះ។ នៅពេលទៅលើកទំនប់ ខ្ញុំនិយាយទំនប់១មករានេះឯង ឬក៏ដីកប្រឡាយនៃទំនប់១មករានេះឯង ថាតើការរៀបចំនៃការរស់នៅយ៉ាងម៉េច? យើងទៅធ្វើកន្លែងធ្វើផ្ទះខ្លួនឯង ឬមានគេធ្វើឲ្យយើង?

[១៤:២០:០៧]

**ឆ៖** ការទៅរស់នៅជីកប្រឡាយហ្នឹង គឺខ្លួនយើងហ្នឹងទាន ខ្លួនយើងទៅធ្វើកន្លែងដេកខ្លួនយើងទៅធ្វើកន្លែងដេក ធ្វើកន្លែងសំណាក់ខ្លួនយើង ដើម្បីនឹងដេកនៅធ្វើការ។

**ស៖** បាទ អ៊ីចឹងខ្ញុំសូមសួរបន្ថែមបន្តិច។ កម្លាំងរបស់លោកទៅពីភូមិអម្បាញ់មិញថា តើអ្នកណាឧបត្ថម្ភសម្ភារៈចប បង្គី ជាដើម។ អ៊ីចឹងទៅធ្វើរោងធ្វើផ្ទះហ្នឹង តើគាត់បានឈើ បានស្លឹក បានក្ដារឯណាធ្វើបាទ?

**ឆ៖** យើងកាប់កន្លែងខ្ញុំ កាលនោះវានៅសម្បូរឈើ។ ឈើខាងលើ១មករាហ្នឹង កូនឈើតូចគរគោក កាប់ដឹកមក យកមកធ្វើទៅ។ វាបានមួយប្រាំងហ្នឹង វារួចកន្លែងនៅមួយប្រាំងហើយទាន។ ហើយចំពោះគ្រឿងប្រក់ហ្នឹង យើងចំបើងដេរធ្វើដូចជាស្បូវទៅ ហើយប្រក់ទៅ។ ប៉ុន្តែវាជិតបានតែថ្ងៃទេទាន

រួចដល់ភ្លៀងមកវាទទឹកហើយ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងជាមួយនឹងការរស់នៅប្រចាំថ្ងៃនៃការធ្វើការងារកន្លែងលើកទំនប់ ឬជីកប្រឡាយ១មកវានេះដដែល ពីព្រឹកមិញលោកបានជម្រាបជូនអង្គសវនាការ និងលោកប្រធានហើយថា បានរបបហូបចំពោះអ្នកធ្វើការងារ ថាជាបបរខាប់ដួសនឹងវែក ឬចាប់នឹងដៃបាន។ ចុះទាក់ទងជាមួយនឹងម្ហូបអាហារវិញ តើពួកគាត់បានរបរជាម្ហូបអាហារដោយយ៉ាងរបៀបណា ឬបានពីណាមក?

[១៤:២២:១០]

**ឆ៖** ចំពោះម្ហូប យើងដែលជាប្រធានភូមិហ្នឹងឯង ចាត់គេទៅរកនៅឯក្រោម រកនៅឯក្រោមអ្នកឯក្រោមដែលយើងចាត់ទៅហ្នឹង គេបញ្ជូនត្រីហ្នឹងមក។ ត្រីហ្នឹងត្រីប្រលាក់ ត្រីអាគេហៅថាត្រីកន្ទុរ៉ត្រី កន្ទុរ៉ត្រីហ្នឹង។

**ស៖** មិនៗអីទេបាទ ម្ហូបអាហារហ្នឹង សូមបន្តទៀតបាទ។ សូមសួរលោកថា នៅក្នុងការឆ្លើយព្រឹកមិញ ខ្ញុំបាទក៏សូមសួរតឡើងវិញ ខ្ញុំបាទមិនបានលើកយកជាឯកសារ ERN មកបញ្ជាក់ទេព្រោះលោកព្រះរាជអាជ្ញាបានសាកសួររួចហើយ ខ្ញុំគ្រាន់បន្ថែមនឹងសំណួររបស់លោកព្រះរាជអាជ្ញាអំពីរឿងថា របបពីរពេល។ តើគាត់ហូបឆ្អែតទេពេលនោះ ព្រោះក្នុងនាមលោកជាមេក្រុមផងដែរបាទ?

**ឆ៖** ការហូបទាំងពីរពេលហ្នឹងទានឆ្អែតដែរ ឆ្អែតតាមរបៀបអង្កាល់នោះវិញ។ មិនបានដូចយើងសព្វថ្ងៃណាទាន មិនមែនយើងឆ្អែតដូចយើងសព្វថ្ងៃថាឆ្អែតមែនទែនទេ។ ប៉ុនវាសម័យនោះ វាគ្រាន់ណាស់ហើយប៉ុណ្ណឹង។

**ស៖** លោកចង់មានន័យថាឆ្អែតតែនិយាយតែពាក្យសម្ដីទេ ឬយ៉ាងម៉េចបាទ?

**ឆ៖** ឆ្អែតមែនណាទាន ក៏ប៉ុន្តែវាមិនដូចយើងសព្វថ្ងៃទេ វាខ្វះម្ហូបខ្វះម្ហា ហើយរឿងហូបហ្នឹងវាមិនខ្វះទេ វាបានមួយចានពីរចានអីចឹងដែរមួយពេល។ យ៉ាងតិចណាស់បានមួយចាន។ បើថាវាសម្បូរទៅក៏បានពីរចាន ត្រូវឆ្នាំហ្នឹងវាខ្វះផង ស្រូវវាលិចផងអាឆ្នាំ៧៦ យើងស្ទូងវាមិនបានហ្នឹង ដល់ស៊ីឆ្នាំ៧៧ វាមិនខ្វះ។ ដល់ខ្វះ អាខ្វះហ្នឹងឯង ដែលវាពិបាកខ្លាំងនោះ។

[១៤:២៤:៥០]

**ស៖** បាទ សូមអរគុណ។ ខ្ញុំបាទក៏សួរបន្តទាក់ទងជាមួយនឹងការហូបចុងនៃការលើកទំនប់ជីកប្រឡាយហ្នឹងដដែលទេ។ លោកបានឆ្លើយជាមួយនឹងសំណួរលោកព្រះរាជអាជ្ញាទាក់ទងនឹងឯកសារ

E3/5255 ព្រឹកមិញនេះដែរ និយាយអំពីរឿងថា៖ "ក្នុងមួយថ្ងៃរបបហូបបានតែមួយកំប៉ុងទេ" ប៉ុន្តែលោកបាននិយាយអំពីរឿងស្លត្រកួន ឬស្លព្រលឹតខ្លះផងដែរ។ អ៊ីចឹងតើចំណុចនេះ វាទាក់ទងជាមួយនឹងការហូបមិនគ្រប់គ្រាន់ ឬក៏ការហូបមិនឆ្អែតនោះទេ ដែលធ្វើឲ្យសុខភាពរបស់ប្រជាជនដែលលើកទំនប់ជីកប្រឡាយហ្នឹងកាន់តែស្គាំងស្គមទៅនោះបាទ?

**ឆ៖** ទាន រសជាតិអាហារវាមិនសូវសម្បូរទេទាន រសជាតិអាហារមិនសូវសម្បូរ ហើយអនាម័យរបស់យើងវាគ្មានផង មនុស្សវាច្រើនជ្រុល ហើយ--

**ស៖** បាទ សូមអរគុណ។ ទាក់ទងនៅក្នុងឯកសារដែលលោកបានឆ្លើយរួចមកហើយផងដែរ លើឯកសារ E3/5255 ERN ជាភាសាខ្មែរ 00239908, ERN ជាភាសាអង់គ្លេស 00250044។ ខ្ញុំចង់បញ្ជាក់ឡើងវិញអំពីការជីកប្រឡាយ ក្រុមរបស់លោក ដែលលោកមានប្រសាសន៍ថា តម្រូវឲ្យម្នាក់ជីកដីឲ្យបាន៣ម៉ែត្រគូប ក្នុងមួយថ្ងៃមួយយប់។ អ៊ីចឹងមែនទេ?

**ឆ៖** ក្នុង--

[១៤:២៦:៥០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ ជាភាសាបារាំង គឺខ្ញុំអត់ឮ ERN ទេ អ៊ីចឹងប្រហែលជាបញ្ហាបកប្រែ សូមឲ្យបញ្ជាក់ឡើងវិញ ដើម្បីឲ្យយើងអាចតាមទាន់នូវការសួររបស់លោកមេធាវី។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណ។ សូមអភ័យទោសដល់លោកប្រធាន ដោយសារខ្ញុំបាទបានស្រាវជ្រាវបានតែឯកសារភាសាពីរ គឺភាសាខ្មែរ និងភាសាអង់គ្លេស។ អ៊ីចឹងសូមអធ្យាស្រ័យ ដោយមិនបានបង្ហាញភាសាបារាំងមួយទៀត ហើយក៏មិនមានអីដែលឆ្គងក្នុងការដែលអង្គជំនុំជម្រះអនុញ្ញាត។

បាទ សូមអរគុណបាទ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** អ៊ីចឹងខ្ញុំសូមបន្តសំណួររបស់ខ្ញុំបាទទៀត។ ទាក់ទងជាមួយនឹងការលើកទំនប់ និងជីកប្រឡាយដដែល នៅពេលដែលផែនការលើកប្រឡាយ ជីកដីក្នុងមួយយប់មួយថ្ងៃ៣ម៉ែត្រគូបនេះ បើសិន

ជាមានការធ្វើមិនគ្រប់ផែនការ តើស្អែកឡើងមានបន្ថែមពីលើការមិនគ្រប់ផែនការថ្ងៃកន្លងទៅនេះដែរឬទេ?

[១៤:២៨:២០]

**លោក ឱ ហួ៖**

**ឆ៖** ចំពោះកន្លែងដែលខ្ញុំបានដឹកនាំនោះ ដាក់ប៉ុនហ្នឹងមែនទាន ប៉ុនជួនកាលគេធ្វើកម្លាំងគ្នាវាខ្សោយមួយថ្ងៃបាន១ម៉ែត្រ ជួនកាលមិនបាន១ម៉ែត្រក៏មិនមានដែរ។ ក៏ប៉ុន្តែចេះតែវាស់ទៅ វាស់ថាៗ ទៅអ្នកវាស់ ដើម្បីសម្រួលដល់គ្នាអ្នកធ្វើផង មនុស្សដូចតែគ្នាទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំបានមើលទៅក្នុងឯកសាររបស់លោកដដែលទេ ទាក់ទងជាមួយនឹងក្រុមរបស់លោក ឃើញថា ការឆ្លើយរបស់លោក ឃើញក្រុមរបស់លោកមិនមានការចាប់មនុស្ស ឬក៏យកមនុស្សទៅសម្លាប់ទេ។ លោកបានឃើញនៅក្រុមគេផ្សេងទៀត។ សំណួររបស់ខ្ញុំចង់សួរថា នៅពេលដែលផែនការរបស់ថ្នាក់លើដាក់ឲ្យលើកទំនប់ ជីកប្រឡាយមិនគ្រប់ផែនការនេះ មានសន្តិសុខឬមានអ្នកត្រួតពិនិត្យពីលើ តើពេលដែលគេមកត្រួតពិនិត្យ លោកដោះស្រាយជាមួយនឹងអ្នកត្រួតពិនិត្យយ៉ាងម៉េច បើសិនជាកូនចៅរបស់លោកធ្វើអត់គ្រប់ផែនការ?

**ឆ៖** អ្នកត្រួតពិនិត្យមក គេមិនសូវជាត្រួតពិនិត្យខាងប្រឡាយទេទាន គេមកត្រួតពិនិត្យតែការងារគេ គឺការងារផ្សឹងរបស់គេទេ ការងារសន្តិសុខរបស់គេទេ ឯប្រឡាយ យើងខ្លួនយើងទេអ្នកពិនិត្យនោះ។

**ស៖** បាទ សូមអរគុណ។ បន្តទៅទៀត ខ្ញុំសួរលោកបន្តិចថា អំមិញលោកទើបតែឆ្លើយថ្មីៗទេអំពីរឿងសម្លៀកបំពាក់ស្បែកជើង។ លោកថាស្បែកជើងរបស់ប្រជាជនជាកម្មករលើកទំនប់ ជីកប្រឡាយហ្នឹង មានយកកង់ឡានយកមកធ្វើជាស្បែកជើង។ តើប្រជាជនដែលនៅលើកទំនប់ ជីកប្រឡាយហ្នឹង មានកង់ឡានយកមកកាត់ជាស្បែកជើងចែកបានគ្រប់គ្នាអីចឹងដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:៣០:៤៧]

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំសូមជំទាស់ដូចគ្នាដែរ គឺថាប្រសិនបើសាក្សីគាត់និយាយតែត្រឹមតែក្រុមគាត់ដែលមានគ្នា២០-៣០នាក់ហ្នឹង គឺវាអត់មានបញ្ហាអ្វីនោះទេ។ ប៉ុន្តែប្រសិនបើគាត់ទៅឆ្លើយអំពីស្បែកជើង ឬក៏សម្លៀកបំពាក់របស់មនុស្សពីរបីម៉ឺនថែមទៀតនោះ គឺគាត់មិនអាចឆ្លើយបាននោះទេ។ ដូច្នេះ ខ្ញុំសូមស្នើដល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីឲ្យកម្រិតសំណួររបស់ខ្លួន តែទៅលើអ្វីដែលគាត់ដឹងតែប៉ុណ្ណោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកធ្វើយ៉ាងដូចម្ដេច ដែលថាលោកមិនអាច -- ដែលថាសាក្សីមិនអាចដឹងអំពីអ្នកផ្សេងបាននោះ? គឺថាប្រសិនបើគាត់ដឹងអំពីអ្នកផ្សេង អំពីអ្នកក្រៅពី១០០នាក់នោះ គាត់អាចឆ្លើយបាន។

**លោក វ៉ិចទ័រ កូប៉េះ**

ប្រសិនបើអ៊ីចឹង យើងចាំបាច់ត្រូវបង្កើតជាមូលដ្ឋានមួយ ដើម្បីឲ្យមានជាមូលដ្ឋានមួយ ដឹងថាមនុស្សពីរបីម៉ឺននាក់ហ្នឹង គាត់ដឹង។ ព្រោះគាត់និយាយថា គាត់គ្រប់គ្រងមនុស្សតែ២០នាក់ទេ។ ដូច្នេះប្រសិនបើការដែលយើងលោតពីថា គាត់ដឹងពីមនុស្ស២០នាក់ ទៅដឹងមនុស្ស២០.០០០នាក់ អាហ្នឹង វាជាការលោតមួយដ៏ខ្ពស់មែនទែន។ ដូច្នេះ ចាំបាច់យើងត្រូវតែបង្កើតជាមូលដ្ឋានមួយ ដែលឲ្យយើងអាចបង្កើតជាមូលដ្ឋានមួយ ដើម្បីយើងលោតពីចំណុចមួយទៅចំណុចមួយទៀត។ ដូច្នេះខ្ញុំគិតថា យើងគួរតែមានចំណុចមួយម្ដងៗ ដែលយើងមិនអាចថាត្រូវចាប់ពីចំណុចតូចមក ទៅគ្របដណ្ដប់ទៅលើចំណុចធំទាំងអស់កើតនោះទេ។

[១៤:៣២:១៦]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ហុង គីមសួន លោកប្រើនូវវិធីសាស្ត្រក្នុងការតាំងសំណួរបែបដូចលោកសហព្រះរាជអាជ្ញាអន្តរជាតិ គាត់បានធ្វើអម្បាញ់មិញ ក៏មានការជំទាស់អ៊ីចឹងដែរ។ អ៊ីចឹង គាត់បំបែកសំណួរហ្នឹងជាពីរប្រភេទ សំណួរនៅក្នុងក្របខ័ណ្ឌចង្អៀត ហើយបន្ទាប់មកសួរសំណួរបែបគ្នា ក្នុងក្របខ័ណ្ឌទូលាយ។ បើសួររបៀបនេះ វានាំឲ្យមានភាពច្បាស់លាស់ រវាងចំណុចដែលគាត់បានដឹងជាក់លាក់ ហើយនិងដឹងផ្សេងទៀត ដែលគាត់ធ្វើការសង្កេត។ យើងបានដាក់ហើយ នូវពាក្យថា តាមការសង្កេតរបស់សាក្សីដែលបានឃើញ បានធ្វើការសង្កេតដើម្បីឆ្លើយតបទៅនឹងសំណួរ។ លោកអាចកែសម្រួលសំណួររបស់លោក ឲ្យដូចនឹងទៅរបៀបការតាំងសំណួរបំបែករបស់សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើ

រួចហើយ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទសុំសួរសំណួរនេះជាថ្មីឡើងវិញ ដើម្បីឲ្យងាយស្រួលក្នុងការស្ដាប់និងឆ្លើយ បាទ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** លោកសាក្សី អម្បាញ់មិញខ្ញុំសួរសំណួរទូលាយ ឥឡូវនេះ ខ្ញុំសូមសួរជាក់លាក់ថា តើនៅក្នុងក្រុមរបស់លោកជាមួយនឹងក្រុមជិតខាងដែលលោកសម្គាល់ឃើញ តើមានការយកកង់ឡានមកចែកឲ្យកាត់ស្បែកជើងបានក្នុងក្រុមគ្រប់គ្នា និងពិនិត្យខាងជុំវិញហ្នឹង មានច្រើនដែរឬទេ?

**លោក ឱ ហួ៖**

**ឆ៖** អឺចេះទេទាន ដែលអារឿងស្បែកជើងហ្នឹង វាអ្នកកាត់ហ្នឹង មិនមែនកាត់ឲ្យគេទេ គឺអ្នកមួយ អ្នកណាចេះកាត់ទៅ ក៏អ្នកដែលផ្សឹងហ្នឹងបានកង់ឡាន សុំកង់ឡានពីគេមកបន្តិចបន្តួចល្មមស្បែកជើងខ្លួនឯង ទៅពឹងឲ្យគេកាត់ឲ្យតែប៉ុណ្ណឹងទេទាន។

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំសួរចូលទៅដល់ខាងផ្នែកស្ត្រីនៃកងកម្មកររបស់លោកម្ដង។ តើស្ត្រីនៅក្នុងកង ឬក្រុមរបស់លោក ទាក់ទងជាមួយនឹងសុខភាពរបស់ស្ត្រី នេះគឺខ្ញុំសូមនិយាយអំពីទាក់ទងជាមួយនឹង ភាគច្រើនគឺស្ត្រីដែលមានស្វាមី និងមានប្ដី ឬមានប្រពន្ធនោះ។ តើស្ត្រីមានជាក្រណាត់ ឬសំឡីអនាម័យសម្រាប់ពួកគាត់ប្រើទេ នៅក្នុងក្រុមរបស់លោក?

[១៤:៣៤:៥០]

**ឆ៖** ទាន កុំថាដល់សំឡីអនាម័យ ឲ្យបានតែខោអាវស្លៀកពាក់ ហើយការងារនោះឯង យកក្រណាត់ចាស់ៗទៅ ដេរទៅ។ ដេរទៅ ប្រើទៅ វាធ្វើម៉េច បើវាអ៊ីចឹងទៅហើយ។

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំសួរដល់កន្លែងដែលលោកឆ្លើយអម្បាញ់មិញរឿងថតកុន រែកដីម្ដង ដែលលោកបានមើលឃើញ។ នៅពេលដែលរត់រែកដីលោកថា លោកដូចជាមេក្រុមផ្សេងៗទៀតជាអ្នកដឹកនាំការរែកដី ហើយរត់ឲ្យគេថត អ៊ីចឹងទេ? នេះសូមបញ្ជាក់បន្តិចសិនបាទ។

**ឆ៖** អឺចឹងមែនទាន បើបានគេមកថតនុំងវាសប្បាយនឹងគេថតផង ម្ល៉ោះហើយខំរត់ដើម្បីវាបានថតនឹងគេ។

**ស៖** បាទ អ៊ីចឹងខ្ញុំសួរទាក់ទិនជាមួយនឹងដីនៅក្នុងបន្ដិ ក្នុងរូបភាព ឬក៏ក្នុងពេលកំពុងតែរែករត់

ហ្នឹង បើមានកម្មករដែលរែកដីកំពប់តាមផ្លូវអ៊ីចឹង តើអង្គការ ឬក៏ថ្នាក់លើយកកំហុស យកទោសពៃរ៍ពីពួកគាត់ដែរទេ?

**ឆ៖** មិនមានយកទេ អត់មានយកទោសយកពៃរ៍អីទេ ដែលខ្ញុំឃើញណា៎ ដែលខ្ញុំធ្វើនឹងគេដែរ ប៉ុន្តែវាមិនសូវនឹងកំពប់ទៀតណាទាន ព្រោះយើងប្រយ័ត្ន ឱ្យវាបានសប្បាយនឹងគេ អង្កាល់នុំងវាមានល្ហែនឯណា មានតែកុន ហើយកុនខ្លួនឯងហ្នឹង។

**សៈ** បាទ សូមអរគុណ។ ឥឡូវនេះ ដោយពេលវេលាផង ខ្ញុំសូមចូលទៅក្នុង -- ទាក់ទងជាមួយនឹងការរៀបការ ដែលលោកជាមេភូមិដែលបានឆ្លើយអម្បាញ់មិញជាមួយលោកសហព្រះរាជអាជ្ញាថា បានជួយរៀបចំបុរសស្ត្រីក្នុងភូមិ បានរៀបការពី៣០ទៅ៤០គូនោះ ហើយលោកថា ទាល់តែមានបុរស ឬក៏ស្ត្រីគេស្នើ ឬក៏គេសុំទៅអង្គការអំពីថា គេចង់បាននារីនេះ ឬបុរសនោះជាដើម។ ចុះនៅក្នុងពេលខ្លះនៃការរៀបចំមង្គលការ ឬរៀបការនោះ មានអ្នកដែលមិនព្រម ឬអ្នកដែលមិនស្ម័គ្រចិត្តដែរឬទេក្នុង២០ ឬ៣០-៤០គូនោះ បាទ?

**ឆ៖** មានដែរទាន។ មានគេមិនយកដែរ។

**សៈ** បាទ សូមអរគុណ។ តើមានអ្វីកើតឡើងចំពោះពួកអ្នកដែលមិនព្រមទៅរៀបការនុំងដែរឬទេ?

**ឆ៖** ចំពោះអ្នកមិនព្រមហ្នឹង គឺគ្មានទៅស្អីទេ ន៎ វាអត់មានថា យកទោសយកពៃរ៍អីទេ បើយើងមិនទាន់ការផង។ គ្នាប្រាប់ថា គ្នាមិនស្រឡាញ់ទេ ក៏អ្វីទៅ។ យើងរៀបតែអ្នកស្រឡាញ់ទៅ ក៏ប៉ុន្តែអង្កាល់នោះ វាមិនអ៊ីចឹងទេណា៎ វាមនុស្សចង់បាន វាដាច់ៗយូរណាស់ ដាច់ការ។

[១៤:៣៨:៣៤]

**សៈ** បាទ សូមអរគុណ។ អម្បាញ់មិញលោកបានជម្រាបជូនអង្គសវនាការអំពីលោក ឬក៏ខាងមេឃុំ ដែលគេមកឈរជាម៉ែជាឪនៃការរៀបការ។ ចុះចំពោះឪពុកម្តាយបង្កើតរបស់គេទៅវិញ តើនៅពេលរៀបការហ្នឹង ខាងប្រធានភូមិ ខាងលោក ឬខាងឃុំហ្នឹងបានប្រាប់ ឬឱ្យដំណឹង ឱ្យឪពុកម្តាយរបស់គូស្វាមីភរិយាគេមកចូលរួមដែរឬទេ?

**ឆ៖** គេអត់មកទេទាន។ វាគេមិនប្រាប់ ព្រោះម៉ែឪមានហើយ ម៉ែឪ គឺគណៈកម្មការឃុំ ហើយភ្ញៀវមេភូមិទាំងអស់ ហើយនិងឈ្លបទាំងអស់ ហើយនិងអ្នកស្រុកដែលទៅមើលហ្នឹង។ ម៉ែឪមានបញ្ហាអី គេគិតតែគ្នាគេប៉ុន្នានាក់ហ្នឹងទៅ គេប្តេជ្ញាថា យកគ្នាជាប្តីប្រពន្ធទៅក៏វារួចការទៅបាត់ហើយ។

**ស៖** បាទ សូមសួរបន្តបន្តិច។ នៅក្នុងពេលរៀបការ២០ ឬក៏៣០គូ ដែលលោកធ្លាប់ជួយរៀបចំហ្នឹង តើមានជាភ្លេងប្រពៃណី ឬក៏មានជាម្ហូបអាហារសម្រាប់មង្គលការនោះដែរទេ?

**ឆ៖** ទៅលើភ្លេងភ្លាត់ ទៅលើអាហារហូបចុក គ្មានទេទាន ហូបពីរោងបាយយើងទៅ។ ហូបពីរោងបាយយើងទៅឲ្យរួចអ៊ីចឹងទៅ គេកំណត់ថាពេលប៉ុនណា ថាម៉ោងប្រាំគេរៀបការ យើងទៅឲ្យដល់ម៉ោងប្រាំទៅ។ ម៉ោងប្រាំទៅអង្គុយចាំគេ តាមគូៗយើងទៅ ដែលគេចាត់ចែង។ អ្នកណាគូនាងណា លោកណាគូនឹងនាងណា អ៊ីចឹងក៏អង្គុយជាគូៗអ៊ីចឹងទៅ។ ហើយក៏គេឧទ្ទេសនាមប្រាប់ទៅ។ ប៉ុណ្ណឹងចាប់ទៅបាត់ហើយ។ តែប្ដេជ្ញាចិត្តទៅ ថាខ្ញុំដើរតាមអង្គការអ៊ីចេះអ៊ីចុះទៅ ក៏ចប់ការបាត់ហើយ។ ប្រហែលជាយើងបីម៉ោងយ៉ាងយូរ។ គ្មានត្រូវការហូបអីទេ គ្មានឲ្យហូប។

**ស៖** បាទ សូមអរគុណបាទ។ សំណួរខ្ញុំសួរបន្ត ទាក់ទងជាមួយនឹងការរៀបការនេះ។ ក្រោយពេលរៀបការ តើគូស្វាមីភរិយាហ្នឹង ខាងលោក ឬក៏ខាងឃុំរៀបចំឲ្យពួកគេទៅ និយាយឲ្យចំគេទៅផ្សំដំណេក ឬក៏គេទៅដេកនៅឯណា? មានន័យថា នៅផ្ទះឪពុកម្ដាយ ឬក៏មានរោងគេធ្វើទុកឲ្យ ឬក៏ទៅតាមកងឯកភាពវិញជាដើម?

[១៤:៤១:៤៧]

**ឆ៖** បើគ្រួសារ បើគូស្វាមីភរិយានោះមានម៉ែមានឪ គេផ្សំដំណេកនៅផ្ទះម៉ែឪគេ។ បើគូស្វាមីភរិយានោះគ្មានម្ដាយឪពុកទេ មេភូមិហ្នឹងឯង រកផ្ទះឲ្យទៅ ឲ្យគ្នាសម្រាកទៅ។ តែប៉ុណ្ណឹងឯងទាន។

**ស៖** បាទ អរគុណ។ តើពួកគេជាគូស្វាមីភរិយាហ្នឹង មានរយៈពេលប៉ុន្មានថ្ងៃ ដែលរស់នៅជួបជុំគ្នា មុននឹងបែកគ្នាទៅវិញបាទ?

**ឆ៖** នៅតាមភូមិមិនអីទេទាន។ នៅតាមភូមិ យើងទៅធ្វើការឆ្ងាយពីគ្នាមែន ប៉ុនល្ងាចឡើងមកៗផ្ទះវិញទេទាន មកជួបជុំគ្នាវិញទេ។ ពេលទៅធ្វើការ ទៅបែកមែន ប៉ុន្តែល្ងាចឡើងមកជួបជុំគ្នានៅផ្ទះវិញទេ។

**ស៖** បាទ សូមអរគុណ។ បើសិនជាពួកគេត្រូវបានទៅតាមកងធ្វើការងារដាច់ដោយឡែកពីគ្នា តើខាងអង្គការទុកពេលឲ្យគេប៉ុន្មានថ្ងៃ ដែលគេមកជួបជុំគ្នាម្ដង?

**ឆ៖** ខ្ញុំបាទមិនដែលដឹងទេ រឿងហ្នឹងទាន។ អាហ្នឹងខាង ទាល់តែខាងគេចូលជួរ ហើយខាងខ្ញុំអត់មានអ៊ីចឹងទេ។ វាអត់មែន វាក្រៅជួរកម្មាភិបាល។

**ស៖** បាទ សូមអរគុណបាទ។ ខ្ញុំសួរលោកបន្តិចទៀត ទាក់ទងជាមួយនឹងក្រោយពេលរៀបការ

តើៗមានគូស្វាមីភរិយាណាទាស់គ្នា មិនចុះសម្រុងនឹងគ្នាដែរទេ? ហើយបើមាន ឬមិនមាន វាសនារបស់ពួកគេយ៉ាងម៉េចដែរ?

[១៤:៤៤:១០]

**ផះ** ការងារដែលរៀបការរួចហើយ ខ្ញុំតាមពិនិត្យអង្កាល់ហ្នឹង មិនឃើញមានទាស់ទែងគ្នាទេ។ ក្នុងភូមិរបស់ខ្ញុំ មិនដែលទាស់ទែងគ្នាទេ។ សព្វថ្ងៃបានកូន បានចៅ មកនៅភ្នំពេញមានកូនគគោក។ មិនដែលឃើញទាស់គ្នា ប៉ុន្តែបើទាស់គ្នា មេភូមិហ្នឹងឯង អ្នកទទួលខុសត្រូវទៅ អប់រំទៅ ពន្យល់ទៅ ស្រុកយើងវាប៉ុណ្ណេះទៅហើយ វាដូចថាវាខ្សត់ខ្សោយប៉ុណ្ណេះ យើងខំទៅឲ្យស្រុកយើងបានសម្បូរសប្បាយទៅ យើងសប្បាយហើយ។

**សះ** បាទ សំណួរចុងក្រោយរបស់ខ្ញុំ គឺចង់សួរលោកទាក់ទងជាមួយនឹងខាងសាសនា។ អម្បាញ់មិញលោកបានជម្រាបជូនខាងលោកប្រធាន និងអង្គសវនាការ អំពីជនជាតិចាម ដែលមិនឲ្យមានការគោរពសាសនា ឬក៏ការស្លៀកពាក់ជាដើម ដែលមើលមិនស្គាល់។ ខ្ញុំចង់សួរអ៊ីចេះ តើថានៅក្នុងភូមិឃុំរបស់លោក ព្រោះលោកពីដំបូង ពីព្រឹកថាបានបួសនៅវត្តជាង១០ឆ្នាំ ឬ១០ឆ្នាំ។ អ៊ីចឹងនៅក្នុងអំឡុងពេលនៃលើកទំនប់ជីកប្រឡាយ១មករាហ្នឹង លោកស្គាល់វត្តបារាយណ៍ដំដែកដែរទេ?

**ផះ** គេហៅ បារាយណ៍ជាន់ដែកទាន បារាយណ៍ជាន់ដែក។ ស្គាល់ទាន ប៉ុនខ្ញុំមិនដែលទៅទេកន្លែងហ្នឹង។ នៅបារាយណ៍ជាន់ដែកហ្នឹង កន្លែងគេសន្តិសុខគេហើយ។

**សះ** លោកអាចបញ្ជាក់បានឲ្យច្បាស់ជាងហ្នឹងទេ សន្តិសុខហ្នឹង គេសម្រាប់ធ្វើអីដែរបាទ?

**ផះ** ពីដើមគេយកមនុស្សទៅអប់រំរៀនសូត្រ ឬក៏មនុស្សដែលទោសធ្ងន់ទៅ ក៏គេយកទៅណាទៀត ក៏ខ្ញុំមិនដឹងដែរទាន។ ត្រង់ហ្នឹងខ្ញុំមិនសូវជាដឹងទេ។

**សះ** ជាចុងក្រោយ តើលោកបានដែលចូលទៅមើលទេ ក្រោយពេលដែលស្រុកមានសន្តិភាពឡើងវិញ ដែលត្រឡប់ទៅមើលកន្លែងបារាយណ៍ជាន់ដែក ដែលថាមន្ទីរសន្តិសុខហ្នឹងឡើងវិញទេ?

[១៤:៤៦:៥២]

**ផះ** ពេលដែលស្រុករាបទាបហើយ ដែលហៅថាអស់សង្គ្រាមហើយ វត្តបារាយណ៍ជាន់ដែកគេធ្វើបុណ្យធម្មតា ខ្ញុំក៏ទៅធ្វើបុណ្យហ្នឹងឯងទាន។ ទៅរៀបចំភ្ជុំបិណ្ឌនៅវត្តខ្លួនឯងផង នៅវត្តបារាយណ៍ជាន់ដែកផង។

**សះ** តើលោកមានដែលឮគេនិយាយថា--

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី លោកប្រើពេលវេលាលើសច្រើនហើយ។ បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកចូល មកកាន់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៧ នាទី ដល់ម៉ោង ១៥:០៣នាទី)*

[១៥:០៣:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ?

បាទ សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរបន្តទៀតដែលខ្ញុំត្រូវសួរទាក់ទងទៅនឹងអ្វីដែលព្រះរាជអាជ្ញាបានសួរពីព្រឹកមិញ។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ជាដំបូង ខ្ញុំសូមនិយាយអំពីស្ថានភាពការងារ លោកប្រាប់ខ្ញុំសិន ថាតើខ្ញុំនិយាយ ឬក៏ខុស បន្ទាប់មកខ្ញុំសួរលោក។ លោកបាននិយាយអំពីការធ្វើការ១៣ម៉ោងក្នុងមួយថ្ងៃ ហើយមានអាហារពីរពេលដែលមិនគ្រប់គ្រាន់ ហើយស្ថានភាពធ្វើការដែលគ្រោះថ្នាក់ ដូចជាលោកនិយាយហើយអំពីការបាក់ដី ឬក៏ការបាក់ទំនប់ ព្រមទាំងការផ្តល់សេវាព្យាបាលដែលមិនគ្រប់គ្រាន់ ថាតើខ្ញុំសង្ខេបទៅលើអ្វីដែល

លោកនិយាយហ្នឹងត្រឹមត្រូវដែរឬទេ គឺវាដូចអ្វីដែលលោកបាននិយាយពីព្រឹកមិញដែរឬទេ?

**លោក ឱ ហួះ**

**ឆ៖** បាទ វាត្រឹមត្រូវហើយទាន។

**ស៖** ហើយបន្តទៅទៀតនេះ ខ្ញុំសូមសួរលោកបន្ត ផ្អែកទៅលើស្ថានភាពទាំងអស់នេះ ខ្ញុំចង់ដឹងថា តើក្នុងមនុស្ស១០០នាក់ ដែលលោកគ្រប់គ្រងហ្នឹង ថាតើមានមនុស្សស្លាប់ដែរឬទេ ក្នុងចំណោមក្រុមរបស់លោក? ហើយប្រសិនបើស្លាប់ហ្នឹង ស្លាប់ប្រហែលប៉ុន្មាននាក់ដែរក្នុងមួយខែ?

**ឆ៖** មនុស្សដែលស្លាប់ ស្លាប់នឹងបាក់ដីម្ដងនោះឯងទាន។ បាក់ដីម្ដងហ្នឹង ថ្ងៃហ្នឹងវា ខ្ញុំប្រាប់ថាកុំឲ្យទៅជ្រកដែរ។ ដល់ខ្ញុំដើរចេញមក ដីហ្នឹងដែលគេជ្រោះទុកពីល្ងាចសម្រាប់រែកព្រឹកឡើង វាជ្រោះម្ខាង វាបាក់មក កិនគ្នាងាប់ ដីប្រហែលជា បើយើងឥឡូវ ប្រហែលជាបីឡាន ដីហ្នឹង ហើយលើមនុស្សប្រហែលជាបីនាក់ ស្លាប់។ មួយស្លាប់ហ្នឹងកន្លែង មួយនោះគ្រាន់តែយកចេញមកបានស្លាប់ ហើយមួយទៀតនោះទៅស្លាប់នៅផ្ទះ មើលទៅវាមិនជា។ អាហ្នឹងតែម្ដង ក្រៅពីហ្នឹងទៀត ដែលខ្ញុំមកធ្វើនៅកំប៉ើយហ្នឹង អានោះដើមត្នោត វាសង្កិនមក គាត់កាប់លុងៗទៅ ដើមត្នោតវាសង្កិនមកលើ ក៏ស្លាប់ទៅ។ ប៉ុន្តែអ៊ំ ដែលអត់ស្លាប់ទេ គាត់ហ្នឹង ខ្ញុំយកទៅពេទ្យ ដល់យកទៅពេទ្យទៅ ក៏ពេទ្យហ្នឹងគេបញ្ជូនទៅតំបន់ ទៅតំបន់នៅកំពង់ចាម ហើយគាត់ហ្នឹង ក៏រស់នៅដល់សព្វថ្ងៃនេះដែរ។

[១៥:០៧:០៥]

**ស៖** ដូច្នេះ ខ្ញុំសូមសង្ខេបបន្តិច ក្នុងរយៈពេល៣ឆ្នាំ ដែលថាពួកគាត់ត្រូវធ្វើការក្រោមស្ថានភាពដែលស្លាប់ទៅដូចធ្ងន់ធ្ងរនោះ គឺថាមានមនុស្សតែបីនាក់ ក្នុងចំណោមមនុស្ស១០០នាក់ដែលលោកគ្រប់គ្រងហ្នឹង គឺមានតែមនុស្សបីនាក់ទេដែលស្លាប់ អ៊ីចឹងមែនទេ?

**ឆ៖** ស្លាប់នឹងការងារមានតែបីនាក់ បីនាក់ហ្នឹងឯងស្លាប់ ស្លាប់នឹងការងារ ការងារដែលយើងជីកប្រឡាយ ហើយស្លាប់ដទៃទៀត អាហ្នឹងវាជារឿងម្យ៉ាងទៅហើយទាន ផ្សេងទេ។

**ស៖** ឥឡូវនេះ យើងពិភាក្សាទៅលើបញ្ហាមួយទៀត ខ្ញុំដឹងថា មានមនុស្សបួននាក់ ស្លាប់ដោយសារគ្រោះថ្នាក់។ ចុះមនុស្សដែលស្លាប់ដោយសារហេតុផលផ្សេងៗទៀត ខ្ញុំនិយាយហ្នឹងគឺនិយាយអំពីក្រុមមនុស្ស១០០នាក់របស់លោកហ្នឹង។ ដូច្នេះខ្ញុំចង់ដឹងថា ទោះបីជាស្លាប់ដោយសារហេតុផលអ្វីក៏ដោយ គឺថាក្នុងចំណោម១០០នាក់ហ្នឹង តើក្នុង១ខែហ្នឹងមានមនុស្សស្លាប់ប៉ុន្មាននាក់ដែរ ក្នុងក្រុមរបស់លោកហ្នឹង ហេតុផលអ្វីក៏ដោយ ស្លាប់ដោយសារហេតុផលអ្វីក៏ដោយ?

**ឆ៖** អត់ទេទាន វាដូចជាគ្មានស្លាប់អីទេក្រៅពីហ្នឹង ព្រោះវាអត់មែន ប៉ុន្តែចេះតែខំរកស៊ីទៅណា។ ស៊ីនេះស៊ីនោះទៅ វាដូចជាស្រួលផង កាលនោះវាអត់មានខ្មោចព្រាយក៏គ្មានធ្វើឲ្យវានេះទេ ស្រួល ប៉ុន្តែអើយវាមិនធាត់ដូចមនុស្សសព្វថ្ងៃទេណា វាស្គមៗហ្នឹងឯង ប៉ុន្តែវាដូចមិនសូវស្លាប់ទេ។

**ស៖** តើលោកអាចពន្យល់ទៅលើចម្លើយដែលលោកឆ្លើយកន្លងមក គឺថាមនុស្សបួននាក់ស្លាប់ដោយសារគ្រោះថ្នាក់ ដែលថា តើលោកចង់មានន័យថាម៉េច ដែលថាមានមនុស្សបួននាក់ស្លាប់ដោយសារហេតុផលហ្នឹងតែប៉ុណ្ណឹងទេ? ខ្ញុំស្តាប់ការបកប្រែជាភាសាអង់គ្លេសដូចជាមិនច្បាស់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

[១៥:០៩:៤៣]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ទេ ទាក់ទងទៅនឹងសំណួររបស់លោកស្រីចៅក្រម ដែលលោកលើកថាមានអ្នកស្លាប់បួននាក់។ ក៏ប៉ុន្តែសាក្សីបានបញ្ជាក់ថា មានតែបីនាក់ទេ ហើយម្នាក់ទៀតនោះមានរបួស ហើយក្រោយមកត្រូវបញ្ជូនទៅមន្ទីរពេទ្យ ហើយក៏ជួយសង្គ្រោះបាន រស់រហូតដល់សព្វថ្ងៃនេះ។ បាទ ដូច្នេះខ្ញុំគ្រាន់សូមជួយបញ្ជាក់ពីអ្វីដែលសាក្សីបញ្ជាក់កន្លងមក។ សូមអរគុណ។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** សូមអរគុណ។ ខ្ញុំមិនជំទាស់ទៅលើអាហ្នឹងទេ ខ្ញុំសូមសួរសំណួរខ្ញុំឡើងវិញ។ លោកបានឆ្លើយកន្លងមកនេះ ថាមានមនុស្សបីនាក់បានស្លាប់ ពាក់ព័ន្ធទៅនឹងហេតុគ្រោះថ្នាក់ ហើយចំពោះការស្លាប់ផ្សេងៗទៀត គឺជាបញ្ហាមួយដទៃ។ តើលោកចង់មានន័យយ៉ាងម៉េចដែលថា ការស្លាប់ផ្សេងទៀតគឺជាបញ្ហាដទៃ បញ្ហាផ្សេងទៀត?

**លោក ឱ ហួ៖**

**ឆ៖** អ្នកដែលស្លាប់ដែលខ្ញុំថា បញ្ហាហ្នឹងវាដទៃ វាការមកនៅឯផ្ទះហើយ ថាធ្វើស្រែនៅផ្ទះណ៎ាជួនកាលគាត់ឈឺ ប៉ុន្តែមិនជាច្រើនទេៗ។ ក្នុង១០០នាក់ហ្នឹង អស់មួយពីរទៀតទៅណា វាដែលគ្រាន់ឈឺៗផង ហើយវាប្រកបផ្សំថ្នាំវាមិនត្រូវ ក៏ងាប់ទៅ។ ថ្នាំយើងថ្នាំពេទ្យខ្មែរយើង។ វាសម័យហ្នឹង វាហាក់ដូចជា បុណ្យជួយដែរ មនុស្សមិនសូវជាឈឺប៉ុន្មានទេទាន។ ហ្នឹងកន្លែងខ្ញុំទេណ៎ា បើកន្លែងគេដទៃទៀតក៏

វាមិនខុសគ្នាប៉ុន្មានទេ។

**ស៖** លោកនិយាយថា មានម្នាក់ ឬក៏ពីរនាក់ស្លាប់ដោយសារជំងឺ។ តើចង់ដឹងថាតើម្នាក់ពីរនាក់ស្លាប់ដោយសារជំងឺហ្នឹងក្នុងរយៈពេល៣ឆ្នាំ ឬក៏១ឆ្នាំ ឬក៏១ខែ?

**ឆ៖** អាហ្នឹងវាត្រឹមការងារធ្វើប្រឡាយទេណា។ ការងារដែលធ្វើប្រឡាយអាស្លាប់បីនាក់នោះធ្វើអីជិតៗប្រឡាយ១មករា អីជើង។ ដល់អាក្រោយមកទៀត ឆ្នាំក្រោយមក ៧៨ ធ្វើប្រឡាយនៅឯំកំប៉ើយតពីអាប្រឡាយដែលពីធ្វើឆ្នាំ៧៧ តមកខាងបារាយណ៍មក។ ចល័តនោះ គេធ្វើមួយកន្លែងទៅ ខ្ញុំនោះមួយកន្លែងទៅ បាទចល័តនោះចល័តតំបន់ណា។ គេធ្វើមួយកន្លែងទៅ ខ្ញុំធ្វើមួយកន្លែងទៅ ហើយសង្កាត់គេដទៃទៀត គេធ្វើអីចឹងទៅ។ ដាក់កំណាត់ចល័តគ្នាទៅ។ ដែលខ្ញុំថា វាមិនឃើញស្លាប់នោះ វាមិនឃើញស្លាប់នៅត្រង់ថា ការងារដែលធ្វើហ្នឹងវាហូបចុកដូចថាវាមិនសូវជាសម្បូរមែនហើយ ប៉ុន្តែវាបានហូបៗ ទោះបីឆ្អាញ់ មិនឆ្អាញ់ម៉េចវាបានហូប។ វាមិនដល់ថ្នាក់អត់រលីងទេ។

[១៥:១៣:២៣]

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកសំណួរដើមរបស់ខ្ញុំវិញ។ លោកនិយាយថា មានកម្មករម្នាក់ពីរនាក់ស្លាប់ដោយសារជំងឺ។ ដូច្នេះខ្ញុំចង់សួរលោក ថាតើម្នាក់ ឬក៏ពីរនាក់ហ្នឹងស្លាប់ក្នុងរយៈពេល៣ឆ្នាំ ឬក៏ក្នុងអំឡុងពេល១ឆ្នាំ ឬក៏ក្នុងអំឡុងពេលត្រឹមតែ១ខែទេ? ប្រសិនបើលោកអាចប្រាប់ សូមប្រាប់មកខ្ញុំផង។

**ឆ៖** អាហ្នឹងគាត់ស្លាប់ក្នុងពេលមួយឆ្នាំ៧៧ យើងនិយាយថា ៧៧មក៧៨ ក្នុងរយៈប្រហែលប៉ុណ្ណឹងណាទាន ក្នុងរយៈកាលប៉ុណ្ណឹង។ ថែមមនុស្សប៉ុណ្ណឹងទៀត។

**ស៖** ដូច្នេះក្នុងចំណោមមនុស្ស១០០នាក់ ក្នុងក្រុមរបស់លោក អ៊ីចឹងប្រហែលក្នុងរយៈពេលនុ៎ងគឺមានមនុស្សតែប្រហែលប្រាំទៅប្រាំមួយនាក់ទេដែលស្លាប់ ហើយអ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** ឥឡូវនេះ ខ្ញុំសូមបន្តទៅសំណួរទី២ របស់ខ្ញុំ គឺថាលោកបាន -- លោកត្រួតពិនិត្យមើលទៅលើមនុស្ស១០០នាក់ ហើយក្នុងចំណោមមនុស្ស១០០នាក់ ដែលលោកត្រួតពិនិត្យហ្នឹង គឺគាត់ធ្វើ -- ពួកគេធ្វើការនៅទំនប់។ ថាតើពួកគាត់១០០នាក់ហ្នឹងធ្វើការដាច់ពីគេ ឬមួយក៏គាត់ធ្វើការជាមួយក្រុមមនុស្សដទៃទៀត មនុស្សប្រហែលជិត២០.០០០នាក់នុ៎ងទៀត? តើពួកគាត់ធ្វើការដាច់ពីគេ ឬក៏គាត់ធ្វើការរួមជាមួយពួកគេ?

[១៥:១៥:០៣]

**ឆ៖** ខ្ញុំសូមជម្រាបថា ឆ្នាំទី១ គឺឆ្នាំ៧៧ហ្នឹង ធ្វើនៅឯស្ទឹងជីនិតណ៎ាទាន ធ្វើនៅស្ទឹងជីនិត ធ្លាក់មកត្បូង។ ដល់ឆ្នាំ៧៨ ធ្វើឯៗត្បូងគេ ពីមកពីស្ទឹងជីនិតប្រហែលជា៣គីឡូទៀតទេ មិនមែនជាប់នឹងស្ទឹងជីនិតទេ។ ធ្វើមួយៗនេះ ធ្វើមួយស្រុកបារាយណ៍។ ហើយន៎ែ កាលដែលរស់នៅហ្នឹង យើងរស់នៅតាមដូចខ្ញុំនិយាយអ៊ីចឹង ថាធ្វើខ្ទមខ្លួនឯង នៅខ្លួនឯង ប៉ុន្តែខ្ទមហ្នឹងធ្វើនៅជាសមូហភាព។ យើង១០ថ្ងៃយើងសម្រាកម្តង។ ដល់សម្រាកម្តង ដែលអ្នកមានប្តីប្រពន្ធក៏គេសូមទៅផ្ទះ ក៏ទៅៗ។ អ្នកដែលមិនទៅ ក៏ហីទៅ។ អ្នកខ្លះគេខ្ជិលទៅ គេចាំហូបបាយល្ងាចរួចបានគេទៅ។

**ស៖** លោកសាក្សី ខ្ញុំចង់ឲ្យលោកឆ្លើយសំណួរខ្ញុំឲ្យផ្ទាល់ ឲ្យចំតែម្តង។ ដូច្នេះខ្ញុំចង់ដឹងថា តើក្រុមរបស់លោកដែលមានមនុស្ស១០០នាក់ហ្នឹង តើពួកគាត់ហ្នឹងធ្វើការជាមួយក្រុមដទៃទៀត ធ្វើការជាមួយកម្មករដទៃទៀត អាចថាជាមួយមនុស្សប៉ុន្មានពាន់ ប៉ុន្មាននាក់ ប៉ុន្មានពាន់ ប៉ុន្មានម៉ឺននាក់ទៀត ឬមួយក៏ក្រុមរបស់លោក១០០នាក់ហ្នឹង ធ្វើការដាច់ពីក្រុមគេដទៃទៀត បានន័យថា គាត់ធ្វើការរួមជាមួយអ្នកដទៃទៀត ឬក៏គាត់ធ្វើការដាច់ពីគេតែម្តង?

[១៥:១៦:៥១]

**ឆ៖** ទាន ន៎ែ ការធ្វើការនេះ ដល់រួចទៅធ្វើការមកខាងដាច់ពីគេទេ ធ្វើការដាច់ពីគេទេ មកខាងបារាយណ៍ទេ។ ពីមុនយើងធ្វើការរួមក្នុងដែលប្រឡាយ១មករា ដែលមកជាប់ពីៗទំនប់១មករា។ ដល់ឆ្នាំក្រោយទៀត យើងធ្វើមកខាងក្រោម១មករាហ្នឹង ប្រហែលជា៣គីឡូទៀត។ ហើយធ្វើបែកពីគេទេ មិនមែនធ្វើជាមួយនឹងគេទេ។ យើងចែកគ្នាទៅ ១០០នាក់ហ្នឹងវាគេឲ្យដីប្រហែលជា១០០ម៉ែត្រ ដីបណ្តោយវា១០០ម៉ែត្រ ជីកប្រឡាយជម្រៅន៎ែ៣ម៉ែត្រ ខ្លះ៤ម៉ែត្រ ខ្លះ -- ហើយនិង៥ម៉ែត្រខ្លះ។ ប៉ុណ្ណឹងឯង។ ហើយគ្នាយើងប៉ុណ្ណឹង ធ្វើប៉ុណ្ណឹងឯង។ ហើយយើងកំណត់ថា ធ្វើពីខែ០១ទៅ ខែ០៦ត្រូវតែរួចៗឲ្យស្អាតហ្មង ព្រោះខែ៦ ចាប់ពីខែ៦ទៅ យើងទៅស្ទូងវិញ។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ នៅពេលដែលលោកធ្វើការជាមួយក្រុមដទៃទៀត តាមដែលលោកសង្កេតឃើញ ថាតើស្ថានភាពការងារគឺដូចគ្នា ឬមួយក៏ក្រុមរបស់លោកមានស្ថានភាពការងារផ្សេងពីគេ? អាចថាមានស្ថានភាពការងារប្រសើរជាងគេ ឬក៏អាក្រក់ជាងគេ? តើលោកសង្កេតឃើញយ៉ាងម៉េចដែរ នៅពេលដែលក្រុមលោកធ្វើការជាមួយក្រុមដទៃទៀតនោះ?

**ឆ៖** ដែលធ្វើជិតក្រុមគេទាន ដែលការធ្វើជិតក្រុមគេ វាប្រឡាស់ប្រកាំ វាលើសគេបន្តិចបន្តួច

ព្រោះយើងប្រើការលោម កំពុងប្រើការហិង្សាដាក់ លោមៗអ៊ីចឹងទៅ។ ខែនេះវាសម្បូរស្វាយ ទៅរកស្វាយខ្ចីមកឱ្យហូបទៅ ពេលណាសម្រាកក៏ស្វាយខ្ចីមួយពីរបី។ កាលនោះយើងវាទឹកប្រហុកនឹងស្វាយខ្ចីហូបៗទៅ។ ហើយវាប៉ុណ្ណឹង វាពិសេសណាស់ហើយ ដែលលោកស្រី វាពិសេសណាស់មែនទែនហើយ វាកម្រនឹងបានស៊ី។ ដល់យើងបានប៉ុណ្ណឹងទៅ វាល្អណាស់ទៅហើយ។ ហើយអាត្រង់ហ្នឹងហើយ ដែលនាំឱ្យគេប្រឹង។ ហើយប្រាប់គេថា យើងធ្វើនេះ វារបស់យើងហើយ បើទោះជាទៅដល់ណាទៀត ក៏គេមកលែងថា *(ឮមិនច្បាស់)* ហើយ។ វាៗជារបស់ៗយើងសម្រាប់ធ្វើស្រែរបស់យើង។ ដល់នេះវាបានដូចសេចក្ដីប្រាថ្នាមែនទាន។

**ស៖** ដូច្នេះខ្ញុំនិយាយបានថា មានក្រុមការងារច្រើនមានការទំនាក់ទំនងជាមួយក្រុមការងារច្រើន ឬក៏មានការប្រាស្រ័យទាក់ទងជាមួយក្រុមការងារច្រើនអ៊ីចឹងនែ៎?

**ឆ៖** យើងធ្វើការអាស្រ័យនឹងកម្លាំងនឹងឯង លោកស្រី។ អាស្រ័យនឹងកម្លាំង បើកម្លាំងគេឯកភាពហើយ ការងារប៉ុនណាក៏ធ្វើកើតដែរ ហើយយើងពឹងគេទេ យើងការងារដែលយើងធ្វើនេះ យើងធ្វើដើម្បីឱ្យបានទៅ ឱ្យវាមានឈ្មោះបោះសំឡេងទៅវារួចខ្លួនយើងផង គេក៏រួចខ្លួន យើងក៏រួចខ្លួនទាំងអស់តែគ្នាហ្នឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកសាក្សី។

[១៥:២១:១៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោក ឱ ហូ ខ្ញុំមានសំណួរមួយចំនួន ដើម្បីបញ្ជាក់ទៅលើចម្លើយរបស់លោក។ ប្រសិនបើខ្ញុំយល់មិនច្រឡំទេកាលពីព្រឹកមិញនេះ លោកបានឆ្លើយថា មុនទំនប់១មករាហ្នឹង គឺមានទំនប់ផ្សេងទៀតដែលនៅការដ្ឋានហ្នឹង ហើយទំនប់នោះគឺថាបំផ្លាញដោយការទម្លាក់គ្រាប់បែក។ អ៊ីចឹងខ្ញុំស្ដាប់អ៊ីចឹង តើខ្ញុំស្ដាប់ត្រូវទេ កាលពីព្រឹកមិញលោកពិតជាឆ្លើយអ៊ីចឹងទេ?

**លោក ឱ ហួ៖**

**ឆ៖** ទានមិនមែនទម្លាក់គ្រាប់បែកទេ ដែលគេលែងធ្វើទំនប់ហ្នឹង បោកគ្រាប់បែកទេទាន។ ដាក់ត្រីយកត្រីស៊ី ដល់ពេលគេចុចមីនហ្នឹងទៅវាផ្ទុះឡើងវាខូចអាទំនប់ហ្នឹង បានគេធ្វើក្រោយគេយក តាមហ្នឹងដែរ គេៗយកតាមហ្នឹងមកៗ គេធ្វើតាមទំនប់ហ្នឹងឯង។ ហើយវាបានទំនប់ហ្នឹងឯងដែលគេប្រើប្រាស់សព្វថ្ងៃនោះ។ ប៉ុន្តែគេធ្វើថ្មីក្រោយទៀត ប៉ុនថា ប្រឡាយនៅទាំងអស់ ប្រើទាំងអស់ ប្រើបានពេញហ្នឹង ហើយស្រួលអស់ពីចិត្តទៀត។

**ស៖** តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេថា នៅពេលណាដែលខ្មែរក្រហមបានចាប់ផ្ដើមសាងសង់ទំនប់? តើមានការដ្ឋានសាងសង់មុនថ្ងៃទី០៧ មករា ទេ? ឬក៏មានគម្រោងហ្នឹងគឺថា ក្រោយថ្ងៃ១៧ មេសាទេ ឬក៏មានតាំងពីថ្ងៃ មុនថ្ងៃ១៧ មេសាទៅទៀត?

**ឆ៖** ន៎ទាន ទំនប់១មករាដែលឲ្យឈ្មោះ ទំនប់១មករាហ្នឹង គេកំណត់ត្រឹមលោកន៎ ប្រធានគាត់ទៅធ្វើជាអធិបតី ក្នុងវិធីបើកវគ្គគឺថ្ងៃ០១ មករា ហ្នឹងហ្មង។ លោក ប៉ុល ពត លោកទៅ។ ប៉ុន្តែគេធ្វើៗ ពីមុនគេត្រួសព្រៃពីថ្ងៃមុនពីដែល ខែ១០ណោះ គេត្រួសព្រៃគេត្រួសអីស្រេច។ ដល់ថ្ងៃ០១ មករាហ្នឹង គាត់អញ្ជើញទៅជាអធិបតីទៅ ក៏គេកំណត់យកថា ១មករា ហើយគេជីកទៅជើងទៅទៀតដល់៦មករា។ អ៊ីចឹងប្រឡាយហ្នឹងវាបានទាំង ៦មករា វាបានទាំង ១មករា។ ប៉ុន្តែកាលដែលធ្វើនោះវាល្អណាស់បាទ ដល់វាបែកបាក់នឹង ទើបតែដាច់ៗ អាទៅមនុស្សវាបំផ្លាញ យកគ្រាប់បែកទៅបោកទៅអីគ្រាប់បែកធំៗចោះធ្វើអាថ្មៃយកត្រីនោះ វាបាក់វាបែកទៅក៏ខូចទៅ។

[១៥:២៤:៥៥]

**ស៖** ចុះមុនពេលសង់ទំនប់ ១មករា ឬក៏ ៦មករានេះ តើមាន -- ខ្មែរក្រហមមានគោលនយោ-បាយសាងសង់ទំនប់ ឬសាងសង់អាងស្ដុកទឹក ឬក៏ប្រឡាយដែរទេ? មានន័យថា ខ្មែរក្រហមចាប់ផ្ដើមសាងសង់ទំនប់ ១មករាហ្នឹងភ្លាមតែម្ដង ឬក៏មុនហ្នឹងមានការសាងសង់ទំនប់ផ្សេងពីនេះ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយៗ!

**លោក ឱ ហួ៖**

**ឆ៖** ទានប្រុស សូមជម្រាបបន្តិចចុះ។ កាលដែលមុនៗដាច់លោក លន់ នល់ ហ្នឹង យើងបានកសាងប្រឡាយមួយដែរខាងកើត ១មករាហ្នឹង ប៉ុន្តែប្រឡាយនោះវាទាបពេក ហើយវាទ្រវាយកពីអូរ។

ដល់កសាងនៅឆ្នាំ១៩៧៤ហ្នឹង ដល់កសាងទៅវាដាច់រលីងឆិញ។ ដល់មកឆ្នាំ៧៦ ពាក់កណ្ដាល៧៦ ខែ ១០ ក៏ខាងលើហ្នឹងកំណត់ថា នឹងចាប់ផ្ដើមសាង១មករា។ កាលនោះគេយកអាគ្រឿងចក្រ យកអី ទៅដកដើមឈើ ដកអីណា មនុស្សទាំងអស់នោះសប្បាយណាស់នឹងការងារហ្នឹង។ ដល់ពេលដកបានទៅ ក៏គេចាប់ផ្ដើមជីកៗ ខ្ញុំនឹងក៏មិនយល់ដែលការជីករបស់គេ វាមិនចេះជាងដែរណ៎ា។ ដល់គេជីកទៅ ក៏គេចែកថា ខាងខ្ញុំនេះឲ្យជីកប្រឡាយមកត្បូង ខាងដែលចល័តហ្នឹងគេធ្វើខាងទំនប់ អាត្រាក់ទ័រវុញខ្លះដែរ គេមិនមែនសុទ្ធតែមនុស្សទេ កាលនោះ។ ក៏ប៉ុន្តែអាត្រាក់ទ័រមួយពីរយកទៅលាបម៉េច មនុស្សរាប់ហ្មឺង ក៏គាត់សែង គាត់រែកអីចឹងទៅ ដែលខ្ញុំថាគេថតណ៎ា គឺគេយកឈើខ្ពស់ធ្វើជាកន្លែងអង្គុយ ហើយគេថតពីលើមក មើលមនុស្សរែកដីហ្នឹងឯង។ ដល់ឃើញគេថតហ្នឹងពួកមេភូមិ ពួកមេក្រុមទាំងខ្លួនឯងហ្នឹង ទាំងមេភូមិទាំងអីហ្នឹងនាំគ្នារត់ទៅ ចេះតែរត់ទៅ រត់ដាក់អម្រែករត់ទៅឲ្យគេថតជាប់។ ហើយដល់ជាប់ថតបានពីរបីថ្ងៃ គេយកមកឲ្យមើលមែន សប្បាយណាស់កាលនោះ បានឃើញអារូបខ្លួនឯងហ្នឹង។ នេះបាន១មករា គេធ្វើពីត្រឹមថ្ងៃ០១ មករា ប៉ុន្តែដែលកាលធ្វើនោះវាមុន ០១ មករា ប៉ុនគេកំណត់យកត្រឹមថ្ងៃ០១ មករា ដែលថ្ងៃដែលលោកប្រធាន លោកទៅជាអធិបតីនោះ ប៉ុណ្ណឹងឯង។

[១៥:២៨:០៦]

**ស៖** លោកទើបតែឆ្លើយថា មានគេដាក់ -- មានប្រើគ្រឿងចក្រដើម្បីរំលំដើមឈើ។ អីចឹងខ្ញុំចង់ដឹងថា តើមានកម្មករដែលធ្វើការដោយដៃទទេ ឬក៏មានឧបករណ៍ ឬក៏មានគ្រឿងចក្រច្រើនដែលសម្រាប់ធ្វើការហ្នឹង? តើលោកអាចជម្រាបបានទេថាតើកម្មករដែលធ្វើដោយដៃហ្នឹងមានប៉ុន្មានភាគរយដែរ ហើយមានគ្រឿងចក្រប៉ុន្មានភាគរយ? ហើយតើមានសត្វទេ? តើគេមានប្រើសត្វយកមកធ្វើការឧទាហរណ៍ដូចជាក្របីគោ យកមកដឹកដី ដឹកអីអីចឹងមានទេ?

**ឆ៖** ខ្ញុំសូមជម្រាបទាន គ្រឿងចក្រដែលខ្ញុំថា គ្រឿងចក្រហ្នឹង មួយទំនប់ ១មករាហ្នឹងប្រើគ្រឿងចក្របីទេ។ អាប្រដាប់ដែលដកដើមឈើមួយទៅ ហើយអាប្រដាប់រុញនោះមួយទៅ ប្រដាប់រៀបឲ្យស្មើមួយទៅ តែប៉ុណ្ណឹងទេ។ ក្រៅពីនោះសុទ្ធតែមនុស្សទេ។

**ស៖** ចុះសត្វគេមានប្រើគោក្របីអីដើម្បីដឹកដីទេ?

**ឆ៖** ព្រោះវាអត់មានទេទាន អត់មានយកសត្វទៅដឹកដីហ្នឹងទេ រែកហ្នឹងមនុស្សយើងមែនៗ។

**ស៖** អីចឹងតាមចម្លើយរបស់លោកហ្នឹងគឺថា មានមនុស្សរាប់ម៉ឺននាក់ធ្វើការនៅការដ្ឋានហ្នឹង ហើយមានគ្រឿងចក្រ ហើយអត់មានប្រើសត្វទេ។ អីចឹងខ្ញុំសង្ខេបមកវិញគឺត្រឹមត្រូវទេ ចម្លើយរបស់

លោកអម្បាញ់មិញនេះ?

**ឆ៖** គ្រឿងចក្រយើងថាមិនធ្វើក៏បានដែរ ព្រោះប្រឡាយប៉ុនណាណើយកគ្រឿងចក្រមួយពីរទៅធ្វើ វាចាញ់មនុស្សទៅហើយ។ ព្រោះវាគ្រាន់តែថាគ្រឿងចក្រហ្នឹងយកមកពង្រាបដី ដូចថាដីដែលយកយើងយកទៅចាក់ទៅវាមិន១ខ្ពស់ទាប១ យកអាត្រាក់ទ័រហ្នឹងទៅរុញឲ្យស្មើប៉ុណ្ណឹងទេបាទ។ មិនមែនយកអាត្រាក់ទ័រហ្នឹងទៅរុញដីហ្នឹងឡើងមកលើគោកទេ កម្លាំងមនុស្សទេ ឡើងមកលើគោកនោះ។ កម្លាំងមនុស្សសុទ្ធសាធ គ្មានយកគោ យកក្របីទេ។

**ស៖** បើតាមខ្ញុំយល់ការសាងសង់ទំនប់ហ្នឹង គឺមានការជាការលើកដីឡើងឲ្យខ្ពស់ដើម្បីទប់ទឹក។ បើតាមការដឹងរបស់លោកនោះ តើទំនប់ហ្នឹងគឺគេលើកដីហ្នឹងគឺប្រហែលជាកម្ពស់ប៉ុន្មានដែរ? ហើយបណ្តោយប៉ុន្មាន? គឺរាប់រយម៉ែត្រ រាប់ពាន់ម៉ែត្រ អ៊ីចឹងលោកអាចគិតមើលទៅមើល ថាប្រហាក់ប្រហែលជាប៉ុន្មានដែរ?

[១៥:៣២:១១]

**ឆ៖** ទំនប់១មករា ហ្នឹងគេគិតពីភូមិព្រៃស្រង៉ែទៅ។ គេគិតពីភូមិព្រៃស្រង៉ែទៅហ្នឹងគេហៅទំនប់១មករា ទៅដល់៦មករាហ្នឹងវាវែងណាស់ទាន ប្រហែលជាចូលជិត១០គីឡូ ក៏ប៉ុន្តែវាមានខ្ពស់មានទាប១។ ហើយគេដាក់វែកដីចាក់មកអាត្រាក់ទ័រចេះតែរុញទៅ អាត្រាក់ទ័ររុញមិនទាន់ ក៏ឆាយនឹងចបយើងទៅទៀតទៅ។ អាហ្នឹងកន្លែងដទៃទៀត ខ្ញុំមិនបានទៅ១ហ្នឹងទេ ប៉ុន្តែអ្នកដើរទៅមើលថ្ងៃ១០ថ្ងៃម្តងទៅមើលឃើញអ៊ីចឹង។ ព្រោះយើងធ្វើការ១០ថ្ងៃគេសម្រាកម្តង។

**ស៖** លោកបាននិយាយអំពីការប្រជុំដែលលោកបានចូលរួម១០ថ្ងៃម្តង។ អ៊ីចឹងការប្រជុំហ្នឹងប្រជុំជាមួយអ្នកបច្ចេកទេស ឬក៏ប្រជុំជាមួយនឹងមេកង? លោកចង់និយាយអំពីកិច្ចប្រជុំអីដែរ?

**ឆ៖** ១០ថ្ងៃប្រជុំម្តង គឺប្រជុំគ្នាយើងទាំង១០០នាក់ហ្នឹង ហើយសង្កាត់គេចូលជួយយោបល់បន្ថែមអាកម្លាំងឲ្យ ឲ្យវារីកឲ្យវាចម្រើន ហើយគេបានផែនការថ្មីមកពីខាងលើ គេផ្សព្វផ្សាយទៅ។ យើងទាំង១០០នាក់ក៏ស្តាប់គាត់ប្រាប់ទៅ។

**ស៖** តើការប្រជុំហ្នឹង គេហៅថាជាការប្រជុំទិតៀន ឬស្វ័យទិតៀន? ឬក៏ក្រៅពីកិច្ចប្រជុំ១០ថ្ងៃម្តងហ្នឹង គេមានកិច្ចប្រជុំស្វ័យទិតៀន ឬមានទិតៀនផ្សេងទៀត?

**ឆ៖** កន្លែងខ្ញុំធ្វើហ្នឹងមិនសូវមានទេទាន អាប្រជុំទិតៀនហ្នឹង។ ច្រើនតែប្រជុំលើកទឹកចិត្ត លើកទឹកចិត្តក្រុមណាដែលខ្លាំងថា ក្រុមនេះពូកែខ្លាំង ក្រុមនេះចំណាប់។ តែអន់ខ្ញុំមិនដែលថាទេ។ ថាក្រុមនេះ

ខ្លាំងជាងគេ រហូតដល់ក្រុមខ្លះប្រឹង ប្រឹងដោយសារនេះ ចង់ធ្វើ គេហៅថាក្រុមពិសេសគេ។ ខ្ញុំបានរៀប ក្រុមពិសេសប្រហែលជា២០នាក់។ ក្រុមហ្នឹងចុះមុនគេ ឈប់ក្រោយគេ។ តែរបបគឺបាយដូចគ្នា វាលើសតែត្រង់ទឹកត្រីទេ បានទឹកត្រីមួយមុខទៀត ហើយក្រុមគេដទៃទៀត វាទាល់តែសុំគេ បានគេឲ្យ។ ហើយម្យ៉ាងក៏គេមិនច្រណែនដែរ ព្រោះក្រុមពិសេសទៅហើយ។ ប៉ុន្តែអានេះ គ្រាន់តែដាក់ថា វាពិសេស គ្រាន់អួតគ្នាឯងទេ។ ឃើញថាវាបាន ដោយការដែលបញ្ចូលកម្លាំង បញ្ចូលគំនិតហ្នឹងឯង។

[១៥:៣៦:១៧]

**ស៖** តើខ្ញុំយល់ត្រូវទេ បើសិនជាខ្ញុំថា ក្រុមរបស់លោកនេះជាក្រុមឈានមុខ? កម្មករដែលស្ថិតនៅក្រោមបង្គាប់របស់លោកនេះ គឺជាកម្មករឈានមុខ ដែលត្រូវធ្វើជាគំរូសម្រាប់កម្មករផ្សេងទៀត តើអ៊ីចឹងទេ?

**ឆ៖** ប្រហែលជាអ៊ីចឹងហើយ ព្រោះមានថ្ងៃមួយនោះ ន៎ៃ ថ្នាក់ស្រុកគេបានប្រើមនុស្សឲ្យយកដែលពស់ ពស់ថ្លាន់១០យកទៅលើកទឹកចិត្តឲ្យក្រុមហ្នឹង គេហូបម្តង។ គេថាក្រុមហ្នឹងក្រុមល្អ។ ខ្ញុំក៏បានអរគុណនឹងគេដែរ គាត់បានយកចិត្តទុកដាក់ហ្នឹង។ ក៏ហូបទាំងអស់គ្នាទៅ។

**ស៖** នៅពេលសម័យនោះ មានប្រើពាក្យថា “ការប្រយុទ្ធក្តៅ ការវាយប្រយុទ្ធក្តៅ” គេមានហៅក្រុមលោកថាជា “ក្រុមវាយសម្រុកក្តៅ” ទេ?

**ឆ៖** ការនិយាយហ្នឹង ខ្ញុំក៏មិនដឹងទេ ក្រែងគេថាឯណាផ្សេងមិនដឹង ប៉ុន្តែកន្លែងខ្ញុំហ្នឹង វាថាក្តៅជាងគេទៅចុះ ក្តៅដោយសារប្រជាជនហ្នឹងឯង។ គេឮដំណឹងថា គេអួតលិចកើត ក៏ប្រឹងនឹងគេទៅដើម្បីបានចំណែក គឺបាយទឹកហ្នឹងឯង។ បើកាលណាវាខ្លាំងជាងគេ វាបានម្ហូប ហូបវាឆ្ងាញ់គ្រាន់បើ។ ប៉ុន្តែដែលខ្ញុំថាឆ្ងាញ់នោះ វាមិនមែនដល់ថ្នាក់សាច់ជ្រូកទេទាន មិនដល់ថ្នាក់សាច់ជ្រូកទេ ឆ្ងាញ់ហ្នឹង បានត្រឹមប្រហុកហ្នឹងឯង។ វាឆ្ងាញ់ណាស់ទៅហើយ។

[១៥:៣៩:០០]

**ស៖** អ៊ីចឹងខ្ញុំអាចនិយាយបានទេ ថាកម្មករដែលធ្វើការនៅក្នុងក្រុមរបស់លោកហ្នឹង គឺថាត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានកម្លាំងកាយមាំមួនខ្លាំង ដើម្បីបង្ហាញគំរូដល់គេ ហើយដើម្បីធ្វើឲ្យលើសពីផែនការដែលបានកំណត់ អ៊ីចឹងទៀត តើមែនទេ?

**ឆ៖** ន៎ៃ អ៊ីចឹងមែនទាន ព្រោះថ្ងៃដែលឆ្នាំ១៩៧៨ ដែលមុនខ្ញុំឈប់ប្រហែល១ខែ ចៅហ្វាយស្រុកមិនដឹង តំបន់ក៏មិនដឹងគេថា “ធ្វើរួចទេ?” ខ្ញុំបានប្រាប់គេថា “យើងធ្វើឲ្យទាល់តែរួច”។ គាត់ថា “ធ្វើម៉េច

រួច? អ៊ើ! ឲ្យអង្គការជួយ"។ គេប្រាប់ថា "អង្គការឲ្យជួយអីខ្លះ?" ខ្ញុំប្រាប់គាត់ថា "ឲ្យជួយដែកស្បែង ន៎ ១៥មក ហើយត្រសេះប្រាំបី ចបមិនបាច់ទេ ខ្ញុំមានអស់ហើយ ហើយនិងផ្លូន១៥"។ គាត់ឲ្យតាមសំណូម ពរមក ក៏ជីកដាក់ទៅឃើញទាន់មែនទាន ទាន់ៗមុនចូលឆ្នាំ ប៉ុន្តែគ្រាន់ថាវាមិនបានសម្អាត ប៉ុន្តែរួចមុន ចូលឆ្នាំ។ អានេះឆ្នាំ១៩៧៨។

**ស៖** ខ្ញុំមានសំណួរផ្សេងទៀតពាក់ព័ន្ធទៅនឹងអ្នកដែលត្រូវគេជ្រើសរើសសម្រាប់យកទៅធ្វើការ នៅការដ្ឋានទំនប់ ១មករា។ តើអ្នកដែលគេចាត់តាំងឲ្យទៅធ្វើការនោះ មានលទ្ធភាពក្នុងការប្រកែកមិន ព្រមទៅធ្វើការទេ? ហើយប្រសិនជាពួកគេទៅដល់ការដ្ឋានហើយនោះ ពួកគេអាចឈប់ធ្វើការ ហើយ អាចចាកចេញពីការដ្ឋានបានទេ? គេអនុញ្ញាតឲ្យធ្វើអ៊ីចឹងបានទេ?

**ឆ៖** អង្កាល់ខ្ញុំដឹងនាំធ្វើស្រែ ហើយធ្វើការដ្ឋានដូចមិនដែលមានពីណាប្រកែកមិនទៅ។ ឲ្យតែថា ខ្ញុំទៅនាំគ្នាទៅទាំងអស់គ្នា។ ថាសប្បាយ ព្រោះទៅៗយប់ទៅក៏ បើយប់ទៅបើខែហ្នឹងវាសម្បូរត្រី ខែ ប្រាំងមែន ប៉ុន្តែសម្បូរត្រីការដ្ឋានហ្នឹង វាថ្មវានៅក្នុងប្រឡាយគេអ្នកមុជចាប់នឹងថ្ម ចាប់ត្រីក្នុងទឹក ចាប់ នឹងថ្មបានក៏គេហូបទៅ មិនមានប្រកាន់ថាអ៊ីចេះថាអ៊ីចុះទេ ព្រោះគេរកហូបកម្លាំងគេ។ ម៉្លោះហើយ មនុស្សចង់ទៅ អ៊ីចឹង។

[១៥:៤២:៣៣]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទផ្សេងទៀត នៅពេលដែលលោកធ្វើជា ប្រធានភូមិនោះ តើនៅក្នុងភូមិរបស់លោកមានឈ្លបទេ?

**ឆ៖** ភូមិរបស់ខ្ញុំមានឈ្លបដូចតែភូមិរបស់គេដែរ ដូចតែគ្នាហ្នឹង។ ប៉ុន្តែឈ្លបខ្ញុំ នៅហ្នឹងក៏វា ស្តាប់បញ្ជារបស់ខ្ញុំ។ ខ្ញុំប្រាប់យ៉ាងម៉េចធ្វើអ៊ីចឹង មិនមែនទៅកំហែងគំរាមពីណា។ ធ្វើការដូចតែគ្នា គេក៏ ស្លូង យើងក៏ស្លូង ឈ្លបក៏ស្លូង មិនឈ្លបក៏ស្លូង ទាំងអស់តែគ្នាតើ។ អ្នកថ្មី និងអ្នកចាស់ដូចតែគ្នាហ្នឹងឯង អង្កាល់ហ្នឹង មិនមែនថា គ្នាអ្នកថ្មីមើលងាយអ៊ីចេះចុះអត់ទេ អត់មានមើលងាយគ្នាទេ ព្រោះគ្នាវាមករស់ នៅកន្លែងឯងហើយ។

**ស៖** តើឈ្លបមានតួនាទីជាក់លាក់អ្វីពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខទេ?

**ឆ៖** ឈ្លបការពារសន្តិសុខឲ្យប្រជាជន ។កុំឲ្យគេលួចមាន់លួចទាប្រជាជន។ នេះដែលខ្ញុំប្រាប់ ពីកាលនោះ តែភូមិដទៃទៀត ខ្ញុំមិនដឹងទេ។ ក្នុងភូមិខ្ញុំ ខ្ញុំថាមើលការខុសត្រូវកុំឲ្យគេលួចមាន់លួចទា ក៏ប៉ុន្តែភូមិហ្នឹងវាមានអ្នកណាលួច បើមាន់ឲ្យចិញ្ចឹមគ្រប់តែផ្ទះ ចិញ្ចឹមទៅហើយយកទៅដាក់រោងបាយ

បើថាយកផ្ទះមួយពីរបីហ្នឹងៗ ថ្ងៃក្រោយទៅយកផ្ទះផ្សេងទៀត ផ្ទះហ្នឹងឈប់យក ទាល់តែជុំបានមកទៀត។ ហើយបើម្ចាស់គេចង់ស៊ីក៏ស៊ីទៅ ធ្វើស៊ីទៅ ប៉ុន្តែវាលួចលាក់ស៊ីទៅណា។ យើងបើកសេរីអ៊ីចឹងទៅក៏វាបានមាន់ច្រើនហើយ ទាច្រើន។

[១៥:៤៥:២៨]

**ស៖** តើឈ្លបត្រូវរាយការណ៍ទេ បើសិនជាពួកឈ្លបនុ៎ងសង្កេតឃើញថា មានខ្មាំងនៅក្នុងជួរប្រជាជននោះ?

**ឆ៖** បាទ បើមានគេរាយការណ៍។ រាយការណ៍ទៅខាងខ្សែគេខាងសង្កាត់ហ្នឹង ហើយប៉ុន្តែក៏គេប្រាប់ខ្ញុំឲ្យដឹងដែរ។ បើខ្ញុំប្រាប់ថា កុំរាយការណ៍ក៏កុំទៅ។ ព្រោះមនុស្សទាំងអស់វាៗមិនងាយអ្នកណាថាមិនខុសទេ វាខុសទាំងអស់តែគ្នាហ្នឹងបន្តិចៗ ប៉ុន្តែយើងអត់ឱនគ្នាទៅ ក៏វាចម្រើនទៅបាត់។ ខ្ញុំយល់ឃើញអ៊ីចឹងបានអង្គាល់នោះខ្ញុំរៀបចំអ៊ីចឹង។ វាគ្មានពីណារៀបចំដូចខ្ញុំទេ ក្រែងក្នុងមួយសង្កាត់បល្ល័ង្កមានតែភូមិហ្នឹងឯង។ អ៊ីចឹងបានថា ប្រធានសង្កាត់ថា បើចង់ដឹងប្រណាំងគ្នាទៅ ធ្វើការប្រណាំងគ្នាទៅ។ ដល់គេចង់ដឹង គេថា អ៊ីចឹងប្រណាំងគ្នា អ្នកណាឈប់មុន។ ខ្ញុំថា ប្រណាំងៗទៅ ខ្ញុំឲ្យមនុស្សគ្នាខ្ញុំ ១០នាក់ គេ១០នាក់ ទៅដកសំណាប ប៉ុន្តែល្ងាចហ្នឹង ខ្ញុំដាំបាយឲ្យហូបស្រេច មើលរៀបចុះទៅដែលថាម៉ោងប្រាំមួយទៅហើយ យើងឲ្យគ្នាហូបបាយពីម៉ោងប្រាំទៅ ហូបឲ្យឆ្អែតទៅ។ អាហ្នឹងវាក្សត់នឹងគេហើយ ប៉ុន្តែវាក្សត់សម្ភូហភាពគេហើយ ប៉ុន្តែវាកម្លាំងរបស់យើងវាខ្លាំង។ យើងវាឈ្នះគេ ព្រោះយើងស៊ីស្រូវយើងតើ ហើយដល់គេវាគ្មានអីក្នុងពោះអាចទន់ជាងយើងដែរ ក៏ប៉ុន្តែវាមិនមានពីណាឲ្យពុងអាម៉េចទេ គ្រាន់តែថា ៗ អ្ហែ! ខ្លាំងមែន ក្រុមភូមិគេខ្លាំងមែន។ គ្រាន់តែប៉ុណ្ណឹងទេ វាគ្មានបានជាអីទេ បានតែប៉ុណ្ណឹងឯង ហើយវាបានល្អជាមួយគ្នារហូត ៗដល់សព្វថ្ងៃហ្នឹងក៏វាសប្បាយទាំងអស់គ្នាទៅ។

[១៥:៤៨:១១]

**ស៖** លោកសាក្សី នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្នុងពេលដែលលោកធ្វើជាប្រធានភូមិនោះ តើលោកអាចជម្រាបបានទេថាមានការបោះឆ្នោតដើម្បីជ្រើសរើសតំណាងប្រជាជនទេ?

**ឆ៖** អត់ទេទាន អត់មានបោះឆ្នោតទេ។ អត់មានបោះឆ្នោតធ្វើប្រធានភូមិអីទេ។ គេចាត់តាំងមកពីលើទេ បើគេអស់ចិត្តគេ គេរំសាយទេ។

**ស៖** ខ្ញុំអត់និយាយពីមេភូមិទេ។ គឺនៅកម្ពុជាទាំងមូលហ្នឹងគឺថា មានសភាតំណាងប្រជាជន តើលោកធ្លាប់ឮពាក្យហ្នឹងទេ សភាតំណាងប្រជាជននោះ? ហើយគេមានរៀបចំជាការបោះឆ្នោតដើម្បី

ជ្រើសរើសអ្នកដែលទៅអង្គុយនៅក្នុងសភាតំណាងប្រជាជនហ្នឹងទេ?

**ឆ៖** បាទ មានទាន។ កាលនោះ វាដាច់ៗ លន់ នល់ យូរដែរទាន ១ខែក៏មិនដឹង កន្លះ ជាងកន្លះខែមិនដឹង គេបោះឆ្នោតនឹងវត្តបារាយណ៍ គេធ្វើកន្លែងបោះឆ្នោតត្រឹមត្រូវ។ បោះឆ្នោត ប៉ុន្តែគេយកតែប្រជាជនចាស់ទៅទេទាន។ អ្នកដែលបូព៌ា អ្នកដែលជាចាម ហើយនិងជា១៧មេសា អត់បានយកទៅទេទាន។

**ស៖** ហើយអ្នកណាជាអ្នកចាត់តាំងបេក្ខជនសម្រាប់ឱ្យគេបោះឆ្នោតនោះ?

**ឆ៖** អ្ហ៎! តេជគុណ សួរខ្ញុំអ៊ីចឹង ខ្ញុំម៉េចនឹងឆ្លើយរួច ខ្ញុំមិនដឹងទេ ហួសសមត្ថភាពខ្ញុំហើយតើ។ ខ្ញុំមិនដឹងថាម៉េចទេ។

**ស៖** ខ្ញុំមានសំណួរពាក់ -- ប្រធានបទចុងក្រោយ ពាក់ព័ន្ធទៅនឹងសាសនា។ លោកបាននិយាយថា ខ្មែរក្រហមមិនអនុញ្ញាតឱ្យប្រតិបត្តិសាសនាទេ ទាំងសាសនាចាម ទាំងព្រះពុទ្ធសាសនា។ តើលោកអាចជម្រាបបានទេថា ចាប់ពីពេលណាទៅ ដែលគេចាប់ផ្ដើមហាមឃាត់មិនឱ្យប្រតិបត្តិសាសនា មុនថ្ងៃទី១៧ មេសា ៧៥ ឬក៏ក្រោយ១៧ មេសា ៧៥?

**ឆ៖** ទាន ខ្ញុំសូមជម្រាបអ៊ីចេះចុះទាន រឿងព្រះពុទ្ធសាសនា និងអ៊ីស្លាមសាសនា ចាប់ផ្ដើមពីឆ្នាំ១៩៧៣ទៅ ជម្រាលបន្តិចៗ។ ពុទ្ធសាសនា លោកយូរមាន់ហើយកាលនុំង ខមាទោស។ លោកយូរមាន់ទៅសមរភូមិ ហ្នឹងខាងៗនែ៎ ខាងខ្ញុំណោះ។ ហើយចាមហ្នឹងក៏លែងឱ្យនៅជុំគ្នាហើយ លែងចូលវិហារហើយ។ ហើយដល់មកឆ្នាំ១៩៧៥ហ្នឹង លោកចាប់ផ្ដើមចាកសិក្ខាបទម្ដងមួយៗ អស់នៅឆ្នាំ១៩៧៥។ ហើយចាមក៏គ្នាលែងបានថ្វាយបង្គំ។

[១៥:៥២:៣០]

**ស៖** ខ្ញុំដូចជាមិនយល់អំពីចម្លើយរបស់លោកទេ ខ្ញុំសូមឱ្យលោកបំភ្លឺ។ លោកឆ្លើយថា ចាប់ពីឆ្នាំចិតសិប -- ឆ្នាំ៧០មក គេលែងឱ្យប្រតិបត្តិសាសនា ឬក៏ចាប់ពី៧០ទៅ គេអាចប្រតិបត្តិសាសនាបាន? ចម្លើយលោក ខ្ញុំមិនយល់មិនច្បាស់ទេ។

**ឆ៖** ជិតត្រូវ។ កាលដំបូងឡើយ ដែលមានលោកដែរណ៎ា មានលោកដែរ តែពួកអ៊ីស្លាមក៏មានដែរ ក៏ប៉ុន្តែអ៊ីស្លាមគេជម្លៀសហើយ ពីឆ្នាំ១៩៧៣, ៧៤នោះ លែងឱ្យនៅហ្នឹងភូមិចាមហើយ លែងឱ្យចូលវិហារហើយ។ ឯលោក ក៏មិនសូវបានគង់នៅហ្នឹងវត្តទេ ចិញ្ចឹមសត្វចិញ្ចឹមធាតុទៅ ចិញ្ចឹមមាន់ចិញ្ចឹមអី យកទៅឧបត្ថម្ភសមរភូមិមុខ ហ្នឹងឆ្នាំ១៩៧៣, ៧៤។ ហើយដល់មកដល់ឆ្នាំ១៩៧៥ ក៏សឹកទៅ

ចាប់ផ្ដើមសឹក ដោយគេយល់ថា លោកមិនចង់បួសហើយ មិនដឹងធ្វើម៉េច សឹកទៅ។ ហ្នឹងដំណើរហ្នឹង អ៊ីចឹងទេ ទាន។

[១៥:៥៤:00]

**សះ** អ៊ីចឹងមានន័យថា ព្រះសង្ឃអាចមានសិទ្ធិសេរីភាពថា ខ្លួនលាចាកសិក្ខាបទ ឬមិនលាចាកសិក្ខាបទ ឬក៏គេបង្ខំ? ហើយបើសិនជាមានការបង្ខំនោះ តើមានព្រះសង្ឃណាប្រកែកមិនព្រមលាចាកសិក្ខាបទទេ?

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយ ពីព្រោះថា ខ្ញុំមិនអាចជំទាស់ទៅនឹងសំណួររបស់ចៅក្រមបានទេ។ ខ្ញុំចង់ដឹងថា តើស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះឬក៏អត់? ពីព្រោះថា អនុវត្តតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនោះ បញ្ហាព្រះពុទ្ធសាសនា គឺមិនស្ថិតនៅក្នុងវិធានការជាក់លាក់ ប្រឆាំងនឹងក្រុមជាក់លាក់ទេ។ អ៊ីចឹង ខ្ញុំចង់បានការបញ្ជាក់ឲ្យបានច្បាស់ ថាតើជាមួយនឹងសាក្សីរូបនេះ ដែលធ្វើការនៅការដ្ឋានទំនប់១មករានេះ យើងអាចនៅក្រៅវិសាលភាព ឬក៏អត់? ហើយអ៊ីចឹងបន្តទៅទៀតនោះ យើងធ្វើយ៉ាងម៉េចទៀត? ហើយអ៊ីចឹងតើគោលជំហររបស់ភាគីហ្នឹងយ៉ាងម៉េចដែរ ទៅលើបញ្ហានេះ?

[១៥:៥៥:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៦:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះល្អណាស់ ហើយសូមជម្រាបអ៊ីចេះថាជាបញ្ញត្តិរួមគឺដែលយើងបានកំណត់អំពីការបែងចែកអង្គហេតុហ្នឹង គឺច្បាស់លាស់ហើយ គឺអង្គហេតុណាគឺសួរពាក់ព័ន្ធនឹងអង្គហេតុហ្នឹង។ ហើយនៅក្នុងអង្គហេតុនៃទំនប់ ១មករា គឺវិសាលភាពមិនគ្របដណ្ដប់ពាក់ព័ន្ធជាមួយនឹងគោលដៅជាក់លាក់ ក៏ដូចជាខាងសាសនានោះទេ ធ្វើទុក្ខបុកម្នេញខាងសាសនាទេ ប៉ុន្តែការតាំងសំណួររបស់លោកចៅក្រម គឺក្នុងក្របខ័ណ្ឌ មួយគឺក្នុងបរិបទទូទៅប៉ុណ្ណោះ ដើម្បីកំណត់អំពីគោលនយោបាយនៃពាក់ព័ន្ធជាមួយនឹងសាសនារបស់បក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ មិនមែននិយាយស្ពរលម្អិតនោះទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីបំភ្លឺនោះ គឺថាមានការចោទប្រកាន់ថាមានគោលនយោបាយនៅទូទាំងប្រទេស កំណត់គោលដៅទៅលើក្រុមជាក់លាក់មួយចំនួនរួមទាំងព្រះពុទ្ធសាសនិក។ អ៊ីចឹងហើយយើងធ្វើយ៉ាងម៉េចដើម្បីកំណត់ក្របខ័ណ្ឌនៃគោលនយោបាយហ្នឹង ហើយសំនួររបស់ខ្ញុំគឺវាពាក់ព័ន្ធទៅនឹងបរិបទទូទៅទេ ខ្ញុំអត់ចូលទៅបញ្ចូលលម្អិតនៃអ្វីដែលបានកើតឡើងនៅការដ្ឋាន ១មករាទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី តើលោកនៅចាំសំណួរខ្ញុំទេ ឬក៏ចង់ឲ្យខ្ញុំសួរសំណួរអម្បាញ់មិញនេះ ឡើងវិញម្តងទៀត?

[១៥:៥៨:១៤]

**លោក ឱ ហួ៖**

**ឆ៖** ខ្ញុំភ្លេចហើយទាន។

**ស៖** លោកសាក្សីៗ អម្បាញ់មិញនេះ ខ្ញុំសួរលោកថាតើលោកដឹងទេថាមានព្រះសង្ឃ -- សួរថាតើការដែលឲ្យព្រះសង្ឃលាចាកសិក្ខាបទហ្នឹងជាការធ្វើឡើងដោយស្ម័គ្រចិត្ត ឬក៏មានការបង្ខំ? ហើយលោកដឹងទេថា តើមានព្រះសង្ឃអង្គណាប្រកែកមិនព្រមលាចាកសិក្ខាបទទេ? ហើយប្រសិនបើមានការប្រកែកបែបនេះ តើនឹងមានរឿងអ្វីកើតឡើងចំពោះព្រះសង្ឃអង្គនោះ?

**ឆ៖** ក្នុងនេះខ្ញុំបាទ ដឹងមិនអស់ទេទាន។ ក្នុងនយោបាយខ្ញុំបាទដឹងមិនអស់ទេទាន។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាឆ្នាំ១៩៧៥ ហ្នឹងព្រះសង្ឃសឹកអស់ហើយទាន ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** សំណួរចុងក្រោយ នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់១មករា លោកធ្លាប់ៗឮឈ្មោះ តាំ, តាតែ ទេ ដែលជាអតីតព្រះសង្ឃ?

**ឆ៖** គិតទៅខ្ញុំអត់ចាំទេ អត់ស្គាល់គាត់ទេ មិនស្គាល់ឈ្មោះគាត់ មិនដែលឃើញគាត់ទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១៦:០០:២៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ម៉ោងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី គឺចាប់ពីពេល

នេះតទៅ រហូតដល់ម៉ោងបីនិងដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ -- ច្រឡំ។

បាទ ឥឡូវនេះសវនាការថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២០ ខែឧសភា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ឌិ ហួ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ឌិ ហួ ដំណើរការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញបញ្ជូនលោក ឌិ ហួ វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ និងឲ្យសូមអញ្ជើញគាត់មកចូលរួមផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកឲ្យបានត្រឹមម៉ោងប្រាំបួនព្រឹក ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូប ត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*